ព្រះ
ត្រៃបិដកបាលី
និង
សេចក្ដីប្រែជាភាសាខ្មែរ
អភិធម្មបិដក
បដ្ឋាន ឆដ្ឋភាគ

៥៥

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស ២៥១០

អភិធម្មបិដកេ

បដ្ឋានស្ស ឆដ្ឋោ ភាគោ

បរិត្តារម្មណត្តិកំ

បដិច្ចវារោ

(១) បរិត្តារម្មណំ ធម្មំ បដិច្ច បរិត្តារម្មណោ ធម្មោ ឧប្បជ្ជតិ ហេតុបច្ចយា បរិត្តារម្មណំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ... បដិសន្ធិក្ខណេ បរិត្តារម្មណំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ... ។

(២) មហគ្គតារម្មណំ ធម្មំ បដិច្ច មហគ្គតារម្មណោ ធម្មោ ឧប្បជ្ជតិ ហេតុបច្ចយា មហគ្គតារម្មណំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ... បដិសន្ធិក្ខណេ មហគ្គតារម្មណំ ... ។

(៣) អប្បមាណារម្មណំ ធម្មំ បដិច្ច អប្បមាណារម្មណោ ធម្មោ ឧប្បជ្ជតិ ហេតុបច្ចយា អប្បមាណារម្មណំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ... ។

អភិធម្មបិដក

បដ្ឋាន ឆដ្ឋភាគ

បរិត្តារម្មណត្តិកៈ

បដិច្ចវារៈ

(១) ធម៌ ដែលមានអារម្មណ៍តូចឆ្មារ អាស្រ័យ នូវធម៌ ដែលមានអារម្មណ៍តូចឆ្មារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យ នូវខន្ធ ១ ដែលមានអារម្មណ៍តូចឆ្មារ នូវខន្ធ ២ ... ខន្ធ ៣ អាស្រ័យ នូវខន្ធ ១ ដែលមានអារម្មណ៍តូចឆ្មារ ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... ។

(២) ធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ អាស្រ័យ នូវធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យ នូវខន្ធ ១ ដែលមានអារម្មណ៍ដល់នូវសភាពធំ នូវខន្ធ ២ ... ដែលមានអារម្មណ៍ដល់នូវសភាពធំ ក្នុងខណៈនៃបដិសន្ធិ ... ។

(៣) ធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន អាស្រ័យ នូវធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យ នូវខន្ធ ១ ដែលមានអារម្មណ៍ប្រមាណមិនបាន នូវខន្ធ ២ ... ។

(៤) បរិត្តារម្មណំ ធម្មំ បដិច្ច បរិត្តារម្មណោ ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា អធិបតិប្បច្ចយា ។ សង្ខិត្តំ ។ អវិគតប្បច្ចយា ។

(៥) ហេតុយា តីណិ អារម្មណេ តីណិ អធិបតិយា តីណិ ។ សង្ខិត្តំ ។ អវិគតេ តីណិ ។ ឯវំ គណេតព្វំ ។

អនុលោមំ ។

(៦) បរិត្តារម្មណំ ធម្មំ បដិច្ច បរិត្តារម្មណោ ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា អហេតុកំ បរិត្តារម្មណំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ... អហេតុកបដិសន្ធិក្ខណេ បរិត្តារម្មណំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ... វិចិកិច្ឆាសហគតេ ឧទ្ធច្ចសហគតេ ខន្ធេ បដិច្ច វិចិកិច្ឆាសហគតោ ឧទ្ធច្ចសហគតោ មោហោ ។

(៧) មហគ្គតារម្មណំ ធម្មំ បដិច្ច មហគ្គតារម្មណោ ធម្មោ ... នហេតុប្បច្ចយា អហេតុកំ មហគ្គតារម្មណំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ... វិចិកិច្ឆាសហគតេ ឧទ្ធច្ចសហគតេ ខន្ធេ បដិច្ច វិចិកិច្ឆាសហគតោ ឧទ្ធច្ចសហគតោ មោហោ ។

(៤) ធម៌ ដែលមានអារម្មណ៍តូចឆ្មារ អាស្រ័យ នូវធម៌ ដែលមានអារម្មណ៍តូចឆ្មារ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ និងអធិបតិប្បច្ច័យ ។ សេចក្តីបំប្រួញ ។ ព្រោះអវិគតប្បច្ច័យ ។

(៥) ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ។ សេចក្តីបំប្រួញ ។ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិត គប្បីរាប់ យ៉ាងនេះចុះ ។

ចប់ អនុលោម ។

(៦) ធម៌ ដែលមានអារម្មណ៍តូចឆ្មារ អាស្រ័យ នូវធម៌ ដែលមានអារម្មណ៍តូចឆ្មារ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យ នូវអហេតុកក្ខន្ធ ១ ដែលមានអារម្មណ៍តូចឆ្មារ នូវខន្ធ ២ ... ខន្ធ ៣ អាស្រ័យ នូវខន្ធ ១ ដែលមានអារម្មណ៍តូចឆ្មារ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ នូវខន្ធ ២ ... មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យ នូវខន្ធទាំងឡាយ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។

(៧) ធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ អាស្រ័យ នូវធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ... ព្រោះនហេតុប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យ នូវអហេតុកក្ខន្ធ ១ ដែលមានអារម្មណ៍ដល់នូវសភាពធំ នូវខន្ធ ២ ... មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យ នូវខន្ធទាំងឡាយ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។

(៨) អប្បមាណារម្មណំ ធម្មំ បដិច្ច អប្បមាណារម្មណោ ធម្មោ ... នហេតុប្បច្ចយា អហេតុកំ អប្បមាណារម្មណំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ... ។

(៩) បរិត្តារម្មណំ ធម្មំ បដិច្ច បរិត្តារម្មណោ ធម្មោ ឧប្បជ្ជតិ នអធិបតិប្បច្ចយា បរិត្តារម្មណំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ... បដិសន្ធិក្ខណេ ... ។

(១០) មហគ្គតារម្មណំ ធម្មំ បដិច្ច មហគ្គតារម្មណោ ធម្មោ ឧប្បជ្ជតិ នអធិបតិប្បច្ចយា មហគ្គតារម្មណំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ... បដិសន្ធិក្ខណេ ... ។

(១១) អប្បមាណារម្មណំ ធម្មំ បដិច្ច អប្បមាណារម្មណោ ធម្មោ ... នអធិបតិប្បច្ចយា អប្បមាណារម្មណំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ... ។

(១២) បរិត្តារម្មណំ ធម្មំ បដិច្ច បរិត្តារម្មណោ ធម្មោ ... នបុរេជាតប្បច្ចយា អរូបេ បរិត្តារម្មណំ ឯកំ ខន្ធំ ... បដិសន្ធិក្ខណេ ... ។

(៨) ធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន អាស្រ័យនូវធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន ... ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវអហេតុកក្ខន្ធ ១ ដែលមានអារម្មណ៍ប្រមាណមិនបាន នូវខន្ធ ២ ... ។

(៩) ធម៌ ដែលមានអារម្មណ៍តូចឆ្មារ អាស្រ័យនូវធម៌ ដែលមានអារម្មណ៍តូចឆ្មារ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលមានអារម្មណ៍តូចឆ្មារ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ... ។

(១០) ធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ អាស្រ័យនូវធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលមានអារម្មណ៍ដល់នូវសភាពធំ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ... ។

(១១) ធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន អាស្រ័យនូវធម៌ ដែលមានប្រមាណមិនបាន ... ព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលមានអារម្មណ៍ប្រមាណមិនបាន នូវខន្ធ ២ ... ។

(១២) ធម៌ ដែលមានអារម្មណ៍តូចឆ្មារ អាស្រ័យនូវធម៌ ដែលមានអារម្មណ៍តូចឆ្មារ ... ព្រោះនបុរេជាតប្បច្ច័យ គឺនូវខន្ធ ១ ដែលមានអារម្មណ៍តូចឆ្មារ ក្នុងអរូប ... ក្នុងខណៈនៃបដិសន្ធិ ... ។

(១៣) មហគ្គតារម្មណំ ធម្មំ បដិច្ច មហគ្គតារម្មណោ ធម្មោ ... នបុរេជាតបច្ចយា អរូបេ មហគ្គតារម្មណំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ... នបុរេជាតបច្ចយា មហគ្គតារម្មណោ បដិសន្ធិ នត្ថិ ។

(១៤) អប្បមាណារម្មណំ ធម្មំ បដិច្ច អប្បមាណារម្មណោ ធម្មោ ... នបុរេជាតបច្ចយា អរូបេ អប្បមាណារម្មណំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ... ។ នបច្ឆាជាតបច្ចយញ្ច នអាសេវនបច្ចយញ្ច នអធិបតិសទិសំ ។

(១៥) បរិត្តារម្មណំ ធម្មំ បដិច្ច បរិត្តារម្មណោ ធម្មោ ... នកម្មបច្ចយា បរិត្តារម្មណេ ខន្ធេ បដិច្ច បរិត្តារម្មណា ចេតនា ។

(១៦) មហគ្គតារម្មណំ ធម្មំ បដិច្ច មហគ្គតារម្មណោ ធម្មោ ... នកម្មបច្ចយា មហគ្គតារម្មណេ ខន្ធេ បដិច្ច មហគ្គតារម្មណា ចេតនា ។

(១៣) ធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ អាស្រ័យនូវធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ... ព្រោះនបុរេជាតបច្ច័យ គឺ ខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលមានអារម្មណ៍ដល់នូវសភាពធំ ក្នុងអរូប នូវខន្ធ ២ ... បដិសន្ធិ មិនមាន ក្នុងអារម្មណ៍ដល់នូវសភាពធំ ព្រោះនបុរេជាតបច្ច័យទេ ។

(១៤) ធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន អាស្រ័យនូវធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន ... ព្រោះនបុរេជាតបច្ច័យ គឺ ខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលមានអារម្មណ៍ប្រមាណមិនបាន ក្នុងអរូប នូវខន្ធ ២ ... នបច្ឆាជាតបច្ច័យ និងនអាសេវនបច្ច័យ ដូចគ្នានឹងនអធិបតិបច្ច័យដែរ ។

(១៥) ធម៌ ដែលមានអារម្មណ៍តូចឆ្មារ អាស្រ័យនូវធម៌ ដែលមានអារម្មណ៍តូចឆ្មារ ... ព្រោះនកម្មបច្ច័យ គឺ ចេតនា ដែលមានអារម្មណ៍តូចឆ្មារ អាស្រ័យនូវខន្ធទាំងឡាយ ដែលមានអារម្មណ៍តូចឆ្មារ ។

(១៦) ធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ អាស្រ័យនូវធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ... ព្រោះនកម្មបច្ច័យ គឺ ចេតនា ដែលមានអារម្មណ៍ដល់នូវសភាពធំ អាស្រ័យនូវខន្ធទាំងឡាយ ដែលមានអារម្មណ៍ដល់នូវសភាពធំ ។

(១៧) អប្បមាណារម្មណំ ធម្មំ បដិច្ច អប្បមាណារម្មណោ ធម្មោ ... នកម្មប្បច្ចយា អប្បមាណារម្មណេ ខន្ធេ បដិច្ច អប្បមាណារម្មណា ចេតនា ។

(១៨) បរិត្តារម្មណំ ធម្មំ បដិច្ច បរិត្តារម្មណោ ធម្មោ ... នវិបាកប្បច្ចយា បដិសន្ធិ នត្ថិ ។ នឈានប្បច្ចយា បញ្ចវិញ្ញាណសហគតំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ... ។ នមគ្គប្បច្ចយា អហេតុកំ បរិត្តារម្មណំ ឯកំ ខន្ធំ ... ទ្វេ ខន្ធេ ... អហេតុកបដិសន្ធិក្ខណេ ទ្វេ ខន្ធេ ... ។

(១៩) មហគ្គតារម្មណំ ធម្មំ បដិច្ច មហគ្គតារម្មណោ ធម្មោ ... នមគ្គប្បច្ចយា អហេតុកំ មហគ្គតារម្មណំ ឯកំ ខន្ធំ ... ទ្វេ ខន្ធេ ... ។

(២០) អប្បមាណារម្មណំ ធម្មំ បដិច្ច អប្បមាណារម្មណោ ធម្មោ ... នមគ្គប្បច្ចយា អហេតុកំ អប្បមាណារម្មណំ ឯកំ ខន្ធំ ... ទ្វេ ខន្ធេ ... ។

(២១) បរិត្តារម្មណំ ធម្មំ បដិច្ច បរិត្តារម្មណោ ធម្មោ ... នវិប្បយុត្តប្បច្ចយា អរូបេ បរិត្តារម្មណំ ឯកំ ខន្ធំ ... ។

(១៧) ធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន អាស្រ័យនូវធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន ... ព្រោះនកម្មប្បច្ច័យ គឺ ចេតនា ដែលមានអារម្មណ៍ប្រមាណមិនបាន អាស្រ័យនូវខន្ធទាំងឡាយ ដែលមានអារម្មណ៍ប្រមាណមិនបាន ។

(១៨) ធម៌ ដែលមានអារម្មណ៍តូចឆ្មារ អាស្រ័យនូវធម៌ ដែលមានអារម្មណ៍តូចឆ្មារ ... ព្រោះនវិបាកប្បច្ច័យ គឺ បដិសន្ធិ មិនមានទេ ។ ព្រោះនឈានប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយវិញ្ញាណ ៥ នូវខន្ធ ២ ... ។ ព្រោះនមគ្គប្បច្ច័យ គឺ នូវអហេតុកខន្ធ ១ ដែលមានអារម្មណ៍តូចឆ្មារ ... នូវខន្ធ ២ ... នូវខន្ធ ២ ក្នុងខណៈនៃអហេតុកបដិសន្ធិ ... ។

(១៩) ធម៌ ដែលមានអារម្មណ៍ដល់នូវមហគ្គតៈ អាស្រ័យនូវធម៌ ដែលមានអារម្មណ៍ដល់នូវមហគ្គតៈ ... ព្រោះនមគ្គប្បច្ច័យ គឺ នូវអហេតុកខន្ធ ១ ដែលមានអារម្មណ៍ដល់នូវមហគ្គតៈ ... នូវខន្ធ ២ ... ។

(២០) ធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន អាស្រ័យនូវធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន ... ព្រោះនមគ្គប្បច្ច័យ គឺ នូវអហេតុកខន្ធ ១ ដែលមានអារម្មណ៍ប្រមាណមិនបាន ... នូវខន្ធ ២ ... ។

(២១) ធម៌ ដែលមានអារម្មណ៍តូចឆ្មារ អាស្រ័យនូវធម៌ ដែលមានអារម្មណ៍តូចឆ្មារ ... ព្រោះនវិប្បយុត្តប្បច្ច័យ គឺ នូវខន្ធ ១ ដែលមានអារម្មណ៍តូចឆ្មារ ក្នុងអរូប ... ។

(៦២) មហគ្គតារម្មណំ ធម្មំ បដិច្ច មហគ្គតារម្មណោ ធម្មោ ... នវិប្បយុត្តប្បច្ចយា អរូបេ មហគ្គតារម្មណំ ឯកំ ខន្ធំ ... ។

(៦៣) អប្បមាណារម្មណំ ធម្មំ បដិច្ច អប្បមាណារម្មណោ ធម្មោ ... នវិប្បយុត្តប្បច្ចយា អរូបេ អប្បមាណារម្មណំ ឯកំ ខន្ធំ ... ទ្វេ ខន្ធេ ... ។

(៦៤) នហេតុយា តីណិ នអធិបតិយា តីណិ ។ បេ ។ នបុរេជាតេ តីណិ នបច្ឆាជាតេ តីណិ នអាសេវនេ តីណិ នកម្មេ តីណិ នវិបាកេ តីណិ នឈានេ ឯកំ នមគ្គេ តីណិ នវិប្បយុត្តេ តីណិ ។ ឯវំ គណេតព្វំ ។

បច្ចនីយំ ។

(៦៥) ហេតុប្បច្ចយា នអធិបតិយា តីណិ ... នបុរេជាតេ តីណិ នបច្ឆាជាតេ តីណិ នអាសេវនេ តីណិ នកម្មេ តីណិ នវិបាកេ តីណិ នវិប្បយុត្តេ តីណិ ។ ឯវំ គណេតព្វំ ។

អនុលោមបច្ចនីយំ ។

(៦២) ធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ អាស្រ័យ នូវធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ... ព្រោះនវិប្បយុត្តប្បច្ច័យ គឺ នូវខន្ធ ១ មានអារម្មណ៍ដល់នូវសភាពធំ ក្នុងអរូប ... ។

(៦៣) ធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន អាស្រ័យ នូវធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន ... ព្រោះនវិប្បយុត្តប្បច្ច័យ គឺ នូវខន្ធ ១ ដែលមានអារម្មណ៍ប្រមាណមិនបាន ក្នុងអរូប ... នូវខន្ធ ២ ... ។

(៦៤) ក្នុងនហេតុប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ។ បេ ។ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិត គប្បីរាប់ យ៉ាងនេះចុះ ។

ចប់ បច្ចនីយៈ ។

(៦៥) ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ... ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិត គប្បីរាប់ យ៉ាងនេះចុះ ។

ចប់ អនុលោមបច្ចនីយៈ ។

[៦២] ហេតុប្បច្ចយា អារម្មណេ តីណិ ... អនន្តរេ តីណិ សមនន្តរេ តីណិ សហជាតេ តីណិ អញ្ញមញ្ញេ តីណិ និស្សយេ តីណិ ឧបនិស្សយេ តីណិ បុរេជាតេ តីណិ អាសេវនេ ទ្វេ កម្មេ តីណិ វិបាកេ ឯកំ អាហារេ តីណិ ឥន្ទ្រិយេ តីណិ ឈានេ តីណិ មគ្គេ ទ្វេ សម្បយុត្តេ តីណិ វិប្បយុត្តេ តីណិ អត្ថិយា តីណិ នត្ថិយា តីណិ វិគតេ តីណិ អវិគតេ តីណិ ។ ឯវំ គណេតព្វំ ។

បច្ចនីយានុលោមំ ។

បដិច្ចវារោ និដ្ឋិតោ ។

សហជាតវារោបិ បច្ចយវារោបិ និស្សយវារោបិ សំសដ្ឋវារោបិ សម្បយុត្តវារោបិ បដិច្ចវារសទិសោ ។

បញ្ហាវារោ

[៦៣] បរិត្តារម្មណោ ធម្មោ បរិត្តារម្មណស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ បរិត្តារម្មណា ហេតូ សម្បយុត្តកានំ ខន្ធានំ ហេតុប្បច្ចយេន បច្ចយោ

(៦២) ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យមានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ២ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងវិគតប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិត គប្បីរាប់ យ៉ាងនេះចុះ ។

ចប់ បច្ចនីយានុលោម ។

ចប់ បដិច្ចវារៈ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

បញ្ហាវារៈ

(៦៣) ធម៌ ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍តូចឆ្មារ ដោយហេតុប្បច្ច័យ គឺ ពួកហេតុ ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ

បដិសន្ធិក្ខណេ បរិត្តារម្មណា ហេតូ សម្បយុត្តកានំ ខន្ធានំ ហេតុបច្ចយេន បច្ចយោ ។

(២៨) មហគ្គតារម្មណោ ធម្មោ មហគ្គតារម្មណស្ស ធម្មស្ស ហេតុបច្ចយេន បច្ចយោ មហគ្គតារម្មណា ហេតូ សម្បយុត្តកានំ ខន្ធានំ ហេតុបច្ចយេន បច្ចយោ បដិសន្ធិក្ខណេ . . . ។

(២៩) អប្បមាណារម្មណោ ធម្មោ អប្បមាណារម្មណស្ស ធម្មស្ស ហេតុបច្ចយេន បច្ចយោ អប្បមាណារម្មណា ហេតូ សម្បយុត្តកានំ ខន្ធានំ ហេតុបច្ចយេន បច្ចយោ ។

(៣០) បរិត្តារម្មណោ ធម្មោ បរិត្តារម្មណស្ស ធម្មស្ស អារម្មណបច្ចយេន បច្ចយោ ទានំ ទត្វា សីលំ សមាទិយិត្វា ឧបោសថកម្មំ កត្វា តំ បច្ចវេក្ខតិ បុព្វេ សុចិណ្ណានិ បច្ចវេក្ខតិ អរិយា បរិត្តារម្មណេ បហីនេ កិលេសេ បច្ចវេក្ខន្តិ វិក្ខម្ភិតេ កិលេសេ បច្ចវេក្ខន្តិ បុព្វេ សមុទាចិណ្ណេ កិលេសេ ជានន្តិ បរិត្តារម្មណេ បរិត្តេ ខន្ធេ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សន្តិ

ពួកហេតុ ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធ ក្នុងខណៈនៃបដិសន្ធិ ដោយហេតុប្បច្ច័យ ។

(២៨) ធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ដោយហេតុប្បច្ច័យ គឺ ពួកហេតុ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ . . . ។

(២៩) ធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន ដោយហេតុប្បច្ច័យ គឺ ពួកហេតុ ដែលមានអារម្មណ៍ប្រមាណមិនបាន ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។

(៣០) ធម៌ ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍តូចឆ្មារ ដោយអារម្មណប្បច្ច័យ គឺ បុគ្គល ឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ហើយពិចារណា នូវកុសល នោះ ពិចារណា នូវកុសលទាំងឡាយ ដែលសន្សំល្អហើយ ក្នុងកាលមុន ព្រះអរិយទាំងឡាយ ពិចារណា នូវពួកកិលេស ដែលមានអារម្មណ៍តូចឆ្មារ ដែលលះបង់ហើយ ពិចារណា នូវពួកកិលេស ដែលសង្កត់សង្កិនហើយ ដឹង នូវពួកកិលេស ដែលធ្លាប់សន្សំមក ក្នុងកាលមុន ឃើញច្បាស់ នូវខន្ធទាំងឡាយតូចឆ្មារ ដែលមានអារម្មណ៍តូចឆ្មារ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន

ស្សាទេន្តិ អភិនន្ទន្តិ តំ អារព្ភ បរិត្តារម្មណោ រាគោ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ ចេតោបរិយញ្ញាណេន បរិត្តារម្មណបរិត្តចិត្តសមង្គិស្ស ចិត្តំ ជានាតិ បរិត្តារម្មណា បរិត្តា ខន្ធា ចេតោបរិយញ្ញាណស្ស បុព្វេនិវាសានុស្សតិញ្ញាណស្ស យថាកម្មូបគញ្ញាណស្ស អនាគតំសញ្ញាណស្ស អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ ។

(៣១) បរិត្តារម្មណោ ធម្មោ មហគ្គតារម្មណស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ទិព្វំ ចក្ខុំ បច្ចវេក្ខតិ ទិព្វំ សោតធាតុំ បច្ចវេក្ខតិ បរិត្តារម្មណំ ឥទ្ធិវិធញ្ញាណំ បច្ចវេក្ខតិ ចេតោបរិយញ្ញាណំ ... បុព្វេនិវាសានុស្សតិញ្ញាណំ ... យថាកម្មូបគញ្ញាណំ ... អនាគតំសញ្ញាណំ បច្ចវេក្ខតិ បរិត្តារម្មណេ មហគ្គតេ ខន្ធេ អនិច្ចតោ ... វិបស្សតិ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ មហគ្គតារម្មណោ រាគោ ... ទោមនស្សំ ឧប្បជ្ជតិ ចេតោបរិយញ្ញាណេន បរិត្តារម្មណមហគ្គតចិត្តសមង្គិស្ស ចិត្តំ ជានាតិ

ត្រេកអរ រីករាយ រាគៈ ដែលមានអារម្មណ៍តូចឆ្មារ ប្រារព្ធ នូវពួកខន្ធនោះ ទើបកើតឡើង ទោមនស្ស កើតឡើង បុគ្គល ដឹង នូវចិត្តនៃបុគ្គល អ្នកប្រកបដោយចិត្តតូចឆ្មារដែលមានអារម្មណ៍តូចឆ្មារ ដោយចេតោបរិយញ្ញាណ ពួកខន្ធ តូចឆ្មារ ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃការពិចារណា នូវចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

(៣១) ធម៌ ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ដោយអារម្មណប្បច្ច័យ គឺ បុគ្គល ពិចារណា នូវទិព្វចក្ខុ ពិចារណា នូវទិព្វសោតធាតុ ពិចារណា នូវឥទ្ធិវិធញ្ញាណ ដែលមានអារម្មណ៍តូចឆ្មារ នូវចេតោបរិយញ្ញាណ ... នូវបុព្វេនិវាសានុស្សតិញ្ញាណ ... នូវយថាកម្មូបគញ្ញាណ ... ពិចារណា នូវអនាគតំសញ្ញាណ ឃើញច្បាស់ នូវពួកខន្ធ ដែលដល់នូវសភាពធំ ដែលមានអារម្មណ៍តូចឆ្មារ ជាមិនទៀង ... ត្រេកអរ រីករាយ រាគៈ ដែលមានអារម្មណ៍ដល់នូវសភាពធំ ប្រារព្ធ នូវខន្ធនោះ ... ទោមនស្ស កើតឡើង បុគ្គល ដឹង នូវចិត្តនៃបុគ្គលអ្នកប្រកបដោយចិត្ត ដល់នូវសភាពធំ ដែលមានអារម្មណ៍តូចឆ្មារ ដោយចេតោបរិយញ្ញាណ

បរិត្តារម្មណា មហគ្គតា ខន្ធា ចេតោបរិយញាណស្ស បុព្វេនិវាសានុស្សតិញាណស្ស អនាគតំសញាណស្ស អាវជ្ជនាយ អារម្មណបច្ចយេន បច្ចយោ ។

(៣៦) មហគ្គតារម្មណោ ធម្មោ មហគ្គតារម្មណស្ស ធម្មស្ស អារម្មណបច្ចយេន បច្ចយោ ។ បេ ។ វិញ្ញាណញ្ចាយតនំ បច្ចវេក្ខតិ នេវសញ្ញានាសញ្ញាយតនំ បច្ចវេក្ខតិ មហគ្គតារម្មណំ បច្ចវេក្ខតិ ចេតោបរិយញាណំ ... បុព្វេនិវាសានុស្សតិញាណំ ... យថាកម្មូបគញាណំ ... អនាគតំសញាណំ បច្ចវេក្ខតិ មហគ្គតារម្មណេ មហគ្គតេ ខន្ធេ អនិច្ចតោ ... វិបស្សតិ អស្សាទេតិ តំ អារព្ភ មហគ្គតារម្មណោ រាគោ ... ទោមនស្សំ ឧប្បជ្ជតិ ចេតោបរិយញាណេន មហគ្គតារម្មណមហគ្គតចិត្តសមង្គិស្ស ចិត្តំ ជានាតិ មហគ្គតារម្មណា មហគ្គតា ខន្ធា ចេតោបរិយញាណស្ស បុព្វេនិវាសានុស្សតិញាណស្ស យថាកម្មូបគញាណស្ស អនាគតំសញាណស្ស អាវជ្ជនាយ អារម្មណបច្ចយេន បច្ចយោ ។

ពួកខន្ធ ដែលដល់នូវសភាពធំ ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃការពិចារណា នូវចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

(៣៦) ធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ដោយអារម្មណប្បច្ច័យ ។ បេ ។ បុគ្គល ពិចារណា នូវវិញ្ញាណញ្ចាយតនៈ ពិចារណា នូវនេវសញ្ញានាសញ្ញាយតនៈ ពិចារណា នូវអារម្មណ៍ដែលដល់នូវសភាពធំ នូវចេតោបរិយញ្ញាណ ... នូវបុព្វេនិវាសានុស្សតិញ្ញាណ ... នូវយថាកម្មូបគញ្ញាណ ... ពិចារណា នូវអនាគតំសញ្ញាណ ឃើញច្បាស់ នូវពួកខន្ធ ដែលមានសភាពធំ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាមិនទៀង ... ត្រេកអរ រាគៈ ដែលមានអារម្មណ៍ដល់នូវសភាពធំ ប្រារព្ធ នូវខន្ធនោះ ... ទោមនស្ស កើតឡើង បុគ្គល ដឹងនូវចិត្ត នៃបុគ្គលអ្នកប្រកបដោយចិត្ត ដែលមានសភាពធំ ដែលមានអារម្មណ៍ដល់នូវសភាពធំ ដោយចេតោបរិយញ្ញាណ ពួកខន្ធ ដែលដល់នូវសភាពធំ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃការពិចារណា នូវចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

(៣៣) មហគ្គតារម្មណោ ធម្មោ បរិត្តារម្មណស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ បឋមជ្ឈានប្បច្ចវេក្ខណំ បច្ចវេក្ខតិ នេវសញ្ញានាសញ្ញាយតនប្បច្ចវេក្ខណំ បច្ចវេក្ខតិ ទិព្វចក្ខុប្បច្ចវេក្ខណំ បច្ចវេក្ខតិ ទិព្វសោតធាតុប្បច្ចវេក្ខណំ បច្ចវេក្ខតិ ឥទ្ធិវិធញ្ញាណ ... ចេតោបរិយញ្ញាណ ... បុព្វេនិវាសានុស្សតិញ្ញាណ ... យថាកម្មូបគញ្ញាណ ... អនាគតំសញ្ញាណប្បច្ចវេក្ខណំ បច្ចវេក្ខតិ អរិយា មហគ្គតារម្មណេ បហីនេ កិលេសេ បច្ចវេក្ខន្តិ វិក្ខម្ភិតេ កិលេសេ បច្ចវេក្ខន្តិ បុព្វេ សមុទាចិណ្ណេ កិលេសេ ជានន្តិ មហគ្គតារម្មណេ ខន្ធេ អនិច្ចតោ ... វិបស្សតិ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ បរិត្តារម្មណោ រាគោ ... ទោមនស្សំ ឧប្បជ្ជតិ ចេតោបរិយញ្ញាណេន មហគ្គតារម្មណបរិត្តចិត្តសមង្គិស្ស ចិត្តំ ជានាតិ មហគ្គតារម្មណា ខន្ធា ចេតោបរិយញ្ញាណស្ស បុព្វេនិវាសានុស្សតិញ្ញាណស្ស យថាកម្មូបគញ្ញាណស្ស អនាគតំសញ្ញាណស្ស អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ ។

(៣៣) ធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍តូចឆ្មារ ដោយអារម្មណប្បច្ច័យ គឺ បុគ្គលពិចារណា នូវបឋមជ្ឈានប្បច្ចវេក្ខណៈ ពិចារណា នូវនេវសញ្ញានាសញ្ញាយតនប្បច្ចវេក្ខណ ពិចារណា នូវទិព្វចក្ខុប្បច្ចវេក្ខណ ពិចារណា នូវទិព្វសោតធាតុប្បច្ចវេក្ខណ នូវឥទ្ធិវិធញ្ញាណ ... នូវចេតោបរិយញ្ញាណ ... នូវបុព្វេនិវាសានុស្សតិញ្ញាណ ... នូវយថាកម្មូបគញ្ញាណ ... ពិចារណា នូវអនាគតំសញ្ញាណប្បច្ចវេក្ខណៈ ព្រះអរិយៈទាំងឡាយ ពិចារណា នូវពួកកិលេស ដែលមានអារម្មណ៍ដល់នូវសភាពធំ ដែលលះបង់ហើយ ពិចារណា នូវពួកកិលេស ដែលសង្កត់សង្កិនហើយ ដឹងនូវពួកកិលេស ដែលធ្លាប់សន្សំហើយ ក្នុងកាលមុន បុគ្គល ឃើញច្បាស់ នូវពួកខន្ធតូចឆ្មារ ដែលមានអារម្មណ៍ដល់នូវសភាពធំ ថាមិនទៀង ... ត្រេកអរ រីករាយ រាគៈ ដែលមានអារម្មណ៍តូចឆ្មារ ព្រោះប្រារព្ធ នូវពួកខន្ធនោះ ... ទោមនស្ស កើតឡើង បុគ្គល ដឹងនូវចិត្តនៃបុគ្គលអ្នកប្រកបដោយចិត្តតូចឆ្មារ ដែលមានអារម្មណ៍ដល់នូវសភាពធំ ដោយចេតោបរិយញ្ញាណ ពួកខន្ធតូចឆ្មារ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃការពិចារណា នូវចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

(៣៦) អប្បមាណារម្មណោ ធម្មោ អប្បមាណារម្មណស្ស ធម្មស្ស អារម្មណបច្ចយេន បច្ចយោ អរិយា មគ្គា វុដ្ឋហិត្វា មគ្គំ បច្ចវេក្ខន្តិ ផលំ បច្ចវេក្ខន្តិ ចេតោបរិយញាណេន អប្បមាណារម្មណបរិត្តចិត្តសមង្គិស្ស ចិត្តំ ជានាតិ អប្បមាណារម្មណា ខន្ធា ចេតោបរិយញាណស្ស បុព្វេនិវាសានុស្សតិញ្ញាណស្ស យថាកម្មូបគញ្ញាណស្ស អនាគតំសញ្ញាណស្ស អាវជ្ជនាយ អារម្មណបច្ចយេន បច្ចយោ ។

(៣៧) អប្បមាណារម្មណោ ធម្មោ បរិត្តារម្មណស្ស ធម្មស្ស អារម្មណបច្ចយេន បច្ចយោ អរិយា គោត្រភុំ បច្ចវេក្ខន្តិ វោទានំ បច្ចវេក្ខន្តិ មគ្គបច្ចវេក្ខណំ បច្ចវេក្ខន្តិ ផលបច្ចវេក្ខណំ បច្ចវេក្ខន្តិ និព្វានបច្ចវេក្ខណំ បច្ចវេក្ខន្តិ អប្បមាណារម្មណេ បរិត្តេ ខន្ធេ អនិច្ចតោ ... វិបស្សតិ ចេតោបរិយញាណេន អប្បមាណារម្មណបរិត្តចិត្តសមង្គិស្ស ចិត្តំ ជានាតិ អប្បមាណារម្មណា បរិត្តា ខន្ធា ចេតោបរិយញាណស្ស បុព្វេនិវាសានុស្សតិញ្ញាណស្ស យថាកម្មូបគញ្ញាណស្ស អនាគតំសញ្ញាណស្ស អាវជ្ជនាយ អារម្មណបច្ចយេន បច្ចយោ ។

(៣៦) ធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន ដោយអារម្មណប្បច្ច័យ គឺព្រះអរិយៈទាំងឡាយ ចេញអំពីមគ្គ ហើយពិចារណា នូវមគ្គ ពិចារណា នូវផល បុគ្គល ដឹង នូវចិត្ត នៃបុគ្គលអ្នកប្រកបដោយចិត្តតូចឆ្មារ ដែលមានអារម្មណ៍ប្រមាណមិនបាន ដោយចេតោបរិយញ្ញាណ ខន្ធទាំងឡាយ ដែលមានអារម្មណ៍ប្រមាណមិនបាន ជាបច្ច័យ នៃការពិចារណា នូវចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

(៣៧) ធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍តូចឆ្មារ ដោយអារម្មណប្បច្ច័យ គឺ ព្រះអរិយៈទាំងឡាយ ពិចារណា នូវគោត្រភូ ពិចារណា នូវវោទានៈ ពិចារណា នូវមគ្គប្បច្ចវេក្ខណៈ ពិចារណា នូវផលប្បច្ចវេក្ខណៈ ពិចារណា នូវនិព្វានប្បច្ចវេក្ខណៈ បុគ្គល ឃើញច្បាស់ នូវខន្ធទាំងឡាយ តូចឆ្មារ ដែលមានអារម្មណ៍ប្រមាណមិនបាន ថាមិនទៀង ... ដឹង នូវចិត្ត នៃបុគ្គលអ្នកប្រកបដោយចិត្តតូចឆ្មារ ដែលមានអារម្មណ៍ប្រមាណមិនបាន ដោយចេតោបរិយញ្ញាណ ខន្ធទាំងឡាយ តូចឆ្មារ ដែលមានអារម្មណ៍ប្រមាណមិនបាន ជាបច្ច័យ នៃការពិចារណា នូវចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

(៣៦) អប្បមាណារម្មណោ ធម្មោ មហគ្គតារម្មណស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។ អរិយា អប្បមាណារម្មណំ ចេតោបរិយញាណំ បច្ចវេក្ខន្តិ ... បុព្វេនិវាសានុស្សតិញាណស្ស អនាគតំសញាណស្ស អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ ។

(៣៧) បរិត្តារម្មណោ ធម្មោ បរិត្តារម្មណស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ អារម្មណាធិបតិ សហជាតាធិបតិ ។ អារម្មណាធិបតិ ទានំ ទត្វា សីលំ សមាទិយិត្វា ឧបោសថកម្មំ កត្វា តំ គរុំ កត្វា បច្ចវេក្ខតិ បុព្វេ សុចិណ្ណានិ គរុំ (១) កត្វា បច្ចវេក្ខតិ បរិត្តារម្មណេ ខន្ធេ គរុំ កត្វា អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ ។ សហជាតាធិបតិ បរិត្តារម្មណាធិបតិ សម្បយុត្តកានំ ខន្ធានំ អធិបតិប្បច្ចយេន បច្ចយោ ។

(៣៨) បរិត្តារម្មណោ ធម្មោ មហគ្គតារម្មណស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ ។ អារម្មណាធិបតិ ទិព្វំ ចក្ខុំ គរុំ កត្វា បច្ចវេក្ខតិ

១ ម. តំ គរុំ ។

(៣៦) ធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ដោយអារម្មណប្បច្ច័យ គឺ ព្រះអរិយៈទាំងឡាយ ពិចារណា នូវចេតោបរិយញ្ញាណ ដែលមានអារម្មណ៍ប្រមាណមិនបាន ... ជាបច្ច័យ នៃការពិចារណា នូវបុព្វេនិវាសានុស្សតិញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

(៣៧) ធម៌ ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍តូចឆ្មារ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺ បុគ្គល ឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ហើយធ្វើ នូវកុសលនោះ ឲ្យជាទីគោរព ហើយពិចារណា ធ្វើ នូវកុសលទាំងឡាយ ដែលធ្លាប់សន្សំល្អ ហើយក្នុងកាលមុន ឲ្យជាទីគោរព ហើយពិចារណា ធ្វើ នូវខន្ធទាំងឡាយ តូចឆ្មារ ដែលមានអារម្មណ៍តូចឆ្មារ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ ព្រោះធ្វើ នូវកុសលនោះ ឲ្យជាទីគោរព ទើបរាគៈកើតឡើង ទិដ្ឋិ កើតឡើង ។ ឯសហជាតាធិបតិ គឺ អធិបតិធម៌ ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃពួកសម្បយុត្តកខន្ធ ដោយអធិបតិប្បច្ច័យ ។

(៣៨) ធម៌ ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ គឺ បុគ្គល ធ្វើ នូវទិព្វចក្ខុ ឲ្យជាទីគោរពហើយ ពិចារណា

ទិព្វំ សោតធាតុំ ... បរិត្តារម្មណំ ឥទ្ធិវិធញ្ញាណំ ចេតោបរិយញ្ញាណំ បុព្វេនិវាសានុស្សតិញ្ញាណំ យថា-កម្មូបគញ្ញាណំ ... អនាគតំសញ្ញាណំ បច្ចវេក្ខតិ បរិត្តារម្មណេ មហគ្គតេ ខន្ធេ គរុំ កត្វា អស្សាទេ-តិ តំ គរុំ កត្វា មហគ្គតារម្មណោ រាគោ ... ទិដ្ឋិ ឧប្បជ្ជតិ ។

(៣៩) មហគ្គតារម្មណោ ធម្មោ មហគ្គតារម្ម-ណស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ អា-រម្មណាធិបតិ សហជាតាធិបតិ ។ អារម្មណាធិបតិ វិញ្ញាណញ្ចាយតនំ គរុំ កត្វា ... នេវសញ្ញានាសញ្ញា-យតនំ ... មហគ្គតារម្មណំ ឥទ្ធិវិធញ្ញាណំ ... ចេតោ-បរិយញ្ញាណំ បុព្វេនិវាសានុស្សតិញ្ញាណំ យថាកម្ម-ូបគញ្ញាណំ ... អនាគតំសញ្ញាណំ គរុំ កត្វា ... មហគ្គតារម្មណេ មហគ្គតេ ខន្ធេ គរុំ កត្វា អស្សា-ទេតិ តំ គរុំ កត្វា មហគ្គតារម្មណោ រាគោ ... ទិដ្ឋិ ... ។ សហជាតាធិបតិ មហគ្គតារម្មណាធិបតិ សម្បយុត្តកានំ ខន្ធានំ អធិបតិប្បច្ចយេន បច្ចយោ ។

នូវទិព្វសោតធាតុ ... នូវឥទ្ធិវិធញ្ញាណ មានអារម្មណ៍តូចទាប ចេតោ-បរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ ... ពិចារណា នូវអនាគតំសញ្ញាណ ធ្វើ នូវខន្ធទាំងឡាយ ដែលដល់នូវសភាពធំ តែមានអារម្មណ៍តូចទាប ឲ្យជាទីគោរព ហើយត្រេកអរ រាគៈ មានអារម្មណ៍ដល់នូវសភាពធំ ធ្វើនូវខន្ធនោះ ឲ្យជាទីគោរព ... ទិដ្ឋិកើតឡើង ។

(៣៩) ធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ដោយអធិបតិប្បច្ច័យ បាន ដល់អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺ បុគ្គល ធ្វើ វិញ្ញាណញ្ចាយតនៈ ឲ្យជាទីគោរព ... នេវសញ្ញានាសញ្ញា-យតនៈ ... ឥទ្ធិវិធញ្ញាណ ដែលមានអារម្មណ៍ដល់នូវសភាពធំ ... ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ ... ធ្វើនូវអនាគតំសញ្ញាណ ឲ្យជាទីគោរព ... ធ្វើ នូវខន្ធទាំងឡាយ ដែលដល់នូវសភាពធំ មានអារម្មណ៍ដល់នូវសភាពធំ ឲ្យជាទីគោរព ហើយត្រេកអរ រាគៈ ដែលមានអារម្មណ៍ដល់នូវសភាពធំ ធ្វើ នូវខន្ធនោះ ឲ្យជាទីគោរព ... ទិដ្ឋិ ... ។ ឯសហជាតាធិបតិ គឺ អធិបតិធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃខន្ធ សម្បយុត្តកខន្ធ ដោយអធិបតិប្បច្ច័យ ។

(៤០) មហគ្គតារម្មណោ ធម្មោ បរិត្តារម្មណស្ស ធម្មស្ស អធិបតិបច្ចយេន បច្ចយោ អារម្មណាធិបតិ បឋមជ្ឈានបច្ចវេក្ខណំ គរុំ កត្វា បច្ចវេក្ខតិ អនាគតំសញ្ញាណបច្ចវេក្ខណំ គរុំ កត្វា ... មហគ្គតារម្មណេ បរិត្តេ ខន្ធេ គរុំ កត្វា អស្សាទេតិ តំ គរុំ កត្វា បរិត្តារម្មណោ រាគោ ... ទិដ្ឋិ ឧប្បជ្ជតិ ។

(៤១) អប្បមាណារម្មណោ ធម្មោ អប្បមាណារម្មណស្ស ធម្មស្ស អធិបតិបច្ចយេន បច្ចយោ អារម្មណាធិបតិ សហជាតាធិបតិ ។ អារម្មណាធិបតិ អរិយា មគ្គា វុដ្ឋហិត្វា មគ្គំ គរុំ កត្វា បច្ចវេក្ខន្តិ ផលំ គរុំ កត្វា ... ។
សហជាតាធិបតិ អប្បមាណារម្មណាធិបតិ សម្បយុត្តកានំ ខន្ធានំ ។

(៤២) អប្បមាណារម្មណោ ធម្មោ បរិត្តារម្មណស្ស ធម្មស្ស ... អារម្មណាធិបតិ សេក្ខា គោត្រភុំ គរុំ កត្វា បច្ចវេក្ខន្តិ វោទានំ គរុំ កត្វា បច្ចវេក្ខន្តិ មគ្គបច្ចវេក្ខណំ

(៤០) ធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍តូចឆ្មារ ដោយអធិបតិបច្ច័យ បានដល់អារម្មណាធិបតិ គឺ បុគ្គល ធ្វើនូវបឋមជ្ឈានបច្ចវេក្ខណៈ ឲ្យជាទីគោរព ហើយពិចារណា ធ្វើនូវអនាគតំសញ្ញាណបច្ចវេក្ខណៈ ឲ្យជាទីគោរព ... ធ្វើនូវខន្ធទាំងឡាយ តូចឆ្មារ ដែលមានអារម្មណ៍ដល់នូវសភាពធំ ឲ្យជាទីគោរព ហើយត្រេកអរ រាគៈ មានអារម្មណ៍តូចឆ្មារ ធ្វើនូវពួកខន្ធៈនោះឲ្យជាទីគោរព ... ទិដ្ឋិ កើតឡើង ។

(៤១) ធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន ដោយអធិបតិបច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺ ព្រះអរិយៈទាំងឡាយ ចេញអំពីមគ្គ ធ្វើនូវមគ្គ ឲ្យជាទីគោរព ហើយពិចារណា ធ្វើនូវផល ឲ្យជាទីគោរព ... ។ ឯសហជាតាធិបតិ គឺ អធិបតិធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន (ជាបច្ច័យ) នៃពួកសម្បយុត្តកក្ខន្ធ ។

(៤២) ធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន (ជាបច្ច័យ) នៃធម៌ ដែលមានអារម្មណ៍តូចឆ្មារ ... បានដល់អារម្មណាធិបតិ គឺ សេក្ខបុគ្គលទាំងឡាយ ធ្វើនូវគោត្រភូ ឲ្យជាទីគោរព ហើយពិចារណា ធ្វើនូវវោទានៈ ឲ្យជាទីគោរព ហើយពិចារណា ធ្វើនូវមគ្គបច្ចវេក្ខណៈ

គរុំ កត្វា បច្ចវេក្ខតិ ផលស្ស បច្ចវេក្ខណំ ... និព្វានប្បច្ចវេក្ខណំ គរុំ កត្វា បច្ចវេក្ខតិ ។

(៤៣) អប្បមាណារម្មណោ ធម្មោ មហគ្គតារម្មណស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ ។ អារម្មណាធិបតិ សេក្ខា អប្បមាណារម្មណំ ចេតោបរិយញ្ញាណំ គរុំ កត្វា ... បុព្វេនិវាសានុស្សតិញ្ញាណំ ... អនាគតំសញ្ញាណំ គរុំ កត្វា បច្ចវេក្ខន្តិ ។

(៤៤) បរិត្តារម្មណោ ធម្មោ បរិត្តារម្មណស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ ។ បុរិមា បុរិមា បរិត្តារម្មណា ខន្ធា បច្ឆិមានំ បច្ឆិមានំ ខន្ធានំ អនន្តរប្បច្ចយេន បច្ចយោ ។

(៤៥) បរិត្តារម្មណោ ធម្មោ មហគ្គតារម្មណស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ ។ បរិត្តារម្មណំ ចុតិចិត្តំ មហគ្គតារម្មណស្ស ឧបបត្តិចិត្តស្ស អនន្តរប្បច្ចយេន បច្ចយោ ។ បរិត្តារម្មណំ ភវង្គំ មហគ្គតារម្មណាយ អាវជ្ជនាយ អនន្តរប្បច្ចយេន បច្ចយោ ។ បរិត្តារម្មណា ខន្ធា មហគ្គតារម្មណស្ស វុដ្ឋានស្ស អនន្តរប្បច្ចយេន បច្ចយោ ។

ឲ្យជាទីគោរព ហើយពិចារណា ផលប្បច្ចវេក្ខណៈ ... ធ្វើនូវនិព្វានប្បច្ចវេក្ខណៈ ឲ្យជាទីគោរព ហើយពិចារណា ។

(៤៣) ធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ គឺសេក្ខបុគ្គលទាំងឡាយ ធ្វើនូវចេតោបរិយញ្ញាណ ដែលមានអារម្មណ៍ប្រមាណមិនបាន ឲ្យជាទីគោរព .. នូវបុព្វេនិវាសានុស្សតិញ្ញាណ ... ធ្វើនូវអនាគតំសញ្ញាណ ឲ្យជាទីគោរព ហើយពិចារណា ។

(៤៤) ធម៌ ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍តូចឆ្មារ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុន ៗ ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃពួកខន្ធក្រោយ ៗ ដោយអនន្តរប្បច្ច័យ ។

(៤៥) ធម៌ ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ដោយអនន្តរប្បច្ច័យ គឺ ចុតិចិត្ត ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃឧបបត្តិចិត្ត ដែលមានអារម្មណ៍ដល់នូវសភាពធំ ដោយអនន្តរប្បច្ច័យ ភវង្គៈ ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃអាវជ្ជនា ដែលមានអារម្មណ៍ដល់នូវសភាពធំ ដោយអនន្តរប្បច្ច័យ ពួកខន្ធ ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃវុដ្ឋានៈ ដែលមានអារម្មណ៍ដល់នូវសភាពធំ ដោយអនន្តរប្បច្ច័យ ។

(៤៦) បរិត្តារម្មណោ ធម្មោ អប្បមាណារម្មណស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ។ បរិត្តារម្មណំ អនុលោមំ គោត្រភុស្ស អនុលោមំ វោទានស្ស អនុលោមំ ផលសមាបត្តិយា អនន្តរប្បច្ចយេន បច្ចយោ ។

(៤៧) មហគ្គតារម្មណោ ធម្មោ មហគ្គតារម្មណស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ។ បុរិមា បុរិមា មហគ្គតារម្មណា ខន្ធា បច្ឆិមានំ បច្ឆិមានំ ខន្ធានំ អនន្តរប្បច្ចយេន បច្ចយោ ។

(៤៨) មហគ្គតារម្មណោ ធម្មោ បរិត្តារម្មណស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ។ មហគ្គតារម្មណំ ចុតិចិត្តំ បរិត្តារម្មណស្ស ឧបបត្តិចិត្តស្ស អនន្តរប្បច្ចយេន បច្ចយោ។ មហគ្គតារម្មណំ ភវង្គំ បរិត្តារម្មណាយ អាវជ្ជនាយ អនន្តរប្បច្ចយេន បច្ចយោ។ មហគ្គតារម្មណា ខន្ធា បរិត្តារម្មណស្ស វុដ្ឋានស្ស អនន្តរប្បច្ចយេន បច្ចយោ ។

(៤៩) មហគ្គតារម្មណោ ធម្មោ អប្បមាណារម្មណស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ។ មហគ្គតារម្មណំ អនុលោមំ គោត្រភុស្ស អនុលោមំ

(៤៦) ធម៌ ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន ដោយអនន្តរប្បច្ច័យ គឺ អនុលោម ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃគោត្រភូ អនុលោម (ជាបច្ច័យ) នៃវោទានៈ អនុលោម ជាបច្ច័យ នៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។

(៤៧) ធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ដោយអនន្តរប្បច្ច័យ គឺ ពួកខន្ធ មុនៗ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃពួកខន្ធ ក្រោយៗ ដោយអនន្តរប្បច្ច័យ ។

(៤៨) ធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍តូចឆ្មារ ដោយអនន្តរប្បច្ច័យ គឺ ចុតិចិត្ត ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃឧបបត្តិចិត្ត ដែលមានអារម្មណ៍តូចឆ្មារ ដោយអនន្តរប្បច្ច័យ ភវង្គៈ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃអាវជ្ជនា ដែលមានអារម្មណ៍តូចឆ្មារ ដោយអនន្តរប្បច្ច័យ ពួកខន្ធ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃវុដ្ឋានៈ ដែលមានអារម្មណ៍តូចឆ្មារ ដោយអនន្តរប្បច្ច័យ ។

(៤៩) ធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន ដោយអនន្តរប្បច្ច័យ គឺ អនុលោម ដែលមានអារម្មណ៍ដល់នូវសភាពធំ (ជាបច្ច័យ) នៃគោត្រភូ អនុលោម

វោទានស្ស អនុលោមំ ផលសមាបត្តិយា និរោធា វុដ្ឋហន្តស្ស នេវសញ្ញានាសញ្ញាយតនំ ផលសមាបត្តិយា អនន្តរប្បច្ចយេន បច្ចយោ ។

(៥០) អប្បមាណារម្មណោ ធម្មោ អប្បមាណារម្មណស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ ។ បុរិមា បុរិមា អប្បមាណារម្មណា ខន្ធា បច្ឆិមានំ បច្ឆិមានំ ខន្ធានំ អនន្តរប្បច្ចយេន បច្ចយោ ។ គោត្រភុ មគ្គស្ស វោទានំ មគ្គស្ស មគ្គោ ផលស្ស ផលំ ផលស្ស អនន្តរប្បច្ចយេន បច្ចយោ ។

(៥១) អប្បមាណារម្មណោ ធម្មោ បរិត្តារម្មណស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ ។ មគ្គប្បច្ចវេក្ខណា បរិត្តារម្មណស្ស វុដ្ឋានស្ស ផលប្បច្ចវេក្ខណា បរិត្តារម្មណស្ស វុដ្ឋានស្ស និព្វានប្បច្ចវេក្ខណា បរិត្តារម្មណស្ស វុដ្ឋានស្ស អប្បមាណារម្មណំ ចេតោបរិយញ្ញាណំ បរិត្តារម្មណស្ស វុដ្ឋានស្ស បុព្វេនិវាសានុស្សតិញ្ញាណំ បរិត្តារម្មណស្ស វុដ្ឋានស្ស អនាគតំសញ្ញាណំ បរិត្តារម្មណស្ស វុដ្ឋានស្ស ផលំ បរិត្តារម្មណស្ស វុដ្ឋានស្ស អនន្តរប្បច្ចយេន បច្ចយោ ។

(ជាបច្ច័យ) នៃវោទានៈ អនុលោម (ជាបច្ច័យ) នៃផលសមាបត្តិ នេវសញ្ញានាសញ្ញាយតនៈ របស់បុគ្គលកាលចេញអំពីនិរោធ ជាបច្ច័យ នៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។

(៥០) ធម៌ ដែលមានអារម្មណ៍មានប្រមាណមិនបាន ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍មានប្រមាណមិនបាន ដោយអនន្តរប្បច្ច័យ គឺ ពួកខន្ធ មុនៗ ដែលមានអារម្មណ៍មានប្រមាណមិនបាន ជាបច្ច័យ នៃពួកខន្ធ ក្រោយៗ ដោយអនន្តរប្បច្ច័យ គោត្រភូ (ជាបច្ច័យ) នៃមគ្គ វោទានៈ (ជាបច្ច័យ) នៃមគ្គ មគ្គ (ជាបច្ច័យ) នៃផល ផល ជាបច្ច័យ នៃផល ដោយអនន្តរប្បច្ច័យ ។

(៥១) ធម៌ ដែលមានអារម្មណ៍មានប្រមាណមិនបាន ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍តូចឆ្មារ ដោយអនន្តរប្បច្ច័យ គឺ ការពិចារណានូវមគ្គ (ជាបច្ច័យ) នៃវុដ្ឋានៈ ដែលមានអារម្មណ៍តូចឆ្មារ ការពិចារណានូវផល (ជាបច្ច័យ) នៃវុដ្ឋានៈ ដែលមានអារម្មណ៍តូចឆ្មារ ការពិចារណានូវព្រះនិព្វាន (ជាបច្ច័យ) នៃវុដ្ឋានៈ ដែលមានអារម្មណ៍តូចឆ្មារ ចេតោបរិយញ្ញាណ ដែលមានអារម្មណ៍មានប្រមាណមិនបាន (ជាបច្ច័យ) នៃវុដ្ឋានៈ ដែលមានអារម្មណ៍តូចឆ្មារ បុព្វេនិវាសានុស្សតិញ្ញាណ (ជាបច្ច័យ) នៃវុដ្ឋានៈ ដែលមានអារម្មណ៍តូចឆ្មារ អនាគតំសញ្ញាណ (ជាបច្ច័យ) នៃវុដ្ឋានៈ ដែលមានអារម្មណ៍តូចឆ្មារ ផល ជាបច្ច័យ នៃវុដ្ឋានៈ ដែលមានអារម្មណ៍តូចឆ្មារ ដោយអនន្តរប្បច្ច័យ ។

(៤២) អប្បមាណារម្មណោ ធម្មោ មហគ្គតារម្មណស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ មគ្គប្បច្ចវេក្ខណា មហគ្គតារម្មណស្ស វុដ្ឋានស្ស ផលប្បច្ចវេក្ខណា មហគ្គតារម្មណស្ស ... និព្វានប្បច្ចវេក្ខណា មហគ្គតារម្មណស្ស ... ផលំ មហគ្គតារម្មណស្ស វុដ្ឋានស្ស អនន្តរប្បច្ចយេន បច្ចយោ ។

(៤៣) បរិត្តារម្មណោ ធម្មោ បរិត្តារម្មណស្ស ធម្មស្ស សមនន្តរប្បច្ចយេន បច្ចយោ អនន្តរសទិសំ ។

(៤៤) បរិត្តារម្មណោ ធម្មោ បរិត្តារម្មណស្ស ធម្មស្ស សហជាតប្បច្ចយេន បច្ចយោ អញ្ញមញ្ញប្បច្ចយេន បច្ចយោ និស្សយប្បច្ចយេន បច្ចយោ តីណិ បដិច្ចសទិសា កាតព្វា ។ ឧបនិស្សយប្បច្ចយេន អារម្មណូបនិស្សយោ អនន្តរូបនិស្សយោ បកតូបនិស្សយោ ។ បកតូបនិស្សយោ បរិត្តារម្មណំ សទ្ធំ ឧបនិស្សាយ ទានំ ទេតិ សីលំ ... ឧបោសថកម្មំ ... បរិត្តារម្មណំ ឈានំ ឧប្បាទេតិ វិបស្សនំ ... អភិញ្ញំ ... សមាបត្តិំ ឧប្បាទេតិ មានំ ជប្បេតិ ទិដ្ឋិំ គណ្ហាតិ បរិត្តារម្មណំ សីលំ ... បញ្ញំ

(៤២) ធម៌ ដែលមានអារម្មណ៍មានប្រមាណមិនបាន ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ដោយអនន្តរប្បច្ច័យ គឺ ការពិចារណា នូវមគ្គ (ជាបច្ច័យ) នៃវុដ្ឋានៈ ដែលមានអារម្មណ៍ដល់នូវសភាពធំ ការពិចារណានូវផល មានអារម្មណ៍ ដល់នូវសភាពធំ ... ការពិចារណា នូវព្រះនិព្វាន ដែលមានអារម្មណ៍ ដល់នូវសភាពធំ ... ផល ជាបច្ច័យ នៃវុដ្ឋានៈ ដែលមានអារម្មណ៍ ដល់នូវសភាពធំ ដោយអនន្តរប្បច្ច័យ ។

(៤៣) ធម៌ ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍តូចឆ្មារ ដោយសមនន្តរប្បច្ច័យ គឺ ប្រហែលគ្នានឹងអនន្តរប្បច្ច័យដែរ ។

(៤៤) ធម៌ ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍តូចឆ្មារ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយអញ្ញមញ្ញប្បច្ច័យ ជាបច្ច័យ ដោយនិស្សយប្បច្ច័យ គឺ ការៈ ទាំងបី បណ្ឌិត គប្បីធ្វើឲ្យប្រហែលគ្នា នឹងបដិច្ចវារៈផងចុះ ។ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ ឯបកតូបនិស្ស័យ គឺ បុគ្គល អាស្រ័យសទ្ធា ដែលមានអារម្មណ៍ តូចឆ្មារ ហើយឲ្យទាន សីល ... ធ្វើឧបោសថកម្ម ... ញុំាងឈាន ដែលមានអារម្មណ៍តូចឆ្មារ ឲ្យកើតឡើង វិបស្សនា ... អភិញ្ញា ... ញុំាងសមាបត្តិឲ្យកើតឡើង តម្កើងមានះ ប្រកាន់ទិដ្ឋិ សីល ដែលមានអារម្មណ៍តូចឆ្មារ ... បញ្ញា

រាគំ ទោសំ មោហំ មានំ ទិដ្ឋឹ បត្ថនំ កាយិកំ សុខំ ... កាយិកំ ទុក្ខំ ឧបនិស្សាយ ទានំ ទេតិ សីលំ ... ឧបោសថកម្មំ ... បរិត្តារម្មណំ ឈានំ ឧប្បាទេតិ វិបស្សនំ ... អភិញ្ញំ ... សមាបត្តឹ ឧប្បាទេតិ បាណំ ហនតិ សង្ឃំ ភិន្ទតិ បរិត្តារម្មណា សទ្ធា ... បញ្ញា រាគោ បត្ថនា កាយិកំ សុខំ ... កាយិកំ ទុក្ខំ បរិត្តារម្មណាយ សទ្ធាយ បញ្ញាយ រាគស្ស បត្ថនាយ កាយិកស្ស សុខស្ស កាយិកស្ស ទុក្ខស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ ។

(៥៥) បរិត្តារម្មណោ ធម្មោ មហគ្គតារម្មណស្ស ធម្មស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ អារម្មណូបនិស្សយោ អនន្តរូបនិស្សយោ បកតូបនិស្សយោ ។ បកតូបនិស្សយោ បរិត្តារម្មណំ សទ្ធំ ឧបនិស្សាយ មហគ្គតារម្មណំ ឈានំ ឧប្បាទេតិ វិបស្សនំ ... អភិញ្ញំ ... សមាបត្តឹ ឧប្បាទេតិ មានំ ជប្បេតិ ទិដ្ឋឹ គណ្ហាតិ បរិត្តារម្មណំ សីលំ ... បញ្ញំ រាគំ បត្ថនំ កាយិកំ សុខំ ... កាយិកំ ទុក្ខំ ឧបនិស្សាយ មហគ្គតារម្មណំ ឈានំ ឧប្បាទេតិ វិបស្សនំ ... អភិញ្ញំ ... សមាបត្តឹ ឧប្បាទេតិ មានំ ជប្បេតិ ទិដ្ឋឹ គណ្ហាតិ

រាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ សេចក្តីប្រាថ្នា កាយិកសុខ ... អាស្រ័យកាយិកទុក្ខ ហើយឲ្យទាន សីល ... ឧបោសថ-កម្ម ... ញុំាងឈាន ដែលមានអារម្មណ៍តូចឆ្មារ ឲ្យកើតឡើង វិបស្សនា ... អភិញ្ញា ... ញុំាងសមាបត្តិឲ្យកើតឡើង សម្លាប់សត្វ បំបែកសង្ឃ សទ្ធា ដែលមានអារម្មណ៍តូចឆ្មារ ... បញ្ញា រាគៈ សេចក្តីប្រាថ្នា កាយិកសុខ ... កាយិកទុក្ខ ជាបច្ច័យ នៃសទ្ធា ដែលមានអារម្មណ៍តូចឆ្មារ បញ្ញា រាគៈ សេចក្តីប្រាថ្នា កាយិកសុខ និងកាយិកទុក្ខ ដោយឧបនិស្សយប្បច្ច័យ ។

(៥៥) ធម៌ ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ ឯបកតូបនិស្ស័យ គឺ បុគ្គល អាស្រ័យ នូវសទ្ធា ដែលមានអារម្មណ៍តូចឆ្មារ ហើយញុំាងឈាន ដែលមានអារម្មណ៍ដល់នូវសភាពធំ ឲ្យកើតឡើង វិបស្សនា ... អភិញ្ញា ... ញុំាងសមាបត្តិឲ្យកើតឡើង តម្កើងមានះ ប្រកាន់ ទិដ្ឋិ សីល ដែលមានអារម្មណ៍តូចឆ្មារ ... បញ្ញា រាគៈ សេចក្តីប្រាថ្នា កាយិកសុខ ... អាស្រ័យនូវកាយិកទុក្ខ ញុំាងឈាន ដែលមានអារម្មណ៍ដល់នូវសភាពធំ ឲ្យកើតឡើង វិបស្សនា ... អភិញ្ញា ... ញុំាងសមាបត្តិឲ្យកើតឡើង តម្កើងមានះ ប្រកាន់ទិដ្ឋិ

បរិត្តារម្មណា សទ្ធា ... កាយិកំ សុខំ ... កាយិកំ ទុក្ខំ មហគ្គតារម្មណាយ សទ្ធាយ បញ្ញាយ រាគស្ស បត្ថនាយ ឧបនិស្សយបច្ចយេន បច្ចយោ ។

(៨៦) បរិត្តារម្មណោ ធម្មោ អប្បមាណារម្មណស្ស ធម្មស្ស ឧបនិស្សយបច្ចយេន បច្ចយោ អនន្តរូប-និស្សយោ បកតូបនិស្សយោ ។ បកតូបនិស្សយោ បរិត្តារម្មណំ សទ្ធំ ឧបនិស្សាយ អប្បមាណារម្មណំ ឈានំ ឧប្បាទេតិ មគ្គំ ... អភិញ្ញំ ... សមាបត្តឹ ឧប្បាទេតិ បរិត្តារម្មណំ សីលំ ... បញ្ញំ រាគំ កាយិកំ សុខំ ... កាយិកំ ទុក្ខំ ឧបនិស្សាយ អប្បមាណារម្មណំ ឈានំ ឧប្បាទេតិ មគ្គំ ... អភិញ្ញំ ... សមាបត្តឹ ឧប្បាទេតិ បរិត្តារម្មណា សទ្ធា ... កាយិកំ សុខំ អប្បមាណារម្មណាយ សទ្ធាយ បញ្ញាយ ឧបនិស្សយបច្ចយេន បច្ចយោ ។

(៨៧) មហគ្គតារម្មណោ ធម្មោ មហគ្គតារម្មណស្ស ធម្មស្ស ឧបនិស្សយបច្ចយេន បច្ចយោ អារម្មណូ-បនិស្សយោ អនន្តរូបនិស្សយោ បកតូបនិស្សយោ ។

សទ្ធា ដែលមានអារម្មណ៍តូចឆ្មារ ... កាយិកសុខ ... កាយិកទុក្ខ ជាបច្ច័យ នៃសទ្ធា ដែលមានអារម្មណ៍ដល់នូវសភាពធំ បញ្ញា រាគៈ សេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។

(៨៦) ធម៌ ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍មានប្រមាណមិនបាន ដោយឧបនិស្សយប្បច្ច័យ បានដល់អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺ បុគ្គលអាស្រ័យ នូវសទ្ធា ដែលមានអារម្មណ៍តូចឆ្មារ ហើយញ៉ាំងឈាន ដែលមានអារម្មណ៍មានប្រមាណមិនបាន ឲ្យកើតឡើង ញ៉ាំងមគ្គ ... ញ៉ាំងអភិញ្ញា ... ញ៉ាំងសមាបត្តិ ឲ្យកើតឡើង សីល ដែលមានអារម្មណ៍តូចឆ្មារ ... បញ្ញា រាគៈ កាយិកសុខ ... អាស្រ័យ កាយិកទុក្ខ ហើយញ៉ាំងឈាន ដែលមានអារម្មណ៍មានប្រមាណមិនបាន ឲ្យកើតឡើង ញ៉ាំងមគ្គ ... ញ៉ាំងអភិញ្ញា ... ញ៉ាំងសមាបត្តិ ឲ្យកើតឡើង សទ្ធា ដែលមានអារម្មណ៍តូចឆ្មារ ... កាយិកសុខ ជាបច្ច័យ នៃសទ្ធា ដែលមានអារម្មណ៍មានប្រមាណមិនបាន និងបញ្ញា ដោយឧបនិស្សយប្បច្ច័យ ។

(៨៧) ធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។

បកតូបនិស្សយោ មហគ្គតារម្មណំ សទ្ធំ ឧបនិស្សាយ មហគ្គតារម្មណំ ឈានំ ឧប្បាទេតិ វិបស្សនំ ... អភិញ្ញំ ... សមាបត្តឹ ... មានំ ... ទិដ្ឋឹ គណ្ហាតិ មហគ្គតារម្មណំ សីលំ ... បញ្ញំ ... រាគំ ... បត្ថនំ ឧបនិស្សាយ ... មហគ្គតារម្មណំ ឈានំ ... ទិដ្ឋឹ គណ្ហាតិ មហគ្គតារម្មណា សទ្ធា ... បញ្ញា ... រាគោ ... បត្ថនា មហគ្គតារម្មណាយ សទ្ធាយ ... បត្ថនាយ ឧបនិស្សយប្បច្ចយេន បច្ចយោ ។

(៤៨) មហគ្គតារម្មណោ ធម្មោ បរិត្តារម្មណស្ស ធម្មស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ អារម្មណូបនិស្សយោ អនន្តរូបនិស្សយោ បកតូបនិស្សយោ ។ បកតូបនិស្សយោ មហគ្គតារម្មណំ សទ្ធំ ឧបនិស្សាយ ទានំ ទេតិ សីលំ សមាទិយតិ ឧបោសថកម្មំ ករោតិ បរិត្តារម្មណំ ឈានំ ... វិបស្សនំ ... អភិញ្ញំ ... សមាបត្តឹ ... មានំ ជប្បេតិ ទិដ្ឋឹ គណ្ហាតិ មហគ្គតារម្មណំ សីលំ ... បត្ថនំ ឧបនិស្សាយ ទានំ ទេតិ ... ទិដ្ឋឹ គណ្ហាតិ

បកតូបនិស្ស័យ គឺ បុគ្គល អាស្រ័យ នូវសទ្ធា ដែលមានអារម្មណ៍ដល់នូវសភាពធំ ហើយញុំាងឈាន ដែលមានអារម្មណ៍ដល់នូវសភាពធំ ឲ្យកើតឡើង ញុំាងវិបស្សនា ... ញុំាងអភិញ្ញា ... ញុំាងសមាបត្តិ ... នូវមានះ ... ប្រកាន់ទិដ្ឋិ នូវសីល ដែលមានអារម្មណ៍ដល់នូវសភាពធំ ... នូវបញ្ញា ... នូវរាគៈ .. អាស្រ័យ នូវសេចក្តីប្រាថ្នា ... នូវឈាន ដែលមានអារម្មណ៍ដល់នូវសភាពធំ ... ប្រកាន់ទិដ្ឋិ សទ្ធា ដែលមានអារម្មណ៍ដល់នូវសភាពធំ ... បញ្ញា ... រាគៈ ... សេចក្តីប្រាថ្នា ជាបច្ច័យ នៃសទ្ធា ដែលមានអារម្មណ៍ដល់នូវសភាពធំ និងសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។

(៤៨) ធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍តូចឆ្មារ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺ បុគ្គល អាស្រ័យ នូវសទ្ធា ដែលមានអារម្មណ៍ដល់នូវសភាពធំ ហើយឲ្យទាន សមាទានសីល ធ្វើនូវឧបោសថកម្ម ញុំាងឈាន ដែលមានអារម្មណ៍តូចឆ្មារ ... ញុំាងវិបស្សនា ... ញុំាងអភិញ្ញា ... ញុំាងសមាបត្តិ ... តម្កើងមានះ ប្រកាន់ទិដ្ឋិ នូវសីល ដែលមានអារម្មណ៍ដល់នូវសភាពធំ ... អាស្រ័យ នូវសេចក្តីប្រាថ្នា ហើយឲ្យទាន .. ប្រកាន់ទិដ្ឋិ

មហគ្គតារម្មណា សទ្ធា . . បញ្ញា បរិត្តារម្មណាយ សទ្ធាយ បញ្ញាយ កាយិកស្ស សុខស្ស កាយិកស្ស ទុក្ខស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ ។

(៥៩) មហគ្គតារម្មណោ ធម្មោ អប្បមាណារម្មណស្ស ធម្មស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ អនន្តរូបនិស្សយោ បកតូបនិស្សយោ ។ បកតូបនិស្សយោ មហគ្គតារម្មណំ សទ្ធំ ឧបនិស្សាយ អប្បមាណារម្មណំ ឈានំ ... មគ្គំ ... អភិញ្ញំ ... សមាបត្តឹ ឧប្បាទេតិ មហគ្គតារម្មណំ សីលំ ... បញ្ញំ ឧបនិស្សាយ អប្បមាណារម្មណំ ឈានំ ... សមាបត្តឹ ឧប្បាទេតិ មហគ្គតារម្មណា សទ្ធា ... បញ្ញា អប្បមាណារម្មណាយ សទ្ធាយ បញ្ញាយ ឧបនិស្សយប្បច្ចយេន បច្ចយោ ។

(៦០) អប្បមាណារម្មណោ ធម្មោ អប្បមាណារម្មណស្ស ធម្មស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ អារម្មណូបនិស្សយោ អនន្តរូបនិស្សយោ បកតូបនិស្សយោ ។ បកតូបនិស្សយោ អប្បមាណារម្មណំ សទ្ធំ ឧបនិស្សាយ អប្បមាណារម្មណំ ឈានំ ... មគ្គំ ...

សទ្ធា ដែលមានអារម្មណ៍ដល់នូវសភាពធំ ... សេចក្ដីប្រាជ្ញា ជាបច្ច័យ នៃសទ្ធា ដែលមានអារម្មណ៍តូចឆ្មារ នៃសេចក្ដីប្រាជ្ញា កាយិកសុខ និងកាយិកទុក្ខ ដោយឧបនិស្សយប្បច្ច័យ ។

(៥៩) ធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍មានប្រមាណមិនបាន ដោយឧបនិស្សយប្បច្ច័យ បានដល់អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គល អាស្រ័យ នូវសទ្ធា ដែលមានអារម្មណ៍ដល់នូវសភាពធំ ហើយញុំាងឈាន ដែលមានអារម្មណ៍មានប្រមាណមិនបាន ... ញុំាងមគ្គ ... ញុំាងអភិញ្ញា ... ញុំាងសមាបត្តិ ឲ្យកើតឡើង នូវសីល ដែលមានអារម្មណ៍ដល់នូវសភាពធំ ... អាស្រ័យ នូវសេចក្ដីប្រាជ្ញា ហើយញុំាងឈាន ដែលមានអារម្មណ៍មានប្រមាណមិនបាន ... ញុំាងសមាបត្តិ ឲ្យកើតឡើង សទ្ធា ដែលមានអារម្មណ៍ដល់នូវសភាពធំ ... សេចក្ដីប្រាជ្ញា ជាបច្ច័យ នៃសទ្ធា ដែលមានអារម្មណ៍មានប្រមាណមិនបាន និងបញ្ញា ដោយឧបនិស្សយប្បច្ច័យ ។

(៦០) ធម៌ ដែលមានអារម្មណ៍មានប្រមាណមិនបាន ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍មានប្រមាណមិនបាន ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គល អាស្រ័យ នូវសទ្ធា ដែលមានអារម្មណ៍មានប្រមាណមិនបាន ហើយញុំាងឈាន ដែលមានអារម្មណ៍មានប្រមាណមិនបាន ... ញុំាងមគ្គ ...

អភិញ្ញំ ... សមាបត្តឹ ឧប្បាទេតិ អប្បមាណារម្មណំ សីលំ ... បញ្ញំ ឧបនិស្សាយ អប្បមាណារម្មណំ ឈានំ ... មគ្គំ ... សមាបត្តឹ ឧប្បាទេតិ អប្បមា-ណារម្មណា សទ្ធា ... បញ្ញា អប្បមាណារម្ម-ណាយ សទ្ធាយ បញ្ញាយ ផលសមាបត្តិយា ឧប-និស្សយប្បច្ចយេន បច្ចយោ ។

(៩១) អប្បមាណារម្មណោ ធម្មោ បរិត្តារម្ម-ណស្ស ធម្មស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ អា-រម្មណូបនិស្សយោ អនន្តរូបនិស្សយោ បកតូបនិស្ស-យោ ។ បកតូបនិស្សយោ អប្បមាណារម្មណំ សទ្ធំ ឧបនិស្សាយ ទានំ ទេតិ សីលំ សមាទិយតិ ឧបោ-សថកម្មំ ករោតិ បរិត្តារម្មណំ ឈានំ ឧប្បាទេតិ វិបស្សនំ ... អភិញ្ញំ ... សមាបត្តឹ ឧប្បាទេតិ អប្ប-មាណារម្មណំ សីលំ ... បញ្ញំ ឧបនិស្សាយ ទានំ ទេតិ ... សមាបត្តឹ ឧប្បាទេតិ អប្បមាណារម្មណា សទ្ធា ... បញ្ញា បរិត្តារម្មណាយ សទ្ធាយ បញ្ញាយ កាយិកស្ស សុខស្ស កាយិកស្ស ទុក្ខស្ស ឧប-និស្សយប្បច្ចយេន បច្ចយោ ។

ញ៉ាំងអភិញ្ញា ... ញ៉ាំងសមាបត្តិ ឲ្យកើតឡើង នូវសីល ដែលមានអារម្មណ៍មានប្រមាណមិនបាន ... អាស្រ័យ នូវបញ្ញា ហើយញ៉ាំងឈាន ដែលមានអារម្មណ៍មានប្រមាណមិនបាន ... ញ៉ាំងមគ្គ ... ញ៉ាំងសមាបត្តិ ឲ្យកើតឡើង សទ្ធា ដែលមានអារម្មណ៍មានប្រមាណមិនបាន ... បញ្ញា ជាបច្ច័យ នៃសទ្ធា ដែលមានអារម្មណ៍មានប្រ-មាណមិនបាន នៃបញ្ញា និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

(៩១) ធម៌ ដែលមានអារម្មណ៍មានប្រមាណមិនបាន ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍តូចឆ្មារ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូប-និស្ស័យ គឺ បុគ្គល អាស្រ័យ នូវសទ្ធា ដែលមានអារម្មណ៍មានប្រមាណមិនបាន ហើយឲ្យទាន សមាទានសីល ធ្វើនូវឧបោសថកម្ម ញ៉ាំងឈាន ដែលមានអារម្មណ៍តូចឆ្មារ ឲ្យកើតឡើង ញ៉ាំងវិបស្សនា ... ញ៉ាំងអភិញ្ញា ... ញ៉ាំងសមាបត្តិ ឲ្យកើតឡើង នូវសីល ដែលមានអារម្មណ៍មានប្រមាណមិនបាន ... អាស្រ័យ នូវបញ្ញា ហើយឲ្យទាន ... ញ៉ាំងសមាបត្តិ ឲ្យកើតឡើង សទ្ធា ដែលមានអារម្មណ៍មានប្រមាណមិនបាន ... បញ្ញា ជាបច្ច័យ នៃសទ្ធា ដែលមានអារម្មណ៍តូចឆ្មារ នៃបញ្ញា កាយិកសុខ និងកាយិកទុក្ខ ដោយឧបនិស្សយប្បច្ច័យ ។

(៦៦) អប្បមាណារម្មណោ ធម្មោ មហគ្គតារម្មណស្ស ធម្មស្ស ឧបនិស្សយបច្ចយេន បច្ចយោ, អារម្មណូបនិស្សយោ អនន្តរូបនិស្សយោ បកតូបនិស្សយោ ។ បកតូបនិស្សយោ អប្បមាណារម្មណំ សទ្ធំ ឧបនិស្សាយ មហគ្គតារម្មណំ ឈានំ ... វិបស្សនំ ... អភិញ្ញំ ... សមាបត្តិំ ឧប្បាទេតិ អប្បមាណារម្មណំ សីលំ ... បញ្ញំ ឧបនិស្សាយ មហគ្គតារម្មណំ ឈានំ ... វិបស្សនំ ... អភិញ្ញំ ... សមាបត្តិំ ឧប្បាទេតិ អប្បមាណារម្មណា សទ្ធា ... បញ្ញា មហគ្គតារម្មណាយ សទ្ធាយ បញ្ញាយ ឧបនិស្សយបច្ចយេន បច្ចយោ ។

(៦៧) បរិត្តារម្មណោ ធម្មោ បរិត្តារម្មណស្ស ធម្មស្ស អាសេវនបច្ចយេន បច្ចយោ បុរិមា បុរិមា បរិត្តារម្មណា ខន្ធា បច្ឆិមានំ បច្ឆិមានំ បរិត្តារម្មណានំ ខន្ធានំ អាសេវនបច្ចយេន បច្ចយោ ។

(៦៨) បរិត្តារម្មណោ ធម្មោ អប្បមាណារម្មណស្ស ធម្មស្ស អាសេវនបច្ចយេន បច្ចយោ បរិត្តារម្មណំ អនុលោមំ គោត្រភុស្ស អនុលោមំ វោទានស្ស អាសេវនបច្ចយេន បច្ចយោ ។

(៦៦) ធម៌ ដែលមានអារម្មណ៍មានប្រមាណមិនបាន ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺ បុគ្គល អាស្រ័យ នូវសទ្ធា ដែលមានអារម្មណ៍មានប្រមាណមិនបាន ហើយញ៉ាំងឈាន ដែលមានអារម្មណ៍ដល់នូវសភាពធំ ... ញ៉ាំងវិបស្សនា ... ញ៉ាំងអភិញ្ញា ... ញ៉ាំងសមាបត្តិ ឲ្យកើតឡើង នូវសីល ដែលដែលមានអារម្មណ៍មានប្រមាណមិនបាន... អាស្រ័យ នូវបញ្ញា ហើយញ៉ាំងឈាន ដែលមានអារម្មណ៍ដល់នូវសភាពធំ... ញ៉ាំងវិបស្សនា ... ញ៉ាំងអភិញ្ញា ... ញ៉ាំងសមាបត្តិ ឲ្យកើតឡើង សទ្ធា ដែលមានអារម្មណ៍មានប្រមាណមិនបាន... បញ្ញា ជាបច្ច័យ នៃសទ្ធា ដែលមានអារម្មណ៍ដល់នូវសភាពធំ និងបញ្ញា ដោយឧបនិស្សយប្បច្ច័យ ។

(៦៧) ធម៌ ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍តូចឆ្មារ ដោយអាសេវនប្បច្ច័យ គឺ ពួកខន្ធ មុនៗ ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃពួកខន្ធ ក្រោយៗ ដែលមានអារម្មណ៍តូចឆ្មារ ដោយអាសេវនប្បច្ច័យ ។

(៦៨) ធម៌ ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍មានប្រមាណមិនបាន ដោយអាសេវនប្បច្ច័យ គឺ អនុលោម ដែលមានអារម្មណ៍តូចឆ្មារ (ជាបច្ច័យ) នៃគោត្រភូ អនុលោម ជាបច្ច័យ នៃវោទានៈ ដោយអាសេវនប្បច្ច័យ ។

(៦៥) មហគ្គតារម្មណោ ធម្មោ មហគ្គតារម្មណស្ស ធម្មស្ស អាសេវនប្បច្ចយេន បច្ចយោ បុរិមា បុរិមា មហគ្គតារម្មណា ខន្ធា បច្ឆិមានំ បច្ឆិមានំ មហគ្គតារម្មណានំ ខន្ធានំ អាសេវនប្បច្ចយេន បច្ចយោ ។

(៦៦) មហគ្គតារម្មណោ ធម្មោ អប្បមាណារម្មណស្ស ធម្មស្ស អាសេវនប្បច្ចយេន បច្ចយោ មហគ្គតារម្មណំ អនុលោមំ គោត្រភុស្ស អនុលោមំ វោទានស្ស អាសេវនប្បច្ចយេន បច្ចយោ ។

(៦៧) អប្បមាណារម្មណោ ធម្មោ អប្បមាណារម្មណស្ស ធម្មស្ស អាសេវនប្បច្ចយេន បច្ចយោ បុរិមា បុរិមា អប្បមាណារម្មណា ខន្ធា បច្ឆិមានំ បច្ឆិមានំ អប្បមាណារម្មណានំ ខន្ធានំ អាសេវនប្បច្ចយេន បច្ចយោ គោត្រភុ មគ្គស្ស វោទានំ មគ្គស្ស អាសេវនប្បច្ចយេន បច្ចយោ ។

(៦៨) បរិត្តារម្មណោ ធម្មោ បរិត្តារម្មណស្ស ធម្មស្ស កម្មប្បច្ចយេន បច្ចយោ សហជាតា នានាខណិកា ។ សហជាតា បរិត្តារម្មណា ចេតនា សម្បយុត្តកានំ ខន្ធានំ កម្មប្បច្ចយេន បច្ចយោ ។

(៦៥) ធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ដោយអាសេវនប្បច្ច័យ គឺ ពួកខន្ធមុនៗ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃពួកខន្ធក្រោយៗ ដែលមានអារម្មណ៍ដល់នូវសភាពធំ ដោយអាសេវនប្បច្ច័យ ។

(៦៦) ធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍មានប្រមាណមិនបាន ដោយអាសេវនប្បច្ច័យ គឺ អនុលោម ដែលមានអារម្មណ៍ដល់នូវសភាពធំ (ជាបច្ច័យ) នៃគោត្រភូ អនុលោម ជាបច្ច័យ នៃវោទានៈ ដោយអាសេវនប្បច្ច័យ ។

(៦៧) ធម៌ ដែលមានអារម្មណ៍មានប្រមាណមិនបាន ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍មានប្រមាណមិនបាន ដោយអាសេវនប្បច្ច័យ គឺ ពួកខន្ធមុនៗ ដែលមានអារម្មណ៍មានប្រមាណមិនបាន ជាបច្ច័យ នៃពួកខន្ធក្រោយៗ ដែលមានអារម្មណ៍មានប្រមាណមិនបាន ដោយអាសេវនប្បច្ច័យ គោត្រភូ (ជាបច្ច័យ) នៃមគ្គ វោទានៈ ជាបច្ច័យ នៃមគ្គ ដោយអាសេវនប្បច្ច័យ ។

(៦៨) ធម៌ ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍តូចឆ្មារ ដោយកម្មប្បច្ច័យ បានដល់សហជាត និងនានាខណិកៈ ។ សហជាត គឺ ចេតនា ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃពួកសម្បយុត្តកខន្ធ ដោយកម្មប្បច្ច័យ ។

នានាខណិកា បរិត្តារម្មណា ចេតនា វិបាកានំ បរិត្តារម្មណានំ ខន្ធានំ កម្មប្បច្ចយេន បច្ចយោ ។

(៦៩) មហគ្គតារម្មណោ ធម្មោ មហគ្គតារម្មណស្ស ធម្មស្ស កម្មប្បច្ចយេន បច្ចយោ សហជាតា នានាខណិកា ។ សហជាតា មហគ្គតារម្មណា ចេតនា សម្បយុត្តកានំ ខន្ធានំ កម្មប្បច្ចយេន បច្ចយោ ។ នានាខណិកា មហគ្គតារម្មណា ចេតនា វិបាកានំ មហគ្គតារម្មណានំ ខន្ធានំ កម្មប្បច្ចយេន បច្ចយោ ។

(៧០) មហគ្គតារម្មណោ ធម្មោ បរិត្តារម្មណស្ស ធម្មស្ស កម្មប្បច្ចយេន បច្ចយោ នានាខណិកា មហគ្គតារម្មណា ចេតនា វិបាកានំ បរិត្តារម្មណានំ ខន្ធានំ កម្មប្បច្ចយេន បច្ចយោ ។

(៧១) អប្បមាណារម្មណោ ធម្មោ អប្បមាណារម្មណស្ស ធម្មស្ស កម្មប្បច្ចយេន បច្ចយោ សហជាតា នានាខណិកា ។ សហជាតា អប្បមាណារម្មណា ចេតនា សម្បយុត្តកានំ ខន្ធានំ កម្មប្បច្ចយេន បច្ចយោ ។

ឯនានាខណិកៈ គឺ ចេតនា ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃពួកវិបាកក្ខន្ធ ដែលមានអារម្មណ៍តូចឆ្មារ ដោយកម្មប្បច្ច័យ ។

(៦៩) ធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ដោយកម្មប្បច្ច័យ បានដល់សហជាតៈ និងនានាខណិកៈ ។ សហជាតៈ គឺ ចេតនា ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺ ចេតនា ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃពួកវិបាកក្ខន្ធ ដែលមានអារម្មណ៍ដល់នូវសភាពធំ ដោយកម្មប្បច្ច័យ ។

(៧០) ធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍តូចឆ្មារ ដោយកម្មប្បច្ច័យ បានដល់នានាខណិកៈ គឺ ចេតនា ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃពួកវិបាកក្ខន្ធ ដែលមានអារម្មណ៍តូចឆ្មារ ដោយកម្មប្បច្ច័យ ។

(៧១) ធម៌ ដែលមានអារម្មណ៍ មានប្រមាណមិនបាន ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍ មានប្រមាណមិនបាន ដោយកម្មប្បច្ច័យ បានដល់សហជាតៈ និងនានាខណិកៈ ។ សហជាតៈ គឺ ចេតនា ដែលមានអារម្មណ៍មានប្រមាណមិនបាន ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។

នានាខណិកា អប្បមាណារម្មណា ចេតនា វិបាកានំ អប្បមាណារម្មណានំ ខន្ធានំ កម្មប្បច្ចយេន បច្ចយោ ។

(៦២) អប្បមាណារម្មណោ ធម្មោ បរិត្តារម្មណស្ស ធម្មស្ស កម្មប្បច្ចយេន បច្ចយោ នានាខណិកា អប្បមាណារម្មណា ចេតនា វិបាកានំ បរិត្តារម្មណានំ ខន្ធានំ កម្មប្បច្ចយេន បច្ចយោ ។

(៦៣) បរិត្តារម្មណោ ធម្មោ បរិត្តារម្មណស្ស ធម្មស្ស វិបាកប្បច្ចយេន បច្ចយោ អាហារប្បច្ចយេន បច្ចយោ ឥន្ទ្រិយប្បច្ចយេន បច្ចយោ ឈានប្បច្ចយេន បច្ចយោ មគ្គប្បច្ចយេន បច្ចយោ សម្បយុត្តប្បច្ចយេន បច្ចយោ អត្ថិប្បច្ចយេន បច្ចយោ នត្ថិប្បច្ចយេន បច្ចយោ វិគតប្បច្ចយេន បច្ចយោ អវិគតប្បច្ចយេន បច្ចយោ ។

(៦៤) ហេតុយា តីណិ អារម្មណេ សត្ត អធិបតិយា សត្ត អនន្តរេ ឆ សមនន្តរេ ឆ សហជាតេ តីណិ អញ្ញមញ្ញេ តីណិ និស្សយេ តីណិ ឧបនិស្សយេ ឆ អាសេវនេ បញ្ច កម្មេ បញ្ច វិបាកេ តីណិ

ឯនានាខណិកៈ គឺ ចេតនា ដែលមានអារម្មណ៍មានប្រមាណមិនបាន ជាបច្ច័យ នៃវិបាកក្ខន្ធ ដែលមានអារម្មណ៍មានប្រមាណមិនបាន ដោយកម្មប្បច្ច័យ ។

(៦២) ធម៌ ដែលមានអារម្មណ៍មានប្រមាណមិនបាន ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍តូចឆ្មារ ដោយកម្មប្បច្ច័យ បានដល់នានាខណិកៈ គឺ ចេតនា ដែលមានអារម្មណ៍មានប្រមាណមិនបាន ជាបច្ច័យ នៃវិបាកក្ខន្ធ ដែលមានអារម្មណ៍តូចឆ្មារ ដោយកម្មប្បច្ច័យ ។

(៦៣) ធម៌ ដែលមានអារម្មណ៍តូចឆ្មារ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍តូចឆ្មារ ដោយវិបាកប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ ជាបច្ច័យ ដោយឈានប្បច្ច័យ ជាបច្ច័យ ដោយមគ្គប្បច្ច័យ ជាបច្ច័យ ដោយសម្បយុត្តប្បច្ច័យ ជាបច្ច័យ ដោយអត្ថិប្បច្ច័យ ជាបច្ច័យ ដោយនត្ថិប្បច្ច័យ ជាបច្ច័យ ដោយវិគតប្បច្ច័យ ជាបច្ច័យ ដោយអវិគតប្បច្ច័យ ។

(៦៤) ក្នុងហេតុប្បច្ច័យ មានវារៈ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ៧ ក្នុងអធិបតិប្បច្ច័យ មានវារៈ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ៥ ក្នុងកម្មប្បច្ច័យ មានវារៈ៥ ក្នុងវិបាកប្បច្ច័យ មានវារៈ៣

អាហារេ តីណិ ឥន្ទ្រិយេ ឈានេ មគ្គេ សម្បយុត្តេ អត្ថិយា តីណិ នត្ថិយា ទ្វេ វិគតេ ទ្វេ អវិគតេ តីណិ ។ ឯវំ គណេតព្វំ ។

អនុលោមំ ។

(៧៥) បរិត្តារម្មណោ ធម្មោ បរិត្តារម្មណស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ សហជាតប្ប-ច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ កម្មប្បច្ចយេន បច្ចយោ ។

(៧៦) បរិត្តារម្មណោ ធម្មោ មហគ្គតារម្មណស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ឧបនិស្សយ-ប្បច្ចយេន បច្ចយោ ។

(៧៧) បរិត្តារម្មណោ ធម្មោ អប្បមាណារម្ម-ណស្ស ធម្មស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ ។

(៧៨) មហគ្គតារម្មណោ ធម្មោ មហគ្គតារម្ម-ណស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ សហជាតប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ ។

ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ និងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនត្ថិ-ប្បច្ច័យ មានវារៈ ២ ក្នុងវិគតប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិត គប្បីរាប់ យ៉ាងនេះចុះ ។

ចប់ អនុលោម ។

(៧៥) ធម៌ ដែលមានអារម្មណ៍តូចទាប ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍តូចទាប ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហ-ជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយកម្មប្បច្ច័យ ។

(៧៦) ធម៌ ដែលមានអារម្មណ៍តូចទាប ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ។

(៧៧) ធម៌ ដែលមានអារម្មណ៍តូចទាប ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍មានប្រមាណមិនបាន ដោយឧបនិស្សយប្បច្ច័យ ។

(៧៨) ធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ។

(៧៩) មហគ្គតារម្មណោ ធម្មោ បរិត្តារម្មណស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ កម្មប្បច្ចយេន បច្ចយោ ។

(៨០) មហគ្គតារម្មណោ ធម្មោ អប្បមាណារម្មណស្ស ធម្មស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ ។

(៨១) អប្បមាណារម្មណោ ធម្មោ អប្បមាណារម្មណស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ សហជាតប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ ។

(៨២) អប្បមាណារម្មណោ ធម្មោ បរិត្តារម្មណស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ កម្មប្បច្ចយេន បច្ចយោ ។

(៨៣) អប្បមាណារម្មណោ ធម្មោ មហគ្គតារម្មណស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ ។

(៨៤) ហេតុយា នវ អារម្មណេ នវ អធិបតិយា នវ អនន្តរេ នវ សមនន្តរេ នវ សហជាតេ នវ អញ្ញមញ្ញេ នវ

(៧៩) ធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍តូចទាប ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយកម្មប្បច្ច័យ ។

(៨០) ធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍មានប្រមាណមិនបាន ដោយឧបនិស្សយប្បច្ច័យ ។

(៨១) ធម៌ ដែលមានអារម្មណ៍មានប្រមាណមិនបាន ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍មានប្រមាណមិនបាន ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ។

(៨២) ធម៌ ដែលមានអារម្មណ៍មានប្រមាណមិនបាន ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍តូចទាប ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយកម្មប្បច្ច័យ ។

(៨៣) ធម៌ ដែលមានអារម្មណ៍មានប្រមាណមិនបាន ជាបច្ច័យ នៃធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ។

(៨៤) ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩

ននិស្សយេ នវ នឧបនិស្សយេ សត្ត នបុរេជាតេ នវ នបច្ឆាជាតេ នវ នអាសេវនេ នវ ។ សង្ខិត្តំ ។ នមគ្គេ នវ នសម្បយុត្តេ នវ នវិប្បយុត្តេ នវ នោអត្ថិយា នវ នោនត្ថិយា នវ នោវិគតេ នវ នោអវិគតេ នវ ។ ឯវំ គណេតព្វំ ។

បច្ចនីយំ ។

(៨៤) ហេតុប្បច្ចយា នអារម្មណេ តីណិ ... នអធិបតិយា នអនន្តរេ នសមនន្តរេ នឧបនិស្សយេ នបុរេជាតេ នបច្ឆាជាតេ នអាសេវនេ តីណិ ។ សង្ខិត្តំ ។ នមគ្គេ នវិប្បយុត្តេ នោនត្ថិយា នោ-វិគតេ តីណិ ។ ឯវំ គណេតព្វំ ។

អនុលោមប្បច្ចនីយំ ។

(៨៥) នហេតុប្បច្ចយា អារម្មណេ សត្ត ... អធិបតិយា សត្ត អនន្តរេ នវ សមនន្តរេ នវ សហ-ជាតេ តីណិ អញ្ញមញ្ញេ តីណិ និស្សយេ តីណិ

(៥៤២) ធម៌ ខាងក្រៅ ជាបច្ច័យ នៃធម៌ ខាងក្នុង ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត គឺ បុគ្គល (ឃើញ) នូវចក្ខុ ខាងក្រៅ ... នូវវត្ថុ ជាមិនទៀង ... ទោមនស្ស កើតឡើង បុគ្គល (ឃើញ) នូវរូប ដោយទិព្វចក្ខុ ... នូវសំឡេង ដោយទិព្វសោតធាតុ ... រូបាយតនៈ ខាងក្រៅ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ ខាងក្នុង ។បេ។

ពហិទ្ធា ផោដ្ឋព្វាយតនំ អជ្ឈត្តស្ស កាយវិញ្ញាណស្ស បុរេជាតប្បច្ចយេន បច្ចយោ ។

(៨៨៣) អជ្ឈត្តា ច ពហិទ្ធា ច ធម្មា អជ្ឈត្តស្ស ធម្មស្ស បុរេជាតប្បច្ចយេន បច្ចយោ អារម្មណបុរេជាតំ វត្ថុបុរេជាតំ ពហិទ្ធា រូបាយតនញ្ច អជ្ឈត្តំ ចក្ខាយតនញ្ច អជ្ឈត្តស្ស ចក្ខុវិញ្ញាណស្ស បុរេជាតប្បច្ចយេន បច្ចយោ ពហិទ្ធា ផោដ្ឋព្វាយតនញ្ច អជ្ឈត្តំ កាយាយតនញ្ច អជ្ឈត្តស្ស កាយវិញ្ញាណស្ស ពហិទ្ធា រូបាយតនញ្ច អជ្ឈត្តំ វត្ថុ ច ... ពហិទ្ធា ផោដ្ឋព្វាយតនញ្ច អជ្ឈត្តំ វត្ថុ ច អជ្ឈត្តានំ ខន្ធានំ បុរេជាតប្បច្ចយេន បច្ចយោ ។

(៨៨៤) អជ្ឈត្តា ច ពហិទ្ធា ច ធម្មា ពហិទ្ធា ធម្មស្ស បុរេជាតប្បច្ចយេន បច្ចយោ អារម្មណបុរេជាតំ វត្ថុបុរេជាតំ អជ្ឈត្តំ រូបាយតនញ្ច ពហិទ្ធា ចក្ខាយតនញ្ច ពហិទ្ធា ចក្ខុវិញ្ញាណស្ស បុរេជាតប្បច្ចយេន បច្ចយោ អជ្ឈត្តំ ផោដ្ឋព្វាយតនញ្ច ពហិទ្ធា កាយាយតនញ្ច ពហិទ្ធា កាយវិញ្ញាណស្ស បុរេជាតប្បច្ចយេន បច្ចយោ អជ្ឈត្តំ រូបាយតនញ្ច ពហិទ្ធា វត្ថុ ច ... អជ្ឈត្តំ ផោដ្ឋព្វាយតនញ្ច

ផោដ្ឋព្វាយតនៈ ខាងក្រៅ ជាបច្ច័យ នៃកាយវិញ្ញាណ ខាងក្នុង ដោយបុរេជាតប្បច្ច័យ ។

(៨៨៣) ធម៌ ខាងក្នុងក្តី ធម៌ ខាងក្រៅក្តី ជាបច្ច័យ នៃធម៌ ខាងក្នុង ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត គឺ រូបាយតនៈ ខាងក្រៅក្តី ចក្ខាយតនៈ ខាងក្នុងក្តី ជាបច្ច័យ នៃចក្ខុវិញ្ញាណ ខាងក្នុង ដោយបុរេជាតប្បច្ច័យ ផោដ្ឋព្វាយតនៈ ខាងក្រៅក្តី កាយាយតនៈ ខាងក្នុងក្តី (ជាបច្ច័យ) នៃកាយវិញ្ញាណ ខាងក្នុង រូបាយតនៈ ខាងក្រៅក្តី វត្ថុ ខាងក្នុងក្តី ... ផោដ្ឋព្វាយតនៈ ខាងក្រៅក្តី វត្ថុ ខាងក្នុងក្តី ជាបច្ច័យ នៃពួកខន្ធ ខាងក្នុង ដោយបុរេជាតប្បច្ច័យ ។

(៨៨៤) ធម៌ ខាងក្នុងក្តី ធម៌ ខាងក្រៅក្តី ជាបច្ច័យ នៃធម៌ ខាងក្រៅ ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត គឺ រូបាយតនៈ ខាងក្នុងក្តី ចក្ខាយតនៈ ខាងក្រៅក្តី ជាបច្ច័យ នៃចក្ខុវិញ្ញាណ ខាងក្រៅ ដោយបុរេជាតប្បច្ច័យ ផោដ្ឋព្វាយតនៈ ខាងក្នុងក្តី កាយាយតនៈ ខាងក្រៅក្តី ជាបច្ច័យ នៃកាយវិញ្ញាណ ខាងក្រៅ ដោយបុរេជាតប្បច្ច័យ រូបាយតនៈ ខាងក្នុងក្តី វត្ថុ ខាងក្រៅក្តី ... ផោដ្ឋព្វាយតនៈ ខាងក្នុងក្តី

ពហិទ្ធា វត្ថុ ច ពហិទ្ធា ខន្ធានំ បុរេជាតប្បច្ចយេន បច្ចយោ ។

(៥៥៥) អជ្ឈត្តោ ធម្មោ អជ្ឈត្តស្ស ធម្មស្ស បច្ឆាជាតប្បច្ចយេន បច្ចយោ បច្ឆាជាតា អជ្ឈត្តា ខន្ធា បុរេជាតស្ស ឥមស្ស កាយស្ស បច្ឆាជាតប្បច្ចយេន បច្ចយោ ។

(៥៥៦) ពហិទ្ធា ធម្មោ ពហិទ្ធា ធម្មស្ស បច្ឆាជាតប្បច្ចយេន បច្ចយោ បច្ឆាជាតា ពហិទ្ធា ខន្ធា បុរេជាតស្ស ឥមស្ស កាយស្ស បច្ឆាជាតប្បច្ចយេន បច្ចយោ ។

(៥៥៧) អជ្ឈត្តោ ធម្មោ អជ្ឈត្តស្ស ធម្មស្ស អាសេវនប្បច្ចយេន បច្ចយោ បុរិមា បុរិមា អជ្ឈត្តា ខន្ធា បច្ឆិមានំ បច្ឆិមានំ អជ្ឈត្តានំ ខន្ធានំ អាសេវនប្បច្ចយេន បច្ចយោ អនុលោមំ គោត្រភុស្ស អនុលោមំ វោទានស្ស គោត្រភុ. មគ្គស្ស វោទានំ មគ្គស្ស អាសេវនប្បច្ចយេន បច្ចយោ ។

(៥៥៨) ពហិទ្ធា ធម្មោ ពហិទ្ធា ធម្មស្ស អាសេវនប្បច្ចយេន បច្ចយោ បុរិមា បុរិមា ។ បេ ។ អជ្ឈត្តសទិសំ យេវ ។

វត្ថុ ខាងក្រៅក្តី ជាបច្ច័យ នៃពួកខន្ធ ខាងក្រៅ ដោយបុរេជាតប្បច្ច័យ ។

(៥៥៥) ធម៌ ខាងក្នុង ជាបច្ច័យ នៃធម៌ ខាងក្នុង ដោយបច្ឆាជាតប្បច្ច័យ បានដល់បច្ឆាជាត គឺ ពួកខន្ធ ខាងក្នុង ជាបច្ច័យ នៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

(៥៥៦) ធម៌ ខាងក្រៅ ជាបច្ច័យ នៃធម៌ ខាងក្រៅ ដោយបច្ឆាជាតប្បច្ច័យ បានដល់បច្ឆាជាត គឺ ពួកខន្ធ ខាងក្រៅ ជាបច្ច័យ នៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

(៥៥៧) ធម៌ ខាងក្នុង ជាបច្ច័យ នៃធម៌ ខាងក្នុង ដោយអាសេវនប្បច្ច័យ គឺ ពួកខន្ធ ខាងក្នុង មុនៗ ជាបច្ច័យ នៃពួកខន្ធ ខាងក្នុង ក្រោយៗ ដោយអាសេវនប្បច្ច័យ អនុលោម (ជាបច្ច័យ) នៃគោត្រភូ អនុលោម (ជាបច្ច័យ) នៃវោទានៈ គោត្រភូ (ជាបច្ច័យ) នៃមគ្គ វោទានៈ ជាបច្ច័យ នៃមគ្គ ដោយអាសេវនប្បច្ច័យ ។

(៥៥៨) ធម៌ ខាងក្រៅ ជាបច្ច័យ នៃធម៌ ខាងក្រៅ ដោយអាសេវនប្បច្ច័យ គឺ មុនៗ ។ បេ ។ ដូចគ្នានឹងអជ្ឈត្តធម៌ដែរ ។

(៤៥៩) អជ្ឈត្តោ ធម្មោ អជ្ឈត្តស្ស ធម្មស្ស កម្មប្បច្ចយេន បច្ចយោ សហជាតា នានាខណិកា ។ សហជាតា អជ្ឈត្តា ចេតនា សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ កម្មប្បច្ចយេន បច្ចយោ ។ នានាខណិកា អជ្ឈត្តា ចេតនា វិបាកានំ អជ្ឈត្តានំ ខន្ធានំ កដត្តា ច រូបានំ កម្មប្បច្ចយេន បច្ចយោ ។

(៤៦០) ពាហិរោ ធម្មោ ពាហិរស្ស ធម្មស្ស កម្មប្បច្ចយេន បច្ចយោ សហជាតា នានាខណិកា ។ សហជាតា ពាហិរា ចេតនា សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ កម្មប្បច្ចយេន បច្ចយោ ។ នានាខណិកា ពាហិរា ចេតនា វិបាកានំ ពាហិរានំ ខន្ធានំ កដត្តា ច រូបានំ កម្មប្បច្ចយេន បច្ចយោ ។

(៤៦១) អជ្ឈត្តោ ធម្មោ អជ្ឈត្តស្ស ធម្មស្ស វិបាកប្បច្ចយេន បច្ចយោ បរិបុណ្ណំ បដិច្ចវារសទិសំ ។

(៤៦២) អជ្ឈត្តោ ធម្មោ អជ្ឈត្តស្ស ធម្មស្ស អាហារប្បច្ចយេន បច្ចយោ អជ្ឈត្តា អាហារា សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ អាហារប្បច្ចយេន បច្ចយោ បដិសន្ធិក្ខណេ

(៤៥៩) ធម៌ ខាងក្នុង ជាបច្ច័យ នៃធម៌ ខាងក្នុង ដោយកម្មប្បច្ច័យ បានដល់សហជាត និងនានាខណិកៈ ។ សហជាត គឺ ចេតនា ខាងក្នុង ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺ ចេតនា ខាងក្នុង ជាបច្ច័យ នៃពួកវិបាកក្ខន្ធ ខាងក្នុងផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

(៤៦០) ធម៌ ខាងក្រៅ ជាបច្ច័យ នៃធម៌ ខាងក្រៅ ដោយកម្មប្បច្ច័យ បានដល់សហជាត និងនានាខណិកៈ ។ សហជាត គឺ ចេតនា ខាងក្រៅ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺ ចេតនា ខាងក្រៅ ជាបច្ច័យ នៃពួកវិបាកក្ខន្ធ ខាងក្រៅផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

(៤៦១) ធម៌ ខាងក្នុង ជាបច្ច័យ នៃធម៌ ខាងក្នុង ដោយវិបាកប្បច្ច័យ គឺ (ចប់) បរិបូណ៌ ដូចបដិច្ចវារៈដែរ ។

(៤៦២) ធម៌ ខាងក្នុង ជាបច្ច័យ នៃធម៌ ខាងក្នុង ដោយអាហារប្បច្ច័យ គឺ ពួកអាហារ ខាងក្នុង ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ

អជ្ឈត្តោ កពឡីការោ អាហារោ អជ្ឈត្តស្ស កាយស្ស អាហារប្បច្ចយេន បច្ចយោ ។

(៩៦៣) អជ្ឈត្តោ ធម្មោ ពហិទ្ធា ធម្មស្ស អាហារប្បច្ចយេន បច្ចយោ អជ្ឈត្តោ កពឡីការោ អាហារោ ពហិទ្ធា កាយស្ស អាហារប្បច្ចយេន បច្ចយោ ។

(៩៦៤) ពហិទ្ធា ធម្មោ ពហិទ្ធា ធម្មស្ស អាហារប្បច្ចយេន បច្ចយោ បវត្តិប្បដិសន្ធិ ។ ពហិទ្ធា កពឡីការោ អាហារោ ពហិទ្ធា កាយស្ស អាហារប្បច្ចយេន បច្ចយោ ។

(៩៦៥) ពហិទ្ធា ធម្មោ អជ្ឈត្តស្ស ធម្មស្ស អាហារប្បច្ចយេន បច្ចយោ ពហិទ្ធា កពឡីការោ អាហារោ អជ្ឈត្តស្ស កាយស្ស អាហារប្បច្ចយេន បច្ចយោ ។

(៩៦៦) អជ្ឈត្តោ ធម្មោ ច ពហិទ្ធា ធម្មោ ច អជ្ឈត្តស្ស ធម្មស្ស អាហារប្បច្ចយេន បច្ចយោ អជ្ឈត្តោ កពឡីការោ អាហារោ ច ពហិទ្ធា កពឡីការោ អាហារោ ច អជ្ឈត្តស្ស កាយស្ស អាហារប្បច្ចយេន បច្ចយោ ។

កពឡីការាហារ ខាងក្នុង ជាបច្ច័យ នៃកាយ ខាងក្នុង ដោយ អាហារប្បច្ច័យ ។

(៩៦៣) ធម៌ ខាងក្នុង ជាបច្ច័យ នៃធម៌ ខាងក្រៅ ដោយ អាហារប្បច្ច័យ គឺ កពឡីការាហារ ខាងក្នុង ជាបច្ច័យ នៃកាយ ខាងក្រៅ ដោយអាហារប្បច្ច័យ ។

(៩៦៤) ធម៌ ខាងក្រៅ ជាបច្ច័យ នៃធម៌ ខាងក្រៅ ដោយ អាហារប្បច្ច័យ ក្នុងបវត្តិប្បដិសន្ធិ ។ កពឡីការាហារ ខាងក្រៅ ជាបច្ច័យ នៃកាយ ខាងក្រៅ ដោយអាហារប្បច្ច័យ ។

(៩៦៥) ធម៌ ខាងក្រៅ ជាបច្ច័យ នៃធម៌ ខាងក្នុង ដោយ អាហារប្បច្ច័យ គឺ កពឡីការាហារ ខាងក្រៅ ជាបច្ច័យ នៃកាយ ខាងក្នុង ដោយអាហារប្បច្ច័យ ។

(៩៦៦) ធម៌ ខាងក្នុងក្តី ធម៌ ខាងក្រៅក្តី ជាបច្ច័យ នៃធម៌ ខាងក្នុង ដោយអាហារប្បច្ច័យ គឺ កពឡីការាហារ ខាងក្នុងក្តី កពឡីការាហារ ខាងក្រៅក្តី ជាបច្ច័យ នៃកាយ ខាងក្នុង ដោយ អាហារប្បច្ច័យ ។

(៤៦៧) អជ្ឈត្តោ ធម្មោ ច ពាហិរោ ធម្មោ ច ពាហិរស្ស ធម្មស្ស អាហារប្បច្ចយេន បច្ចយោ អជ្ឈត្តោ កពឡីការោ អាហារោ ច ពាហិរោ កពឡីការោ អាហារោ ច ពាហិរស្ស កាយស្ស អាហារប្បច្ចយេន បច្ចយោ ។

(៤៦៨) អជ្ឈត្តោ ធម្មោ អជ្ឈត្តស្ស ធម្មស្ស ឥន្ទ្រិយប្បច្ចយេន បច្ចយោ អជ្ឈត្តិកា ឥន្ទ្រិយា រូបជីវិតិន្ទ្រិយស្ស វិត្ថារេតព្វំ ។ ឈានប្បច្ចយេន បច្ចយោ មគ្គប្បច្ចយេន បច្ចយោ សម្បយុត្តប្បច្ចយេន បច្ចយោ វិប្បយុត្តប្បច្ចយេន បច្ចយោ សហជាតំ បុរេជាតំ បច្ឆាជាតំ មាតិកាបទានិ អនុមជ្ជន្តេន វិត្ថារេតព្វានិ ។

(៤៦៩) ពាហិរោ ធម្មោ ពាហិរស្ស ធម្មស្ស វិប្បយុត្តប្បច្ចយេន បច្ចយោ សហជាតំ បុរេជាតំ បច្ឆាជាតំ ។ សង្ខិត្តំ ។

(៤៧០) អជ្ឈត្តោ ធម្មោ អជ្ឈត្តស្ស ធម្មស្ស អត្ថិប្បច្ចយេន បច្ចយោ សហជាតំ បុរេជាតំ បច្ឆាជាតំ

(៤៦៧) ធម៌ខាងក្នុងក្ដី ធម៌ខាងក្រៅក្ដី ជាបច្ច័យនៃធម៌ខាងក្រៅ ដោយអាហារប្បច្ច័យ គឺ កពឡីការាហារ ខាងក្នុងក្ដី កពឡីការាហារ ខាងក្រៅក្ដី ជាបច្ច័យ នៃកាយ ខាងក្រៅ ដោយអាហារប្បច្ច័យ ។

(៤៦៨) ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយ ដែលប្រព្រឹត្តទៅខាងក្នុង ដល់រូបជីវិតិន្ទ្រិយ បណ្ឌិតគប្បីឲ្យពិស្ដារចុះ ។ ជាបច្ច័យ ដោយឈានប្បច្ច័យ ជាបច្ច័យ ដោយមគ្គប្បច្ច័យ ជាបច្ច័យ ដោយសម្បយុត្តប្បច្ច័យ ជាបច្ច័យ ដោយវិប្បយុត្តប្បច្ច័យ មានដល់សហជាត បុរេជាត និងបច្ឆាជាត បទនៃមាតិកាទាំងឡាយ បណ្ឌិត កាលអនុម័ត គប្បីឲ្យពិស្ដារចុះ ។

(៤៦៩) ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្រៅ ដោយវិប្បយុត្តប្បច្ច័យ មានដល់សហជាត បុរេជាត និងបច្ឆាជាត ។ សេចក្ដីបំប្រួញ ។

(៤៧០) ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយអត្ថិប្បច្ច័យ មានដល់សហជាត បុរេជាត បច្ឆាជាត

អាហារំ ឥន្ទ្រិយំ ។ សហជាតោ អជ្ឈត្តោ ឯកោ ខន្ធោ តិណ្ណន្នំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ ទ្វេ ខន្ធា ... បដិសន្ធិក្ខណេ ខន្ធា វត្ថុស្ស វត្ថុ ខន្ធានំ ឯកំ មហាភូតំ ... ។ សង្ខិត្តំ ។ អសញ្ញសត្តានំ ឯកំ មហាភូតំ តិណ្ណន្នំ មហាភូតានំ ។ បុរេជាតំ ចក្ខុំ ... វត្ថុំ ... បុរេជាតសទិសំ ។ វត្ថុ អជ្ឈត្តានំ ខន្ធានំ អត្ថិប្បច្ចយេន បច្ចយោ ។ បច្ឆាជាតា អជ្ឈត្តា ខន្ធា អជ្ឈត្តោ កពឡីការោ អាហារោ ច ឥមស្ស កាយស្ស រូបជីវិតិន្ទ្រិយំ កដត្តារូបានំ ។

(៤៧១) អជ្ឈត្តោ ធម្មោ ពហិទ្ធា ធម្មស្ស អត្ថិប្បច្ចយេន បច្ចយោ បុរេជាតំ អាហារំ ។ បុរេជាតំ បរេ អជ្ឈត្តំ ចក្ខុំ ... វត្ថុំ អនិច្ចតោ ... វិបស្សតិ ទិព្វេន ចក្ខុនា ... ទិព្វាយ សោតធាតុយា ... អជ្ឈត្តំ រូបាយតនំ ... ផោដ្ឋព្វាយតនំ ពហិទ្ធា កាយវិញ្ញាណស្ស អត្ថិប្បច្ចយេន បច្ចយោ ។ អជ្ឈត្តោ កពឡីការោ អាហារោ ពហិទ្ធា កាយស្ស អត្ថិប្បច្ចយេន បច្ចយោ ។

កាហារ និងឥន្ទ្រិយ ។ សហជាត គឺ ខន្ធ ១ ខាងក្នុង (ជាបច្ច័យ) នៃខន្ធ ៣ ផង នៃចិត្តសមុដ្ឋានរូបផង ខន្ធ ២ ... ពួកខន្ធ (ជាបច្ច័យ) នៃវត្ថុ ក្នុងខណៈនៃបដិសន្ធិ វត្ថុ (ជាបច្ច័យ) នៃពួកខន្ធ មហាភូត ១ ... ។ សេចក្តីបំប្រួញ ។ មហាភូត ១ របស់ពួកអសញ្ញសត្វ (ជាបច្ច័យ) នៃមហាភូត ៣ ។ បុរេជាត គឺ ចក្ខុ ... វត្ថុ ... ដូចគ្នានឹងបុរេជាតដែរ ។ វត្ថុ ជាបច្ច័យ នៃពួកខន្ធ ខាងក្នុង ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺ ពួកខន្ធ ខាងក្នុងក្តី កពឡិង្ការាហារ ខាងក្នុងក្តី (ជាបច្ច័យ) នៃកាយ នេះ រូបជីវិតិន្ទ្រិយ (ជាបច្ច័យ) នៃពួកកដត្តារូប ។

(៤៧១) ធម៌ ខាងក្នុង ជាបច្ច័យ នៃធម៌ ខាងក្រៅ ដោយអត្ថិប្បច្ច័យ បានដល់បុរេជាត និងអាហារ ។ បុរេជាត គឺ បុគ្គលដទៃ ឃើញច្បាស់ ចក្ខុ ខាងក្នុង ... វត្ថុ ជាមិនទៀង ... ដោយទិព្វចក្ខុ ... ដោយទិព្វសោតធាតុ ... រូបាយតនៈ ខាងក្នុង ... ផោដ្ឋព្វាយតនៈ ជាបច្ច័យ នៃកាយវិញ្ញាណ ខាងក្រៅ ដោយអត្ថិប្បច្ច័យ ។ កពឡិង្ការាហារ ខាងក្នុង ជាបច្ច័យ នៃកាយ ខាងក្រៅ ដោយអត្ថិប្បច្ច័យ ។

(៤៧២) ពាហិរោ ធម្មោ ពាហិរស្ស ធម្មស្ស អត្ថិ-
បច្ចយេន បច្ចយោ សហជាតំ បុរេជាតំ បច្ឆាជាតំ
អាហារំ ឥន្ទ្រិយំ ពាហិរា ខន្ធាជាការណំ មាតិកា-
បទានិ វិត្ថារេតព្ពានិ ។

(៤៧៣) ពាហិរោ ធម្មោ អជ្ឈត្តិកស្ស ធម្មស្ស
អត្ថិបច្ចយេន បច្ចយោ បុរេជាតំ អាហារំ ។ បុរេ-
ជាតំ ពាហិរំ ចក្ខុំ ... វត្ថុំ ... ទិព្វេន ចក្ខុនា
រូបំ ... ទិព្វាយ សោតធាតុយា សទ្ទំ ... ពាហិរំ
រូបាយតនំ ... ផោដ្ឋព្វាយតនំ អជ្ឈត្តស្ស កាយ-
វិញ្ញាណស្ស អត្ថិបច្ចយេន បច្ចយោ ។ ពាហិរោ
កពឡីការោ អាហារោ អជ្ឈត្តស្ស កាយស្ស
អត្ថិបច្ចយេន បច្ចយោ ។

(៤៧៤) អជ្ឈត្តោ ច ពាហិរោ ច ធម្មា ច
អជ្ឈត្តិកស្ស ធម្មស្ស អត្ថិបច្ចយេន បច្ចយោ បុរេ-
ជាតំ អាហារំ ។ បុរេជាតំ ពាហិរំ រូបាយត-
នញ្ច អជ្ឈត្តំ ចក្ខុ ច អជ្ឈត្តស្ស ចក្ខុវិញ្ញាណស្ស
ពាហិរំ ផោដ្ឋព្វាយតនញ្ច អជ្ឈត្តំ កាយាយតនញ្ច
អជ្ឈត្តស្ស កាយវិញ្ញាណស្ស អត្ថិបច្ចយេន បច្ចយោ

(៤៧២) ធម៌ ខាងក្រៅ ជាបច្ច័យ នៃធម៌ ខាងក្រៅ ដោយ
អត្ថិបច្ច័យ បានដល់សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ
មិនមានការធ្វើឲ្យផ្សេង ១ គ្នា ត្រូវធម៌ជាខាងក្រៅឡើយ ឯបទនៃ
មាតិកាទាំងឡាយ បណ្ឌិត គប្បីឲ្យពិស្តារចុះ ។

(៤៧៣) ធម៌ ខាងក្រៅ ជាបច្ច័យ នៃធម៌ ខាងក្នុង ដោយ
អត្ថិបច្ច័យ បានដល់បុរេជាត និងអាហារ ។ បុរេជាត គឺ បុគ្គល
(ឃើញច្បាស់) នូវចក្ខុ ខាងក្រៅ ... នូវវត្ថុ ... នូវរូប ដោយ
ទិព្វចក្ខុ ... នូវសំឡេង ដោយទិព្វសោតធាតុ ... រូបាយតនៈ ខាង
ក្រៅ ... ផោដ្ឋព្វាយតនៈ ជាបច្ច័យ នៃកាយវិញ្ញាណ ខាងក្នុង
ដោយអត្ថិបច្ច័យ ។ កពឡីការាហារ ខាងក្រៅ ជាបច្ច័យ នៃកាយ
ខាងក្នុង ដោយអត្ថិបច្ច័យ ។

(៤៧៤) ធម៌ ខាងក្នុងក្ដី ធម៌ ខាងក្រៅក្ដី ជាបច្ច័យ នៃធម៌
ខាងក្នុង ដោយអត្ថិបច្ច័យ បានដល់បុរេជាត និងអាហារ ។ បុរេ-
ជាត គឺ រូបាយតនៈ ខាងក្រៅក្ដី ចក្ខុ ខាងក្នុងក្ដី (ជាបច្ច័យ) នៃ
ចក្ខុវិញ្ញាណ ខាងក្នុង ផោដ្ឋព្វាយតនៈ ខាងក្រៅក្ដី កាយាយតនៈ
ខាងក្នុងក្ដី ជាបច្ច័យ នៃកាយវិញ្ញាណ ខាងក្នុង ដោយអត្ថិបច្ច័យ

ពហិទ្ធា រូបាយតនញ្ច អជ្ឈត្តំ វត្ថុ ច ... ពហិទ្ធា ផោដ្ឋព្វាយតនញ្ច អជ្ឈត្តំ វត្ថុ ច អជ្ឈត្តានំ ខន្ធានំ អត្ថិប្បច្ចយេន បច្ចយោ ។ អាហារំ អជ្ឈត្តោ កពឡិង្ការោ អាហារោ ច ពហិទ្ធា កពឡិង្ការោ អាហារោ ច អជ្ឈត្តស្ស កាយស្ស អត្ថិប្បច្ចយេន បច្ចយោ ។

(៥៧៥) អជ្ឈត្តោ ធម្មោ ច ពហិទ្ធា ធម្មោ ច ពហិទ្ធា ធម្មស្ស អត្ថិប្បច្ចយេន បច្ចយោ បុរេជាតំ អាហារំ ។ បុរេជាតំ អជ្ឈត្តំ រូបាយតនញ្ច ពហិទ្ធា ចក្ខាយតនញ្ច ពហិទ្ធា ចក្ខុវិញ្ញាណស្ស អត្ថិប្បច្ចយេន បច្ចយោ អជ្ឈត្តំ ផោដ្ឋព្វាយតនញ្ច ពហិទ្ធា កាយាយតនញ្ច ពហិទ្ធា កាយវិញ្ញាណស្ស អត្ថិប្បច្ចយេន បច្ចយោ អជ្ឈត្តំ រូបាយតនញ្ច ពហិទ្ធា វត្ថុ ច ពហិទ្ធា ខន្ធានំ អត្ថិប្បច្ចយេន បច្ចយោ អជ្ឈត្តំ ផោដ្ឋព្វាយតនញ្ច ពហិទ្ធា វត្ថុ ច ពហិទ្ធា ខន្ធានំ អត្ថិប្បច្ចយេន បច្ចយោ ។ អាហារំ អជ្ឈត្តោ កពឡិង្ការោ អាហារោ ច ពហិទ្ធា កពឡិង្ការោ អាហារោ ច ពហិទ្ធា កាយស្ស អត្ថិប្បច្ចយេន បច្ចយោ ។

រូបាយតនៈ ខាងក្រៅក្តី វត្ថុ ខាងក្នុងក្តី ... ផោដ្ឋព្វាយតនៈ ខាងក្រៅក្តី វត្ថុ ខាងក្នុងក្តី ជាបច្ច័យ នៃពួកខន្ធ ខាងក្នុង ដោយអត្ថិប្បច្ច័យ ។ ឯអាហារ គឺ កពឡិង្ការាហារ ខាងក្នុងក្តី កពឡិង្ការាហារ ខាងក្រៅក្តី ជាបច្ច័យ នៃកាយ ខាងក្នុង ដោយអត្ថិប្បច្ច័យ ។

(៥៧៥) ធម៌ ខាងក្នុងក្តី ធម៌ ខាងក្រៅក្តី ជាបច្ច័យ នៃធម៌ ខាងក្រៅ ដោយអត្ថិប្បច្ច័យ បានដល់បុរេជាត និងអាហារ ។ បុរេជាត គឺ រូបាយតនៈ ខាងក្នុងក្តី ចក្ខាយតនៈ ខាងក្រៅក្តី ជាបច្ច័យ នៃចក្ខុវិញ្ញាណ ខាងក្រៅ ដោយអត្ថិប្បច្ច័យ ផោដ្ឋព្វាយតនៈ ខាងក្នុងក្តី កាយាយតនៈ ខាងក្រៅក្តី ជាបច្ច័យ នៃកាយវិញ្ញាណ ខាងក្រៅ ដោយអត្ថិប្បច្ច័យ រូបាយតនៈ ខាងក្នុងក្តី វត្ថុ ខាងក្រៅក្តី ជាបច្ច័យ នៃពួកខន្ធ ខាងក្រៅ ដោយអត្ថិប្បច្ច័យ ផោដ្ឋព្វាយតនៈ ខាងក្នុងក្តី វត្ថុ ខាងក្រៅក្តី ជាបច្ច័យ នៃពួកខន្ធ ខាងក្រៅ ដោយអត្ថិប្បច្ច័យ ។ ឯអាហារ គឺ កពឡិង្ការាហារ ខាងក្នុងក្តី កពឡិង្ការាហារ ខាងក្រៅក្តី ជាបច្ច័យ នៃកាយ ខាងក្រៅ ដោយអត្ថិប្បច្ច័យ ។

(៤៧៦) អព្យាកតោ ធម្មោ អព្យាកតស្ស ធម្មស្ស នត្ថិប្បច្ចយេន បច្ចយោ វិគតប្បច្ចយេន បច្ចយោ អវិគតប្បច្ចយេន បច្ចយោ ។

(៤៧៧) ហេតុយា ទ្វេ អារម្មណេ ចត្តារិ អធិបតិយា ចត្តារិ អនន្តរេ ទ្វេ សមនន្តរេ ទ្វេ សហជាតេ អញ្ញមញ្ញេ និស្សយេ ទ្វេ ឧបនិស្សយេ ចត្តារិ បុរេជាតេ ឆ បច្ឆាជាតេ អាសេវនេ កម្មេ វិបាកេ ទ្វេ អាហារេ ឆ ឥន្ទ្រិយេ ទ្វេ ឈានេ មគ្គេ សម្បយុត្តេ វិប្បយុត្តេ ទ្វេ អត្ថិយា ឆ នត្ថិយា ទ្វេ វិគតេ ទ្វេ អវិគតេ ឆ ។ ឯវំ គណេតព្វំ ។

អនុលោមំ ។

(៤៧៨) អព្យាកតោ ធម្មោ អព្យាកតស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ សហជាតប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ បុរេជាតប្បច្ចយេន បច្ចយោ បច្ឆាជាតប្បច្ចយេន បច្ចយោ កម្មប្បច្ចយេន បច្ចយោ អាហារប្បច្ចយេន បច្ចយោ ឥន្ទ្រិយប្បច្ចយេន បច្ចយោ ។

(៤៧៦) ធម៌ ខានកុន ជាបច្ច័យ នៃធម៌ ខានកុន ដោយនត្ថិប្បច្ច័យ ជាបច្ច័យ ដោយវិគតប្បច្ច័យ ជាបច្ច័យ ដោយអវិគតប្បច្ច័យ ។

(៤៧៧) ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និងនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុងបច្ឆាជាតប្បច្ច័យ អាសេវនប្បច្ច័យ កម្មប្បច្ច័យ និងវិបាកប្បច្ច័យ មានវារៈ ២ ក្នុងអាហារប្បច្ច័យ មានវារៈ ៦ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ២ ក្នុងឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ និងវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៦ ក្នុងនត្ថិប្បច្ច័យ មានវារៈ ២ ក្នុងវិគតប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៦ ។ បណ្ឌិត គប្បីរាប់ យ៉ាងនេះឯង ។

ចប់ អនុលោម ។

(៤៧៨) ធម៌ ខានកុន ជាបច្ច័យ នៃធម៌ ខានកុន ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយកម្មប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ ។

(៨៧៩) អជ្ឈត្តោ ធម្មោ ពហិទ្ធា ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ បុរេជាតប្បច្ចយេន បច្ចយោ អាហារប្បច្ចយេន បច្ចយោ ។

(៨៨០) ពហិទ្ធា ធម្មោ ពហិទ្ធា ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ សហជាតប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ បុរេជាតប្បច្ចយេន បច្ចយោ បច្ឆាជាតប្បច្ចយេន បច្ចយោ កម្មប្បច្ចយេន បច្ចយោ អាហារប្បច្ចយេន បច្ចយោ ឥន្ទ្រិយប្បច្ចយេន បច្ចយោ ។

(៨៨១) ពហិទ្ធា ធម្មោ អជ្ឈត្តស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ បុរេជាតប្បច្ចយេន បច្ចយោ អាហារប្បច្ចយេន បច្ចយោ ។

(៨៨២) អជ្ឈត្តោ ធម្មោ ច ពហិទ្ធា ធម្មោ ច អជ្ឈត្តស្ស ធម្មស្ស ... បុរេជាតំ អាហារំ ។

(៨៨៣) អជ្ឈត្តោ ធម្មោ ច ពហិទ្ធា ធម្មោ ច ពហិទ្ធា ធម្មស្ស ... បុរេជាតំ អាហារំ ។

(៨៧៩) ធម៌ខាងក្នុង ជាបច្ច័យ នៃធម៌ខាងក្រៅ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ។

(៨៨០) ធម៌ខាងក្រៅ ជាបច្ច័យ នៃធម៌ខាងក្រៅ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយកម្មប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ ។

(៨៨១) ធម៌ខាងក្រៅ ជាបច្ច័យ នៃធម៌ខាងក្នុង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ។

(៨៨២) ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ជាបច្ច័យ នៃធម៌ខាងក្នុង ... បានដល់បុរេជាត និងអាហារ ។

(៨៨៣) ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី (ជាបច្ច័យ) នៃធម៌ខាងក្រៅ ... បានដល់បុរេជាត និងអាហារ ។

(៥៨៤) នហេតុយា ២ នអារម្មណេ ២ នអធិបតិយា ២ ។ សង្ខិត្តំ ។ សព្វត្ថ ២ កាតព្វា នវិប្បយុត្តេ ២ នោអត្ថិយា ចត្តារិ នោនត្ថិយា ២ នោវិគតេ ២ នោអវិគតេ ចត្តារិ ។ ឯវំ គណេតព្វំ ។

បច្ចនីយំ ។

(៥៨៥) ហេតុប្បច្ចយា នអារម្មណេ ទ្វេ ... នអធិបតិយា នអនន្តរេ នសមនន្តរេ នអញ្ញមញ្ញេ នឧបនិស្សយេ ទ្វេ ។ សង្ខិត្តំ ។ សព្វត្ថ ទ្វេ នសម្បយុត្តេ នវិប្បយុត្តេ នោនត្ថិយា នោវិគតេ ទ្វេ ។ ឯវំ គណេតព្វំ ។

អនុលោមប្បច្ចនីយំ ។

(៥៨៤) គឺនហេតុប្បច្ច័យ មានវារៈ ២ គឺនអារម្មណប្បច្ច័យ មានវារៈ ២ គឺនអធិបតិប្បច្ច័យ មានវារៈ ២ ។ សេចក្តីបំប្រួញ ។ គ្រប់បទទាំងអស់ បណ្ឌិតគប្បីធ្វើឲ្យមានវារៈ ២ ផងចុះ គឺនវិប្បយុត្តប្បច្ច័យ មានវារៈ ២ គឺនោអត្ថិប្បច្ច័យ មានវារៈ ៤ គឺនោនត្ថិប្បច្ច័យ គឺនោវិគតប្បច្ច័យ មានវារៈ ២ គឺនោអវិគតប្បច្ច័យ មានវារៈ ៤ ។ បណ្ឌិតគប្បីរាប់ យ៉ាងនេះចុះ ។

ចប់ បច្ចនីយៈ ។

(៥៨៥) គឺនអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះហេតុប្បច្ច័យ ... គឺនអធិបតិប្បច្ច័យ នអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ នអញ្ញមញ្ញប្បច្ច័យ និងនឧបនិស្សយប្បច្ច័យ មានវារៈ ២ ។ សេចក្តីបំប្រួញ ។ គឺបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ២ គឺនសម្បយុត្តប្បច្ច័យ នវិប្បយុត្តប្បច្ច័យ នោនត្ថិប្បច្ច័យ និងនោវិគតប្បច្ច័យ មានវារៈ ២ ។ បណ្ឌិតគប្បីរាប់ យ៉ាងនេះចុះ ។

ចប់ អនុលោមប្បច្ចនីយៈ ។

(៩៨២) នហេតុប្បច្ចយា នារម្មណេ ចត្តារិ ... នាធិបតិយា ចត្តារិ អនុលោមបទានិ គណេតព្វានិ នោវិគតេ ៦ ។ ឯវំ គណេតព្វំ ។

បច្ចនីយានុលោមំ ។

បញ្ហាវារោ និដ្ឋិតោ ។

អជ្ឈត្តត្តិកំ វីសតិមំ និដ្ឋិតំ ។

([illegible]) ក្នុងនារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុប្បច្ច័យ ... ក្នុងនាធិបតិប្បច្ច័យ មានវារៈ ៤ អនុលោមបទទាំងបួន បណ្ឌិត គប្បីរាប់(តាមនេះឲ្យគ្រប់) ក្នុងនោវិគតប្បច្ច័យ មានវារៈ ៦ ។ បណ្ឌិត គប្បីរាប់ យ៉ាងនេះចុះ ។

ចប់ បច្ចនីយានុលោម ។

ចប់ បញ្ហាវារៈ ។

ចប់ អជ្ឈត្តត្តិកៈ ទី ២០ ។

អជ្ឈត្តារម្មណត្តិកំ

បដិច្ចវារោ

(៨៨៧) អជ្ឈត្តារម្មណំ ធម្មំ បដិច្ច អជ្ឈត្តារម្មណោ ធម្មោ ឧប្បជ្ជតិ ហេតុបច្ចយា អជ្ឈត្តារម្មណំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ... បដិសន្ធិក្ខណេ អជ្ឈត្តារម្មណំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ... ។

(៨៨៨) ពហិទ្ធារម្មណំ ធម្មំ បដិច្ច ពហិទ្ធារម្មណោ ធម្មោ ឧប្បជ្ជតិ ហេតុបច្ចយា ពហិទ្ធារម្មណំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ... បដិសន្ធិក្ខណេ ពហិទ្ធារម្មណំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ... ។

(៨៨៩) អជ្ឈត្តារម្មណំ ធម្មំ បដិច្ច អជ្ឈត្តារម្មណោ ធម្មោ ឧប្បជ្ជតិ អារម្មណបច្ចយា សង្ខិត្តំ ។ អវិគតបច្ចយា ។

(៨៩០) ហេតុយា ទ្វេ អារម្មណេ ទ្វេ ។ សង្ខិត្តំ ។ សព្វត្ថ ទ្វេ អវិគតេ ទ្វេ ។ ឯវំ គណេតព្វំ ។

អនុលោមំ ។

អជ្ឈត្តារម្មណត្តិកៈ

បដិច្ចវារៈ

(៨៨៧) អជ្ឈត្តារម្មណធម៌ អាស្រ័យ នូវអជ្ឈត្តារម្មណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យ នូវខន្ធ ១ ជាអជ្ឈត្តារម្មណ៍ នូវខន្ធ ២ ... ខន្ធ ៣ អាស្រ័យ នូវខន្ធ ១ ជាអជ្ឈត្តារម្មណ៍ ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... ។

(៨៨៨) ពហិទ្ធារម្មណធម៌ អាស្រ័យ នូវពហិទ្ធារម្មណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យ នូវខន្ធ ១ ជាពហិទ្ធារម្មណ៍ នូវខន្ធ ២ ... ខន្ធ ៣ អាស្រ័យ នូវខន្ធ ១ ជាពហិទ្ធារម្មណ៍ ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... ។

(៨៨៩) អជ្ឈត្តារម្មណធម៌ អាស្រ័យ នូវអជ្ឈត្តារម្មណធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ សេចក្តីបំប្រួញ ។ ព្រោះអវិគតប្បច្ច័យ ។

(៨៩០) ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ។ សេចក្តីបំប្រួញ ។ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។ បណ្ឌិត គប្បីរាប់យ៉ាងនេះចុះ ។

ចប់ អនុលោម ។

(៩៩១) អជ្ឈត្តារម្មណំ ធម្មំ បដិច្ច អជ្ឈត្តារម្មណោ ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា អហេតុកំ អជ្ឈត្តារម្មណំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ... អហេតុកបដិសន្ធិក្ខណេ អជ្ឈត្តារម្មណំ ឯកំ ខន្ធំ បដិច្ច ទ្វេ ខន្ធេ ... វិចិកិច្ឆាសហគតេ ឧទ្ធច្ចសហគតេ ខន្ធេ បដិច្ច វិចិកិច្ឆាសហគតោ ឧទ្ធច្ចសហគតោ មោហោ ។

(៩៩២) ពហិទ្ធារម្មណំ ធម្មំ បដិច្ច ពហិទ្ធារម្មណោ ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា អហេតុកំ ពហិទ្ធារម្មណំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ... អហេតុកបដិសន្ធិក្ខណេ វិចិកិច្ឆាសហគតេ ឧទ្ធច្ចសហគតេ ខន្ធេ បដិច្ច វិចិកិច្ឆាសហគតោ ឧទ្ធច្ចសហគតោ មោហោ ។

(៩៩៣) អជ្ឈត្តារម្មណំ ធម្មំ បដិច្ច អជ្ឈត្តារម្មណោ ធម្មោ ឧប្បជ្ជតិ នអធិបតិប្បច្ចយា អនុលោមសហជាតសទិសំ និន្នានាករណំ ។ នបុរេជាតប្បច្ចយា អរូបេ អជ្ឈត្តារម្មណំ ឯកំ ខន្ធំ បដិច្ច បដិសន្ធិក្ខណេ ... ។

(៩៩១) អជ្ឈត្តារម្មណធម៌ អាស្រ័យ នូវអជ្ឈត្តារម្មណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យ នូវអហេតុកក្ខន្ធ ១ ជាអជ្ឈត្តារម្មណ៍ នូវខន្ធ ២ ... អាស្រ័យ នូវខន្ធ ១ ជាអជ្ឈត្តារម្មណ៍ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ នូវខន្ធ ២ ... មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យ នូវខន្ធទាំងឡាយ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។

(៩៩២) ពហិទ្ធារម្មណធម៌ អាស្រ័យ នូវពហិទ្ធារម្មណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យ នូវអហេតុកក្ខន្ធ ១ ជាពហិទ្ធារម្មណ៍ នូវខន្ធ ២ ... មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យ នូវខន្ធទាំងឡាយ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។

(៩៩៣) អជ្ឈត្តារម្មណធម៌ អាស្រ័យ នូវអជ្ឈត្តារម្មណធម៌ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺ ដូចសហជាតប្បច្ច័យក្នុងអនុលោមដែរ មិនមានការធ្វើឲ្យផ្សេងគ្នាទេ ។ ព្រោះនបុរេជាតប្បច្ច័យ គឺ អាស្រ័យ នូវខន្ធ ១ ជាអជ្ឈត្តារម្មណ៍ ក្នុងអរូប ក្នុងខណៈនៃបដិសន្ធិ ... ។

(៥៩៤) ពហិទ្ធារម្មណំ ធម្មំ បដិច្ច ពហិទ្ធារម្មណោ ធម្មោ ឧប្បជ្ជតិ ន បុរេជាតប្បច្ចយា អរូបេ ពហិទ្ធារម្មណំ ឯកំ ខន្ធំ បដិច្ច បដិសន្ធិក្ខណេ ... ន បច្ឆាជាតប្បច្ចយា ន អាសេវនប្បច្ចយា សហជាតសទិសំ ។ ន កម្មប្បច្ចយា អជ្ឈត្តារម្មណេ ខន្ធេ បដិច្ច អជ្ឈត្តារម្មណា ចេតនា ។

(៥៩៥) ពហិទ្ធារម្មណំ ធម្មំ បដិច្ច ពហិទ្ធារម្មណោ ធម្មោ ឧប្បជ្ជតិ ន កម្មប្បច្ចយា ពហិទ្ធារម្មណេ ខន្ធេ បដិច្ច ពហិទ្ធារម្មណា ចេតនា ។

(៥៩៦) អជ្ឈត្តារម្មណំ ធម្មំ បដិច្ច ... ន វិបាកប្បច្ចយា បដិសន្ធិ នត្ថិ ។ ន ឈានប្បច្ចយា បញ្ចវិញ្ញាណសហគតំ អជ្ឈត្តារម្មណំ ឯកំ ... ។

(៥៩៧) ពហិទ្ធារម្មណំ ធម្មំ បដិច្ច ... ន ឈានប្បច្ចយា បញ្ចវិញ្ញាណសហគតំ ពហិទ្ធារម្មណំ ឯកំ ខន្ធំ ... ន មគ្គប្បច្ចយា នហេតុសទិសោ មោហោ នត្ថិ ។ ន វិប្បយុត្តប្បច្ចយា អរូបេ អជ្ឈត្តារម្មណំ ឯកំ ខន្ធំ ... ។

(៥៩៨) ពហិទ្ធារម្មណំ ធម្មំ បដិច្ច ... ន វិប្បយុត្តប្បច្ចយា អរូបេ ពហិទ្ធារម្មណំ ឯកំ ខន្ធំ ... ។

(៥៩៤) ពហិទ្ធារម្មណធម៌ អាស្រ័យ នូវពហិទ្ធារម្មណធម៌ ទើប កើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺ អាស្រ័យ នូវខន្ធ១ ជាពហិទ្ធារម្មណ៍ ក្នុងអរូប ក្នុងខណៈនៃបដិសន្ធិ ... ព្រោះនបច្ឆាជាតប្បច្ច័យ និងនអាសេវនប្បច្ច័យ គឺ ដូចគ្នានឹងសហជាតប្បច្ច័យដែរ ។ ព្រោះនកម្មប្បច្ច័យ គឺ ចេតនា ជាអជ្ឈត្តារម្មណ៍ អាស្រ័យ នូវខន្ធទាំងឡាយ ជាអជ្ឈត្តារម្មណ៍ ។

(៥៩៥) ពហិទ្ធារម្មណធម៌ អាស្រ័យ នូវពហិទ្ធារម្មណធម៌ ទើប កើតឡើង ព្រោះនកម្មប្បច្ច័យ គឺ ចេតនា ជាពហិទ្ធារម្មណ៍ អាស្រ័យ នូវខន្ធទាំងឡាយ ជាពហិទ្ធារម្មណ៍ ។

(៥៩៦) អាស្រ័យ នូវអជ្ឈត្តារម្មណធម៌ ... ព្រោះនវិបាកប្បច្ច័យ គឺ បដិសន្ធិ មិនមានទេ ។ ព្រោះនឈានប្បច្ច័យ គឺ នូវខន្ធ១ ជាអជ្ឈត្តារម្មណ៍ ដែលប្រកបដោយបញ្ចវិញ្ញាណ ... ។

(៥៩៧) អាស្រ័យ នូវពហិទ្ធារម្មណធម៌ ... ព្រោះនឈានប្បច្ច័យ គឺ នូវខន្ធ១ ជាពហិទ្ធារម្មណ៍ ដែលប្រកបដោយបញ្ចវិញ្ញាណ ... ព្រោះនមគ្គប្បច្ច័យ គឺ ដូចគ្នានឹងនហេតុប្បច្ច័យដែរ តែមោហៈ មិនមានឡើយ ។ ព្រោះនវិប្បយុត្តប្បច្ច័យ គឺ នូវខន្ធ១ ជាអជ្ឈត្តារម្មណ៍ ក្នុងអរូប ... ។

(៥៩៨) អាស្រ័យ នូវពហិទ្ធារម្មណធម៌ ... ព្រោះនវិប្បយុត្តប្បច្ច័យ គឺ នូវខន្ធ១ ជាពហិទ្ធារម្មណ៍ ក្នុងអរូប ... ។

(៥៩៩) នហេតុយា ទ្វេ នអធិបតិយា ទ្វេ នបុរេជាតេ ទ្វេ នបច្ឆាជាតេ ទ្វេ នអាសេវនេ នកម្មេ នវិបាកេ នឈានេ នមគ្គេ នវិប្បយុត្តេ ទ្វេ ។ ឯវំ គណេតព្វំ ។

បច្ចនីយំ ។

(៦០០) ហេតុប្បច្ចយា នអធិបតិយា ទ្វេ ... នវិបាកេ ទ្វេ នវិប្បយុត្តេ ទ្វេ ។ ឯវំ គណេតព្វំ ។

អនុលោមបច្ចនីយំ ។

(៦០១) នហេតុប្បច្ចយា អារម្មណេ ទ្វេ ... អនន្តរេ ទ្វេ សមនន្តរេ ទ្វេ ។ សង្ខិត្តំ ។ មគ្គេ ទ្វេ អវិគតេ ទ្វេ ។ ឯវំ គណេតព្វំ ។

បច្ចនីយានុលោមំ ។

បដិច្ចវារោ និដ្ឋិតោ ។

សហជាតវារោបិ បច្ចយវារោបិ និស្សយវារោបិ សំសដ្ឋវារោបិ សម្បយុត្តវារោបិ បដិច្ចវារសទិសា ។

(៥៩៩) ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ២ ក្នុងនអាសេវនប្បច្ច័យ នកម្មប្បច្ច័យ នវិបាកប្បច្ច័យ នឈានប្បច្ច័យ នមគ្គប្បច្ច័យ និងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ។ បណ្ឌិតគប្បីរាប់ យ៉ាងនេះចុះ ។

ចប់ បច្ចនីយៈ ។

(៦០០) ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ព្រោះហេតុប្បច្ច័យ ... ក្នុងនវិបាកប្បច្ច័យ មានវារៈ ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ។ បណ្ឌិតគប្បីរាប់ យ៉ាងនេះចុះ ។

ចប់ អនុលោមបច្ចនីយៈ ។

(៦០១) ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ២ ។ សេចក្តីបំព្រួញ ។ ក្នុងមគ្គប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។ បណ្ឌិតគប្បីរាប់ យ៉ាងនេះចុះ ។

ចប់ បច្ចនីយានុលោម ។

ចប់ បដិច្ចវារៈ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

បញ្ហាវារោ

(២០២) អជ្ឈត្តារម្មណោ ធម្មោ អជ្ឈត្តារម្មណស្ស ធម្មស្ស ហេតុបច្ចយេន បច្ចយោ អជ្ឈត្តារម្មណា ហេតូ សម្បយុត្តកានំ ខន្ធានំ ហេតុបច្ចយេន បច្ចយោ បដិសន្ធិក្ខណេ អជ្ឈត្តារម្មណា ហេតូ សម្បយុត្តកានំ ខន្ធានំ ។

(២០៣) ពហិទ្ធារម្មណោ ធម្មោ ពហិទ្ធារម្មណស្ស ធម្មស្ស ហេតុបច្ចយេន បច្ចយោ ពហិទ្ធារម្មណា ហេតូ ... បដិសន្ធិក្ខណេ ... ។

(២០៤) អជ្ឈត្តារម្មណោ ធម្មោ អជ្ឈត្តារម្មណស្ស ធម្មស្ស អារម្មណបច្ចយេន បច្ចយោ អជ្ឈត្តារម្មណំ វិញ្ញាណញ្ចាយតនំ បច្ចវេក្ខតិ នេវសញ្ញានាសញ្ញាយតនំ បច្ចវេក្ខតិ អជ្ឈត្តារម្មណំ អជ្ឈត្តំ ទិព្វំ ចក្ខុំ បច្ចវេក្ខតិ ទិព្វំ សោតធាតុំ ... ឥទ្ធិវិធញាណំ ... បុព្វេនិវាសានុស្សតិញាណំ ... យថាកម្មូបគញាណំ ... អនាគតំសញាណំ បច្ចវេក្ខតិ អរិយា អជ្ឈត្តារម្មណេ បហីនេ កិលេសេ បច្ចវេក្ខន្តិ វិក្ខម្ភិតេ កិលេសេ បច្ចវេក្ខន្តិ បុព្វេ សមុទាចិណ្ណេ ... អជ្ឈត្តារម្មណេ អជ្ឈត្តេ ខន្ធេ អនិច្ចតោ ... វិបស្សតិ

បញ្ហាវារៈ

(២០២) អជ្ឈត្តារម្មណធម៌ ជាបច្ច័យ នៃអជ្ឈត្តារម្មណធម៌ ដោយហេតុប្បច្ច័យ គឺ ពួកហេតុ ជាអជ្ឈត្តារម្មណ៍ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ពួកហេតុ ជាអជ្ឈត្តារម្មណ៍ (ជាបច្ច័យ) នៃពួកសម្បយុត្តកក្ខន្ធ ក្នុងខណៈនៃបដិសន្ធិ ។

(២០៣) ពហិទ្ធារម្មណធម៌ ជាបច្ច័យ នៃពហិទ្ធារម្មណធម៌ ដោយហេតុប្បច្ច័យ គឺ ពួកហេតុជា ពហិទ្ធារម្មណ៍ ... ក្នុងខណៈនៃបដិសន្ធិ ... ។

(២០៤) អជ្ឈត្តារម្មណធម៌ ជាបច្ច័យ នៃអជ្ឈត្តារម្មណធម៌ ដោយ អារម្មណប្បច្ច័យ គឺ បុគ្គល ពិចារណា នូវវិញ្ញាណញ្ចាយតនៈ ជាអជ្ឈត្តារម្មណ៍ ពិចារណា នូវនេវសញ្ញានាសញ្ញាយតនៈ ពិចារណា នូវទិព្វចក្ខុ ខាងក្នុង ជាអជ្ឈត្តារម្មណ៍ ពិចារណា នូវទិព្វសោតធាតុ ... នូវឥទ្ធិវិធញ្ញាណ ... នូវបុព្វេនិវាសានុស្សតិញ្ញាណ ... នូវយថាកម្មូបគញ្ញាណ ... នូវអនាគតំសញ្ញាណ ពួកព្រះអរិយៈ ពិចារណា នូវពួកកិលេស ជាអជ្ឈត្តារម្មណ៍ ដែលបុគ្គលលះបង់ហើយ ពិចារណា នូវពួកកិលេស ដែលសង្កត់សង្កិនហើយ នូវពួកកិលេស ដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ... ឃើញច្បាស់ នូវពួកខន្ធ ខាងក្នុង ដែលជាអជ្ឈត្តារម្មណ៍ ជាមិនទៀង ...

អស្សាទេតិ អភិនន្ទតិ តំ អារព្ភ អជ្ឈត្តារម្មណោ រាគោ ... ទោមនស្សំ ឧប្បជ្ជតិ អជ្ឈត្តារម្មណា អជ្ឈត្តា ខន្ធា បុព្វេនិវាសានុស្សតិញាណស្ស យថា-កម្មូបគញាណស្ស អនាគតំសញាណស្ស អាវជ្ជ-នាយ អារម្មណបច្ចយេន បច្ចយោ ។

(៦០៩) អជ្ឈត្តារម្មណោ ធម្មោ ពហិទ្ធារម្ម-ណស្ស ធម្មស្ស អារម្មណបច្ចយេន បច្ចយោ បរេ អជ្ឈត្តារម្មណំ វិញ្ញាណញ្ចាយតនំ ... នេវសញ្ញា-នាសញ្ញាយតនំ បច្ចវេក្ខតិ បរេ អជ្ឈត្តារម្មណំ អជ្ឈត្តំ ទិព្វំ ចក្ខុំ បច្ចវេក្ខតិ ទិព្វំ សោតធាតុំ ... ឥទ្ធិវិធញាណំ ... បុព្វេនិវាសានុស្សតិញាណំ ... យថាកម្មូបគញាណំ ... អនាគតំសញាណំ បច្ចវេក្ខ-តិ អជ្ឈត្តារម្មណេ អជ្ឈត្តេ ខន្ធេ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សតិ ចេតោបរិយញាណេន អជ្ឈត្តា-រម្មណអជ្ឈត្តចិត្តសមង្គិស្ស ចិត្តំ ជានាតិ អជ្ឈត្តា-រម្មណា ពហិទ្ធា ខន្ធា ចេតោបរិយញាណស្ស បុព្វេ-និវាសានុស្សតិញាណស្ស យថាកម្មូបគញាណស្ស អនាគតំសញាណស្ស អាវជ្ជនាយ អារម្មណបច្ច-យេន បច្ចយោ ។

ត្រេកអរ រីករាយ រាគៈ ដែលជាអជ្ឈត្តារម្មណ៍ ប្រារព្ធ នូវខន្ធនោះ ... ទោមនស្ស ទើបកើតឡើង ពួកខន្ធ ខាងក្នុង ដែលជាអជ្ឈត្តា-រម្មណ៍ ជាបច្ច័យ នៃការពិចារណា នូវបុព្វេនិវាសានុស្សតិញាណ យថា-កម្មូបគញាណ និងអនាគតំសញាណ ដោយអារម្មណប្បច្ច័យ ។

(៦០៩) អជ្ឈត្តារម្មណធម៌ ជាបច្ច័យ នៃពហិទ្ធារម្មណធម៌ ដោយអារម្មណប្បច្ច័យ គឺ បុគ្គលដទៃ ពិចារណា នូវវិញ្ញាណញ្ចាយ-តនៈ ជាអជ្ឈត្តារម្មណ៍ ... នូវនេវសញ្ញានាសញ្ញាយតនៈ បុគ្គលដទៃ ពិចារណា នូវទិព្វចក្ខុ ខាងក្នុង ដែលជាអជ្ឈត្តារម្មណ៍ ពិចារណា នូវទិព្វ-សោតធាតុ ... នូវឥទ្ធិវិធញាណ ... នូវបុព្វេនិវាសានុស្សតិញាណ ... នូវយថាកម្មូបគញាណ ... នូវអនាគតំសញាណ ឃើញច្បាស់ នូវពួកខន្ធ ខាងក្នុង ជាអជ្ឈត្តារម្មណ៍ ជាមិនទៀង ជាទុក្ខ ជាអនត្តា ដឹងនូវចិត្ត របស់បុគ្គល អ្នកប្រកបដោយអជ្ឈត្តចិត្តជាអជ្ឈត្តារម្មណ៍ ដោយចេតោបរិយញាណ ពួកខន្ធ ខាងក្រៅ ជាអជ្ឈត្តារម្មណ៍ ជាបច្ច័យ នៃការពិចារណា នូវចេតោបរិយញាណ បុព្វេនិវាសានុស្សតិញាណ យថាកម្មូបគញាណ និងអនាគតំសញាណ ដោយអារម្មណប្បច្ច័យ ។

(២០៦) ពហិទ្ធារម្មណោ ធម្មោ ពហិទ្ធារម្មណស្ស ធម្មស្ស អារម្មណបច្ចយេន បច្ចយោ បរេ ពហិទ្ធារម្មណំ ពហិទ្ធា ទិព្វំ ចក្ខុំ បច្ចវេក្ខតិ ទិព្វំ សោតធាតុំ . . ឥទ្ធិវិធញាណំ . . . ចេតោបរិយញាណំ . . . បុព្វេនិវាសានុស្សតិញាណំ . . . យថាកម្មូបគញាណំ . . . អនាគតំសញាណំ បច្ចវេក្ខតិ បរេ ពហិទ្ធារម្មណេ ពហិទ្ធា ខន្ធេ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សតិ ចេតោបរិយញាណេន ពហិទ្ធារម្មណពហិទ្ធាចិត្តសមង្គិស្ស ចិត្តំ ជានាតិ ពហិទ្ធារម្មណា ពហិទ្ធា ខន្ធា ចេតោបរិយញាណស្ស បុព្វេនិវាសានុស្សតិញាណស្ស យថាកម្មូបគញាណស្ស អនាគតំសញាណស្ស អាវជ្ជនាយ អារម្មណបច្ចយេន បច្ចយោ ។

(២០៧) ពហិទ្ធារម្មណោ ធម្មោ អជ្ឈត្តារម្មណស្ស ធម្មស្ស អារម្មណបច្ចយេន បច្ចយោ ទានំ ទត្វា សីលំ សមាទិយិត្វា ឧបោសថកម្មំ កត្វា តំ បច្ចវេក្ខតិ បុព្វេ សុចិណ្ណានិ បច្ចវេក្ខតិ ឈានា វុដ្ឋហិត្វា ឈានំ បច្ចវេក្ខតិ អរិយា មគ្គា វុដ្ឋហិត្វា មគ្គំ បច្ចវេក្ខន្តិ ផលំ បច្ចវេក្ខន្តិ

(២០៦) ពហិទ្ធារម្មណធម៌ ជាបច្ច័យ នៃពហិទ្ធារម្មណធម៌ ដោយអារម្មណប្បច្ច័យ គឺ បុគ្គលដទៃ ពិចារណា នូវទិព្វចក្ខុ ខាងក្រៅ ជាពហិទ្ធារម្មណ៍ នូវទិព្វសោតធាតុ . . . នូវឥទ្ធិវិធញាណ . . នូវចេតោបរិយញាណ . . . នូវបុព្វេនិវាសានុស្សតិញាណ . . . នូវយថាកម្មូបគញាណ . . . ពិចារណា នូវអនាគតំសញាណ បុគ្គលដទៃ ឃើញច្បាស់ នូវពួកខន្ធ ខាងក្រៅ ជាពហិទ្ធារម្មណ៍ ថាមិនទៀង ជាទុក្ខ ជាអនត្តា ដឹង នូវចិត្ត របស់បុគ្គល អ្នកប្រកបដោយចិត្តខាងក្រៅជាពហិទ្ធារម្មណ៍ ដោយចេតោបរិយញាណ ពួកខន្ធ ខាងក្រៅ ជាពហិទ្ធារម្មណ៍ ជាបច្ច័យ នៃការពិចារណា នូវចេតោបរិយញាណ បុព្វេនិវាសានុស្សតិញាណ យថាកម្មូបគញាណ និងអនាគតំសញាណ ដោយអារម្មណប្បច្ច័យ ។

(២០៧) ពហិទ្ធារម្មណធម៌ ជាបច្ច័យ នៃអជ្ឈត្តារម្មណធម៌ ដោយអារម្មណប្បច្ច័យ គឺ បុគ្គល ឲ្យទាន សមាទាន សីល ធ្វើឧបោសថកម្ម ពិចារណា នូវកុសលនោះ ពិចារណា នូវកុសលទាំងឡាយ ដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ចេញអំពីឈាន ហើយពិចារណា នូវឈាន ព្រះអរិយៈទាំងឡាយ ចេញអំពីមគ្គ ហើយពិចារណា នូវមគ្គ ពិចារណា នូវផល

បហីនេ កិលេសេ បច្ចវេក្ខតិ វិក្ខម្ភិតេ កិលេសេ ... បុព្វេ សមុទាចិណ្ណេ ។ បេ ។ ពហិទ្ធារម្មណំ អជ្ឈត្តំ ទិព្វំ ចក្ខុំ បច្ចវេក្ខតិ ទិព្វំ សោតធាតុំ ... ឥទ្ធិវិធញាណំ ... ចេតោបរិយញាណំ ... បុព្វេនិវាសានុស្សតិញាណំ ... យថាកម្មូបគញាណំ ... អនាគតំសញាណំ ... ពហិទ្ធារម្មណេ អជ្ឈត្តេ ខន្ធេ អនិច្ចតោ ... វិបស្សតិ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ អជ្ឈត្តារម្មណោ រាគោ ... ទោមនស្សំ ឧប្បជ្ជតិ ពហិទ្ធារម្មណា អជ្ឈត្តា ខន្ធា ឥទ្ធិវិធញាណស្ស បុព្វេនិវាសានុស្សតិញាណស្ស យថាកម្មូបគញាណស្ស អនាគតំសញាណស្ស អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ ។

(២០៨) អជ្ឈត្តារម្មណោ ធម្មោ អជ្ឈត្តារម្មណស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ អារម្មណាធិបតិ សហជាតាធិបតិ ។ អារម្មណាធិបតិ អជ្ឈត្តារម្មណំ អជ្ឈត្តំ វិញ្ញាណញ្ចាយតនំ គរុំ កត្វា បច្ចវេក្ខតិ នេវសញ្ញានាសញ្ញាយតនំ គរុំ កត្វា ... អជ្ឈត្តារម្មណំ អជ្ឈត្តំ ទិព្វំ ចក្ខុំ គរុំ កត្វា ... ទិព្វំ សោតធាតុំ ... ឥទ្ធិវិធញាណំ ...

ពិចារណា នូវពួកកិលេស ដែលលះបង់ហើយ ... នូវពួកកិលេស ដែលសង្កត់សង្កិនហើយ ... នូវពួកកិលេស ដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ។ បេ ។ បុគ្គល ពិចារណា នូវទិព្វចក្ខុ ខាងក្នុង ជាពហិទ្ធារម្មណ៍ នូវទិព្វសោតធាតុ ... នូវឥទ្ធិវិធញ្ញាណ ... នូវចេតោបរិយញ្ញាណ ... នូវបុព្វេនិវាសានុស្សតិញ្ញាណ ... នូវយថាកម្មូបគញ្ញាណ ... នូវអនាគតំសញ្ញាណ ... ឃើញច្បាស់ នូវពួកខន្ធ ខាងក្នុង ជាពហិទ្ធារម្មណ៍ ជាមិនទៀង ... ត្រេកអរ រីករាយ រាគៈ ជាអជ្ឈត្តារម្មណ៍ ប្រារព្ធ នូវខន្ធនោះ ... ទោមនស្ស កើតឡើង ពួកខន្ធ ខាងក្នុង ជាពហិទ្ធារម្មណ៍ ជាបច្ច័យ នៃការពិចារណា នូវឥទ្ធិវិធញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

(២០៨) អជ្ឈត្តារម្មណធម៌ ជាបច្ច័យ នៃអជ្ឈត្តារម្មណធម៌ ដោយអធិបតិប្បច្ច័យ គឺអារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺ បុគ្គល ធ្វើ នូវវិញ្ញាណញ្ចាយតនៈ ខាងក្នុង ជាអជ្ឈត្តារម្មណ៍ ឲ្យជាទីគោរព ហើយពិចារណា ធ្វើ នូវនេវសញ្ញានាសញ្ញាយតនៈ ឲ្យជាទីគោរព ... ធ្វើ នូវទិព្វចក្ខុ ខាងក្នុង ជាអជ្ឈត្តារម្មណ៍ ឲ្យជាទីគោរព ... នូវទិព្វសោតធាតុ ... នូវឥទ្ធិវិធញ្ញាណ ...

បុព្វេនិវាសានុស្សតិញាណំ ... យថាកម្មូបគញាណំ ... អនាគតំសញាណំ គរុំ កត្វា ... អជ្ឈត្តារម្មណេ អជ្ឈត្តេ ខន្ធេ គរុំ កត្វា អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា អជ្ឈត្តារម្មណោ រាគោ ... ទិដ្ឋិ ឧប្បជ្ជតិ ។ សហជាតាធិបតិ អជ្ឈត្តារម្មណាធិបតិ សម្បយុត្តកានំ ខន្ធានំ អធិបតិប្បច្ចយេន បច្ចយោ ។

(៦០៩) ពហិទ្ធារម្មណោ ធម្មោ ពហិទ្ធារម្មណស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ សហជាតាធិបតិ ពហិទ្ធារម្មណាធិបតិ សម្បយុត្តកានំ ខន្ធានំ អធិបតិប្បច្ចយេន បច្ចយោ ។

(៦១០) ពហិទ្ធារម្មណោ ធម្មោ អជ្ឈត្តារម្មណស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ អារម្មណាធិបតិ ទានំ ទត្វា សីលំ សមាទិយិត្វា ឧបោសថកម្មំ កត្វា តំ គរុំ កត្វា បច្ចវេក្ខតិ បុព្វេ សុចិណ្ណានិ ... ឈានា វុដ្ឋហិត្វា ... អរិយា មគ្គា វុដ្ឋហិត្វា មគ្គំ ... ផលំ គរុំ កត្វា ... ពហិទ្ធារម្មណំ អជ្ឈត្តំ ទិព្វំ ចក្ខុំ គរុំ កត្វា ... ទិព្វំ សោតធាតុំ ... ឥទ្ធិវិធញាណំ ... ចេតោបរិយញាណំ ... បុព្វេនិវាសានុស្សតិញាណំ ... យថាកម្មូបគញាណំ ...

នូវបុព្វេនិវាសានុស្សតិញ្ញាណ ... នូវយថាកម្មូបគញ្ញាណ ... ធ្វើនូវអនាគតំសញ្ញាណ ឲ្យជាទីគោរព ... ធ្វើ នូវពួកខន្ធ ខាងក្នុង ជាអជ្ឈត្តារម្មណ៍ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ ព្រោះជាអជ្ឈត្តារម្មណ៍ ធ្វើ នូវខន្ធនោះ ឲ្យជាទីគោរព ... ទិដ្ឋិ កើតឡើង ។ ឯសហជាតាធិបតិ គឺ អជ្ឈត្តារម្មណាធិបតិធម៌ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។

(៦០៩) ពហិទ្ធារម្មណធម៌ ជាបច្ច័យ នៃពហិទ្ធារម្មណធម៌ ដោយអធិបតិប្បច្ច័យ បានដល់សហជាតាធិបតិ គឺ ពហិទ្ធារម្មណាធិបតិធម៌ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។

(៦១០) ពហិទ្ធារម្មណធម៌ ជាបច្ច័យ នៃអជ្ឈត្តារម្មណធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ គឺ បុគ្គល ឲ្យទាន សមាទានសីល ធ្វើ ឧបោសថកម្ម ធ្វើ នូវកុសលនោះ ឲ្យជាទីគោរព ហើយពិចារណា នូវពួកកុសល ដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ... ចេញអំពីឈាន ... ព្រះអរិយៈទាំងឡាយ ចេញអំពីមគ្គ (ធ្វើ) នូវមគ្គ ... ធ្វើ នូវផល ឲ្យជាទីគោរព .. ធ្វើ នូវទិព្វចក្ខុ ខាងក្នុង ដែលជាពហិទ្ធារម្មណ៍ ឲ្យជាទីគោរព ... (ធ្វើ) នូវទិព្វសោតធាតុ (ឲ្យជាទីគោរព) .. នូវឥទ្ធិវិធញ្ញាណ ... នូវចេតោបរិយញ្ញាណ ... នូវបុព្វេនិវាសានុស្សតិញ្ញាណ ... នូវយថាកម្មូបគញ្ញាណ ...

អនាគតំសញ្ញាណំ គរុំ កត្វា បច្ចវេក្ខតិ ពហិទ្ធារម្មណេ អជ្ឈត្តេ ខន្ធេ គរុំ កត្វា អស្សាទេតិ តំ គរុំ កត្វា អជ្ឈត្តារម្មណោ រាគោ ... ទិដ្ឋិ ឧប្បជ្ជតិ ។

(៦១១) អជ្ឈត្តារម្មណោ ធម្មោ អជ្ឈត្តារម្មណស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ បុរិមា បុរិមា អជ្ឈត្តារម្មណា ខន្ធា បច្ឆិមានំ បច្ឆិមានំ អជ្ឈត្តារម្មណានំ ខន្ធានំ អនន្តរប្បច្ចយេន បច្ចយោ ។

(៦១២) អជ្ឈត្តារម្មណោ ធម្មោ ពហិទ្ធារម្មណស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ អជ្ឈត្តារម្មណំ ចុតិចិត្តំ ពហិទ្ធារម្មណស្ស ឧបបត្តិចិត្តស្ស អនន្តរប្បច្ចយេន បច្ចយោ អជ្ឈត្តារម្មណំ ភវង្គំ ពហិទ្ធារម្មណាយ អាវជ្ជនាយ អនន្តរប្បច្ចយេន បច្ចយោ អជ្ឈត្តារម្មណា ខន្ធា ពហិទ្ធារម្មណស្ស វុដ្ឋានស្ស អនន្តរប្បច្ចយេន បច្ចយោ អជ្ឈត្តារម្មណំ អនុលោមំ គោត្រភុស្ស អនុលោមំ វោទានស្ស អនុលោមំ ផលសមាបត្តិយា និរោធា វុដ្ឋហន្តស្ស នេវសញ្ញានាសញ្ញាយតនំ ផលសមាបត្តិយា អនន្តរប្បច្ចយេន បច្ចយោ ។

ធ្វើ ឱ្យ អនាគតំសញ្ញាណ ឲ្យជាទីគោរព ហើយពិចារណា ធ្វើ ឱ្យ ពួកខន្ធ ខាងក្នុង ដែលជាពហិទ្ធារម្មណ៍ ឲ្យជាទីគោរព ហើយត្រេកអរ រាគៈ ជាអជ្ឈត្តារម្មណ៍ ធ្វើ ឱ្យខន្ធនោះ ឲ្យជាទីគោរព ... ទិដ្ឋិ ក៏កើតឡើង ។

(៦១១) អជ្ឈត្តារម្មណធម៌ ជាបច្ច័យ នៃអជ្ឈត្តារម្មណធម៌ ដោយអនន្តរប្បច្ច័យ គឺ ពួកខន្ធ ជាអជ្ឈត្តារម្មណ៍ មុន ៗ ជាបច្ច័យ នៃពួកខន្ធ ជាអជ្ឈត្តារម្មណ៍ ក្រោយ ៗ ដោយអនន្តរប្បច្ច័យ ។

(៦១២) អជ្ឈត្តារម្មណធម៌ ជាបច្ច័យ នៃពហិទ្ធារម្មណធម៌ ដោយអនន្តរប្បច្ច័យ គឺ ចុតិចិត្ត ដែលជាអជ្ឈត្តារម្មណ៍ ជាបច្ច័យ នៃឧបបត្តិចិត្ត ដែលជាពហិទ្ធារម្មណ៍ ដោយអនន្តរប្បច្ច័យ ភវង្គៈ ជាអជ្ឈត្តារម្មណ៍ ជាបច្ច័យ នៃអាវជ្ជនៈ ជាពហិទ្ធារម្មណ៍ ដោយអនន្តរប្បច្ច័យ ពួកខន្ធ ជាអជ្ឈត្តារម្មណ៍ ជាបច្ច័យ នៃវុដ្ឋានៈ ដែលជាពហិទ្ធារម្មណ៍ ដោយអនន្តរប្បច្ច័យ អនុលោម ដែលជាអជ្ឈត្តារម្មណ៍ (ជាបច្ច័យ) នៃគោត្រភូ អនុលោម (ជាបច្ច័យ) នៃវោទានៈ អនុលោម (ជាបច្ច័យ) នៃផលសមាបត្តិ នេវសញ្ញានាសញ្ញាយតនៈ របស់បុគ្គល កាលចេញអំពីនិរោធ ជាបច្ច័យ នៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។

(៦១៣) ពហិទ្ធារម្មណោ ធម្មោ ពហិទ្ធារម្មណស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ បុរិមា បុរិមា ពហិទ្ធារម្មណា ខន្ធា បច្ឆិមានំ បច្ឆិមានំ ពហិទ្ធារម្មណានំ ខន្ធានំ អនន្តរប្បច្ចយេន បច្ចយោ ពហិទ្ធារម្មណំ អនុលោមំ គោត្រភុស្ស អនុលោមំ វោទានស្ស គោត្រភុ មគ្គស្ស វោទានំ មគ្គស្ស មគ្គោ ផលស្ស ផលំ ផលស្ស អនុលោមំ ផលសមាបត្តិយា អនន្តរប្បច្ចយេន បច្ចយោ ។

(៦១៤) ពហិទ្ធារម្មណោ ធម្មោ អជ្ឈត្តារម្មណស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ ពហិទ្ធារម្មណំ ចុតិចិត្តំ អជ្ឈត្តារម្មណស្ស ឧបបត្តិចិត្តស្ស អនន្តរប្បច្ចយេន បច្ចយោ ពហិទ្ធារម្មណំ ភវង្គំ អជ្ឈត្តារម្មណាយ អាវជ្ជនាយ អនន្តរប្បច្ចយេន បច្ចយោ ពហិទ្ធារម្មណា ខន្ធា អជ្ឈត្តារម្មណស្ស វុដ្ឋានស្ស អនន្តរប្បច្ចយេន បច្ចយោ ។

(៦១៥) អជ្ឈត្តារម្មណោ ធម្មោ អជ្ឈត្តារម្មណស្ស ធម្មស្ស សមនន្តរប្បច្ចយេន បច្ចយោ សហជាតប្បច្ចយេន បច្ចយោ អញ្ញមញ្ញប្បច្ចយេន បច្ចយោ និស្សយប្បច្ចយេន បច្ចយោ

(៦១៣) ពហិទ្ធារម្មណធម៌ ជាបច្ច័យ នៃពហិទ្ធារម្មណធម៌ ដោយអនន្តរប្បច្ច័យ គឺ ពួកខន្ធ ដែលជាពហិទ្ធារម្មណ៍ មុន ៗ ជាបច្ច័យ នៃពួកខន្ធ ដែលជាពហិទ្ធារម្មណ៍ ក្រោយ ៗ ដោយអនន្តរប្បច្ច័យ អនុលោម ដែលជាពហិទ្ធារម្មណ៍ (ជាបច្ច័យ) នៃគោត្រភូ អនុលោម (ជាបច្ច័យ) នៃវោទានៈ គោត្រភូ (ជាបច្ច័យ) នៃមគ្គ វោទានៈ (ជាបច្ច័យ) នៃមគ្គ មគ្គ (ជាបច្ច័យ) នៃផល ផល (ជាបច្ច័យ) នៃផល អនុលោម ជាបច្ច័យ នៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។

(៦១៤) ពហិទ្ធារម្មណធម៌ ជាបច្ច័យ នៃអជ្ឈត្តារម្មណធម៌ ដោយអនន្តរប្បច្ច័យ គឺ ចុតិចិត្ត ដែលជាពហិទ្ធារម្មណ៍ ជាបច្ច័យ នៃឧបបត្តិចិត្ត ដែលជាអជ្ឈត្តារម្មណ៍ ដោយអនន្តរប្បច្ច័យ ភវង្គៈ ដែលជាពហិទ្ធារម្មណ៍ ជាបច្ច័យ នៃអាវជ្ជនៈ ដែលជាអជ្ឈត្តារម្មណ៍ ដោយអនន្តរប្បច្ច័យ ពួកខន្ធ ដែលជាពហិទ្ធារម្មណ៍ ជាបច្ច័យ នៃវុដ្ឋានៈ ដែលជាអជ្ឈត្តារម្មណ៍ ដោយអនន្តរប្បច្ច័យ ។

(៦១៥) អជ្ឈត្តារម្មណធម៌ ជាបច្ច័យ នៃអជ្ឈត្តារម្មណធម៌ ដោយសមនន្តរប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយអញ្ញមញ្ញប្បច្ច័យ ជាបច្ច័យ ដោយនិស្សយប្បច្ច័យ ជាបច្ច័យ

ឧបនិស្សយបច្ចយេន បច្ចយោ អារម្មណូបនិស្សយោ អនន្តរូបនិស្សយោ បកតូបនិស្សយោ ។ បកតូបនិស្សយោ អជ្ឈត្តារម្មណា អនិច្ចានុបស្សនា ទុក្ខានុបស្សនា អនត្តានុបស្សនា អជ្ឈត្តារម្មណាយ អនិច្ចានុបស្សនាយ ទុក្ខានុបស្សនាយ អនត្តានុបស្សនាយ ឧបនិស្សយបច្ចយេន បច្ចយោ ។

(៦១៦) អជ្ឈត្តារម្មណោ ធម្មោ ពហិទ្ធារម្មណស្ស ធម្មស្ស ឧបនិស្សយបច្ចយេន បច្ចយោ អនន្តរូបនិស្សយោ បកតូបនិស្សយោ ។ បកតូបនិស្សយោ អជ្ឈត្តារម្មណា អនិច្ចានុបស្សនា ទុក្ខានុបស្សនា អនត្តានុបស្សនា ពហិទ្ធារម្មណាយ អនិច្ចានុបស្សនាយ ទុក្ខានុបស្សនាយ អនត្តានុបស្សនាយ ឧបនិស្សយបច្ចយេន បច្ចយោ ។

(៦១៧) ពហិទ្ធារម្មណោ ធម្មោ ពហិទ្ធារម្មណស្ស ធម្មស្ស ឧបនិស្សយបច្ចយេន បច្ចយោ អនន្តរូបនិស្សយោ បកតូបនិស្សយោ ។ បកតូបនិស្សយោ ពហិទ្ធារម្មណា អនិច្ចានុបស្សនា ទុក្ខានុបស្សនា អនត្តានុបស្សនា ពហិទ្ធារម្មណាយ អនិច្ចានុបស្សនាយ ទុក្ខានុបស្សនាយ អនត្តានុបស្សនាយ ឧបនិស្សយបច្ចយេន បច្ចយោ ។

ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺ អនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ដែលជាអជ្ឈត្តារម្មណ៍ ជាបច្ច័យ នៃអនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ដែលជាអជ្ឈត្តារម្មណ៍ ដោយឧបនិស្សយប្បច្ច័យ ។

(៦១៦) អជ្ឈត្តារម្មណធម៌ ជាបច្ច័យ នៃពហិទ្ធារម្មណធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អនន្តរូបនិស្ស័យ បកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺ អនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ដែលជាអជ្ឈត្តារម្មណ៍ ជាបច្ច័យ នៃអនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ដែលជាពហិទ្ធារម្មណ៍ ដោយឧបនិស្សយប្បច្ច័យ ។

(៦១៧) ពហិទ្ធារម្មណធម៌ ជាបច្ច័យ នៃពហិទ្ធារម្មណធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺ អនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ដែលជាពហិទ្ធារម្មណ៍ ជាបច្ច័យ នៃអនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ដែលជាពហិទ្ធារម្មណ៍ ដោយឧបនិស្សយច្ច័យ ។

(៦១៨) ពហិទ្ធារម្មណោ ធម្មោ អជ្ឈត្តារម្មណស្ស ធម្មស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ អារម្មណូបនិស្សយោ អនន្តរូបនិស្សយោ បកតូបនិស្សយោ ។ បកតូបនិស្សយោ ពហិទ្ធារម្មណា អនិច្ចានុបស្សនា ទុក្ខានុបស្សនា អនត្តានុបស្សនា អជ្ឈត្តារម្មណាយ អនិច្ចានុបស្សនាយ ទុក្ខានុបស្សនាយ អនត្តានុបស្សនាយ ឧបនិស្សយប្បច្ចយេន បច្ចយោ ។

(៦១៩) អជ្ឈត្តារម្មណោ ធម្មោ អជ្ឈត្តារម្មណស្ស ធម្មស្ស អាសេវនប្បច្ចយេន បច្ចយោ បុរិមា បុរិមា អជ្ឈត្តារម្មណា ខន្ធា បច្ឆិមានំ បច្ឆិមានំ អជ្ឈត្តារម្មណានំ ខន្ធានំ អាសេវនប្បច្ចយេន បច្ចយោ ។

(៦២០) អជ្ឈត្តារម្មណោ ធម្មោ ពហិទ្ធារម្មណស្ស ធម្មស្ស អាសេវនប្បច្ចយេន បច្ចយោ អជ្ឈត្តារម្មណំ អនុលោមំ គោត្រភុស្ស អនុលោមំ វោទានស្ស អាសេវនប្បច្ចយេន បច្ចយោ ។

(៦២១) ពហិទ្ធារម្មណោ ធម្មោ ពហិទ្ធារម្មណស្ស ធម្មស្ស អាសេវនប្បច្ចយេន បច្ចយោ ពហិទ្ធារម្មណំ អនុលោមំ គោត្រភុស្ស អនុលោមំ វោទានស្ស គោត្រភុ មគ្គស្ស វោទានំ មគ្គស្ស អាសេវនប្បច្ចយេន បច្ចយោ ។

(៦១៨) ពហិទ្ធារម្មណធម៌ ជាបច្ច័យ នៃអជ្ឈត្តារម្មណធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺ អនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ដែលជាពហិទ្ធារម្មណ៍ ជាបច្ច័យ នៃអនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ដែលជាអជ្ឈត្តារម្មណ៍ ដោយឧបនិស្សយប្បច្ច័យ ។

(៦១៩) អជ្ឈត្តារម្មណធម៌ ជាបច្ច័យ នៃអជ្ឈត្តារម្មណធម៌ ដោយអាសេវនប្បច្ច័យ គឺ ពួកខន្ធ ដែលជាអជ្ឈត្តារម្មណ៍ មុនៗ ជាបច្ច័យ នៃពួកខន្ធ ដែលជាអជ្ឈត្តារម្មណ៍ ក្រោយៗ ដោយអាសេវនប្បច្ច័យ ។

(៦២០) អជ្ឈត្តារម្មណធម៌ ជាបច្ច័យ នៃពហិទ្ធារម្មណធម៌ ដោយអាសេវនប្បច្ច័យ គឺ អនុលោម ដែលជាអជ្ឈត្តារម្មណ៍ (ជាបច្ច័យ) នៃគោត្រភូ អនុលោម ជាបច្ច័យ នៃវោទានៈ ដោយអាសេវនប្បច្ច័យ ។

(៦២១) ពហិទ្ធារម្មណធម៌ ជាបច្ច័យ នៃពហិទ្ធារម្មណធម៌ ដោយអាសេវនប្បច្ច័យ គឺ អនុលោម ដែលជាពហិទ្ធារម្មណ៍ (ជាបច្ច័យ) នៃគោត្រភូ អនុលោម (ជាបច្ច័យ) នៃវោទានៈ គោត្រភូ (ជាបច្ច័យ) នៃមគ្គ វោទានៈ ជាបច្ច័យ នៃមគ្គ ដោយអាសេវនប្បច្ច័យ ។

(៦៦២) អជ្ឈត្តារម្មណោ ធម្មោ អជ្ឈត្តារម្មណស្ស ធម្មស្ស កម្មប្បច្ចយេន បច្ចយោ សហជាតា នានា-ខណិកា ។ សហជាតា អជ្ឈត្តារម្មណា ចេតនា សម្បយុត្តកានំ ខន្ធានំ កម្មប្បច្ចយេន បច្ចយោ ។ នានាខណិកា អជ្ឈត្តារម្មណា ចេតនា វិបាកានំ អជ្ឈត្តារម្មណានំ ខន្ធានំ កម្មប្បច្ចយេន បច្ចយោ ។

(៦៦៣) អជ្ឈត្តារម្មណោ ធម្មោ ពហិទ្ធារម្មណស្ស ធម្មស្ស កម្មប្បច្ចយេន បច្ចយោ នានាខណិកា អជ្ឈត្តារម្មណា ចេតនា វិបាកានំ ពហិទ្ធារម្មណានំ ខន្ធានំ កម្មប្បច្ចយេន បច្ចយោ ។

(៦៦៤) ពហិទ្ធារម្មណោ ធម្មោ ពហិទ្ធារម្មណស្ស ធម្មស្ស កម្មប្បច្ចយេន បច្ចយោ សហជាតា នានា-ខណិកា ។ សហជាតា ពហិទ្ធារម្មណា ចេតនា សម្បយុត្តកានំ ខន្ធានំ កម្មប្បច្ចយេន បច្ចយោ ។ នានាខណិកា ពហិទ្ធារម្មណា ចេតនា វិបាកានំ ពហិទ្ធារម្មណានំ ខន្ធានំ កម្មប្បច្ចយេន បច្ចយោ ។

(៦៦២) អជ្ឈត្តារម្មណធម៌ ជាបច្ច័យ នៃអជ្ឈត្តារម្មណធម៌ ដោយកម្មប្បច្ច័យ បានដល់សហជាត និងនានាខណិកៈ ។ សហ-ជាត គឺ ចេតនា ជាអជ្ឈត្តារម្មណ៍ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺ ចេតនា ជាអជ្ឈត្តារម្មណ៍ ជាបច្ច័យ នៃពួកវិបាកក្ខន្ធ ដែលជាអជ្ឈត្តារម្មណ៍ ដោយកម្មប្បច្ច័យ ។

(៦៦៣) អជ្ឈត្តារម្មណធម៌ ជាបច្ច័យ នៃពហិទ្ធារម្មណធម៌ ដោយកម្មប្បច្ច័យ បានដល់នានាខណិកៈ គឺ ចេតនា ជាអជ្ឈត្តារម្មណ៍ ជាបច្ច័យ នៃពួកវិបាកក្ខន្ធ ដែលជាពហិទ្ធារម្មណ៍ ដោយកម្មប្បច្ច័យ ។

(៦៦៤) ពហិទ្ធារម្មណធម៌ ជាបច្ច័យ នៃពហិទ្ធារម្មណធម៌ ដោយកម្មប្បច្ច័យ បានដល់សហជាត និងនានាខណិកៈ ។ សហ-ជាត គឺ ចេតនា ជាពហិទ្ធារម្មណ៍ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺ ចេតនា ជាពហិទ្ធារម្មណ៍ ជាបច្ច័យ នៃពួកវិបាកក្ខន្ធ ដែលជាពហិទ្ធារម្មណ៍ ដោយកម្មប្បច្ច័យ ។

(៦៦៥) ពហិទ្ធារម្មណោ ធម្មោ អជ្ឈត្តារម្មណស្ស ធម្មស្ស កម្មប្បច្ចយេន បច្ចយោ នានាខណិកា ពហិទ្ធារម្មណា ចេតនា វិបាកានំ អជ្ឈត្តារម្មណានំ ខន្ធានំ កម្មប្បច្ចយេន បច្ចយោ ។

(៦៦៦) អជ្ឈត្តារម្មណោ ធម្មោ អជ្ឈត្តារម្ម-ណស្ស ធម្មស្ស វិបាកប្បច្ចយេន បច្ចយោ អា-ហារប្បច្ចយេន បច្ចយោ ឥន្ទ្រិយប្បច្ចយេន បច្ចយោ ឈានប្បច្ចយេន បច្ចយោ មគ្គប្បច្ចយេន បច្ចយោ សម្បយុត្តប្បច្ចយេន បច្ចយោ អត្ថិប្បច្ចយេន បច្-ចយោ នត្ថិប្បច្ចយេន បច្ចយោ វិគតប្បច្ចយេន បច្-ចយោ អវិគតប្បច្ចយេន បច្ចយោ ។

(៦៦៧) ហេតុយា ទ្វេ អារម្មណេ ចត្តារិ អធិបតិយា តីណិ អនន្តរេ ចត្តារិ សមនន្តរេ ចត្តារិ សហជាតេ ទ្វេ អញ្ញមញ្ញេ ទ្វេ និស្សយេ ទ្វេ ឧបនិស្សយេ ចត្តារិ អាសេវនេ តីណិ កម្មេ ចត្តារិ វិបាកេ ទ្វេ ។ សង្ខិត្តំ ។ សព្វត្ថ ទ្វេ

(៦៦៥) ពហិទ្ធារម្មណធម៌ ជាបច្ច័យ នៃអជ្ឈត្តារម្មណធម៌ ដោយកម្មប្បច្ច័យ បានដល់នានាខណិកៈ គឺ ចេតនា ជាពហិទ្ធារម្មណ៍ ជាបច្ច័យ នៃពួកវិបាកក្ខន្ធ ដែលជាអជ្ឈត្តារម្មណ៍ ដោយកម្មប្បច្ច័យ ។

(៦៦៦) អជ្ឈត្តារម្មណធម៌ ជាបច្ច័យ នៃអជ្ឈត្តារម្មណធម៌ ដោយវិបាកប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ ជាបច្ច័យ ដោយឈានប្បច្ច័យ ជាបច្ច័យ ដោយមគ្គប្បច្ច័យ ជាបច្ច័យ ដោយសម្បយុត្តប្បច្ច័យ ជាបច្ច័យ ដោយអត្ថិប្បច្ច័យ ជាបច្ច័យ ដោយនត្ថិប្បច្ច័យ ជាបច្ច័យ ដោយវិគតប្បច្ច័យ ជាបច្ច័យ ដោយអវិគតប្បច្ច័យ ។

(៦៦៧) ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ ២ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ២ ក្នុងនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ ២ ។ សេចក្តីបំប្រួញ ។ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ២

សម្បយុត្តេ ទ្វេ អត្ថិយា ទ្វេ នត្ថិយា ចត្តារិ វិគតេ ចត្តារិ អវិគតេ ទ្វេ ។ ឯវំ គណេតព្វំ ។

អនុលោមំ ។

(៦២៨) អជ្ឈត្តារម្មណោ ធម្មោ អជ្ឈត្តារម្មណស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ សហជាតប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ កម្មប្បច្ចយេន បច្ចយោ ។

(៦២៩) អជ្ឈត្តារម្មណោ ធម្មោ ពហិទ្ធារម្មណស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ កម្មប្បច្ចយេន បច្ចយោ ។

(៦៣០) ពហិទ្ធារម្មណោ ធម្មោ ពហិទ្ធារម្មណស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ សហជាតប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ កម្មប្បច្ចយេន បច្ចយោ ។

(៦៣១) ពហិទ្ធារម្មណោ ធម្មោ អជ្ឈត្តារម្មណស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ កម្មប្បច្ចយេន បច្ចយោ ។

ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងអត្ថិប្បច្ច័យ មានវារៈ ២ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងវិគតប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។ បណ្ឌិត គប្បីរាប់ យ៉ាងនេះជាដើម ។

ចប់ អនុលោម ។

(៦២៨) អជ្ឈត្តារម្មណធម៌ ជាបច្ច័យ នៃអជ្ឈត្តារម្មណធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយកម្មប្បច្ច័យ ។

(៦២៩) អជ្ឈត្តារម្មណធម៌ ជាបច្ច័យ នៃពហិទ្ធារម្មណធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយកម្មប្បច្ច័យ ។

(៦៣០) ពហិទ្ធារម្មណធម៌ ជាបច្ច័យ នៃពហិទ្ធារម្មណធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយកម្មប្បច្ច័យ ។

(៦៣១) ពហិទ្ធារម្មណធម៌ ជាបច្ច័យ នៃអជ្ឈត្តារម្មណធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយកម្មប្បច្ច័យ ។

(៦៣២) នហេតុយា ចត្តារិ នអារម្មណេ ចត្តារិ នអធិបតិយា ចត្តារិ នអនន្តរេ ចត្តារិ ។ សង្ខិត្តំ ។ សព្វត្ថ ចត្តារិ នបុរេជាតេ នបច្ឆាជាតេ នអាសេវនេ ។ សង្ខិត្តំ ។ នវិប្បយុត្តេ ចត្តារិ ។ សង្ខិត្តំ ។ នោអវិគតេ ចត្តារិ ។ ឯវំ គណេតព្វំ ។

បច្ចនីយំ ។

(៦៣៣) ហេតុប្បច្ចយា នអារម្មណេ ទ្វេ ... នអធិបតិយា ទ្វេ នអនន្តរេ នសមនន្តរេ នឧប-និស្សយេ នអាសេវនេ នកម្មេ នោនត្ថិយា នោវិ-គតេ ទ្វេ សព្វត្ថ ទ្វេ ។ ឯវំ គណេតព្វំ ។

អនុលោមបច្ចនីយំ ។

(៦៣៤) នហេតុប្បច្ចយា អារម្មណេ ចត្តារិ ... អធិបតិយា តីណិ អនន្តរេ ចត្តារិ សមនន្តរេ ចត្តារិ សហជាតេ អញ្ញមញ្ញេ និស្សយេ ទ្វេ ឧប-និស្សយេ ចត្តារិ អាសេវនេ តីណិ កម្មេ ចត្តារិ

(៦៣២) ក្នុងនហេតុប្បច្ច័យ មានវារៈ ៤ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៤ ។ សេចក្តីបំប្រួញ ។ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៤ (ដូចគ្នា) ក្នុងនបុរេជាតប្បច្ច័យ នបច្ឆាជាតប្បច្ច័យ និងនអាសេវនប្បច្ច័យ (មានវារៈ ៤) ។ សេចក្តីបំប្រួញ ។ ក្នុងនវិប្ប-យុត្តប្បច្ច័យ មានវារៈ ៤ ។ សេចក្តីបំប្រួញ ។ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៤ ។ បណ្ឌិតគប្បីរាប់ យ៉ាងនេះចុះ ។

ចប់ បច្ចនីយៈ ។

(៦៣៣) ក្នុងនអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះហេតុ-ប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងនអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ នឧបនិស្សយប្បច្ច័យ នអាសេវនប្បច្ច័យ នកម្មប្ប-ច្ច័យ នោនត្ថិប្បច្ច័យ និងនោវិគតប្បច្ច័យ មានវារៈ ២ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ២ ។ បណ្ឌិតគប្បីរាប់ យ៉ាងនេះចុះ ។

ចប់ អនុលោមបច្ចនីយៈ ។

(៦៣៤) ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុ-ប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ អញ្ញមញ្ញ-ប្បច្ច័យ និងនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៤

វិបាកេ ទ្វេ ។ សង្ខិត្តំ ។ សម្បយុត្តេ ទ្វេ អត្ថិយា ទ្វេ នត្ថិយា ចត្តារិ វិគតេ ចត្តារិ អវិគតេ ។ ឯវំ គណេតព្វំ ។

បច្ចនីយានុលោមំ ។

បញ្ហាវារោ និដ្ឋិតោ ។

អជ្ឈត្តារម្មណត្តិកំ ឯកវីសតិមំ និដ្ឋិតំ ។

ក្នុងវិបាកប្បច្ច័យ មានវារៈ ២ ។ សេចក្តីបំព្រួញ ។ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងអត្ថិប្បច្ច័យ មានវារៈ ២ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងវិគតប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។ បណ្ឌិត គប្បីរាប់ យ៉ាងនេះចុះ ។

ចប់ បច្ចនីយានុលោម ។

ចប់ បញ្ហាវារៈ ។

ចប់ អជ្ឈត្តារម្មណត្តិកៈ ទី ២១ ។

សនិទស្សនសប្បដិឃត្តិកំ

បដិច្ចវារោ

(២៣៨) អនិទស្សនសប្បដិឃំ ធម្មំ បដិច្ច អនិទស្សនសប្បដិឃោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា អនិទស្សនសប្បដិឃំ ឯកំ មហាភូតំ បដិច្ច ទ្វេ មហាភូតា ទ្វេ មហាភូតេ បដិច្ច ឯកំ មហាភូតំ អនិទស្សនសប្បដិឃេ មហាភូតេ បដិច្ច អនិទស្សនសប្បដិឃំ ចិត្តសមុដ្ឋានំ រូបំ កដត្តារូបំ ឧបាទារូបំ ផោដ្ឋព្វាយតនំ បដិច្ច ចក្ខាយតនំ សោតាយតនំ ។ អនិទស្សនសប្បដិឃំ ធម្មំ បដិច្ច សនិទស្សនសប្បដិឃោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា អនិទស្សនសប្បដិឃេ មហាភូតេ បដិច្ច សនិទស្សនសប្បដិឃំ ចិត្តសមុដ្ឋានំ រូបំ កដត្តារូបំ ឧបាទារូបំ ផោដ្ឋព្វាយតនំ បដិច្ច រូបាយតនំ ។ អនិទស្សនសប្បដិឃំ ធម្មំ បដិច្ច អនិទស្សនសប្បដិឃោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា អនិទស្សនសប្បដិឃេ មហាភូតេ បដិច្ច អនិទស្សនសប្បដិឃំ ចិត្តសមុដ្ឋានំ រូបំ កដត្តារូបំ ឧបាទារូបំ ផោដ្ឋព្វាយតនំ បដិច្ច អាបោធាតុ ឥន្ទ្រិយំ កពឡិង្ការោ អាហារោ ។

៤៦៣

សនិទស្សនសប្បដិឃត្តិកៈ

បដិច្ចវារៈ

(២៣៨) អនិទស្សនសប្បដិឃធម៌ (ធម៌ ដែលមិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់) អាស្រ័យ នូវអនិទស្សនសប្បដិឃធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ មហាភូត ២ អាស្រ័យ នូវមហាភូត ១ ជាអនិទស្សនសប្បដិឃៈ មហាភូត ១ អាស្រ័យ នូវមហាភូត ២ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាអនិទស្សនសប្បដិឃៈ អាស្រ័យ នូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈ ចក្ខាយតនៈ និងសោតាយតនៈ អាស្រ័យ នូវផោដ្ឋព្វាយតនៈ ។ សនិទស្សនសប្បដិឃធម៌ (ធម៌ ដែលប្រកបដោយការឃើញ ផងប្រកបដោយការប៉ះពាល់) អាស្រ័យ នូវអនិទស្សនសប្បដិឃធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាសនិទស្សនសប្បដិឃៈ អាស្រ័យ នូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈ រូបាយតនៈ អាស្រ័យ នូវផោដ្ឋព្វាយតនៈ ។ អនិទស្សនសប្បដិឃធម៌ អាស្រ័យ នូវអនិទស្សនសប្បដិឃធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាអនិទស្សនសប្បដិឃៈ អាស្រ័យ នូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈ អាបោធាតុ ឥន្ទ្រិយ និងកពឡិង្ការាហារ អាស្រ័យ នូវផោដ្ឋព្វាយតនៈ ។

អនិទស្សនសប្បដិឃំ ធម្មំ បដិច្ច សនិទស្សនសប្ប-
ដិឃោ ច អនិទស្សនអប្បដិឃោ ច ធម្មា ឧប្បជ្ជន្តិ
ហេតុប្បច្ចយា អនិទស្សនសប្បដិឃេ មហាភូតេ
បដិច្ច សនិទស្សនសប្បដិឃញ្ច អនិទស្សនអប្បដិ-
ឃញ្ច ចិត្តសមុដ្ឋានំ រូបំ កដត្តារូបំ ឧបាទារូបំ ផោ-
ដ្ឋព្វាយតនំ បដិច្ច រូបាយតនំ អាបោធាតុ ឥន្ទ្រិយំ
កពឡីង្ការោ អាហារោ ។ អនិទស្សនសប្បដិឃំ
ធម្មំ បដិច្ច អនិទស្សនសប្បដិឃោ ច អនិទស្សន-
អប្បដិឃោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា អនិ-
ទស្សនសប្បដិឃំ ឯកំ មហាភូតំ បដិច្ច ទ្វេ មហា-
ភូតា អាបោធាតុ ច ទ្វេ មហាភូតេ បដិច្ច ឯកំ
មហាភូតំ អាបោធាតុ ច អនិទស្សនសប្បដិឃេ
មហាភូតេ បដិច្ច អនិទស្សនសប្បដិឃញ្ច អនិទស្ស-
នអប្បដិឃញ្ច ចិត្តសមុដ្ឋានំ រូបំ កដត្តារូបំ ឧបា-
ទារូបំ ផោដ្ឋព្វាយតនំ បដិច្ច ចក្ខាយតនំ សោតាយ-
តនំ អាបោធាតុ ឥន្ទ្រិយំ កពឡីង្ការោ អាហារោ ។

សនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ (ធម៌ ដែលមិន
ប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់)ក្តី អាស្រ័យ
នូវអនិទស្សនសប្បដិឃធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ
ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាសនិទស្សនសប្បដិឃៈ
ក្តី ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យ នូវពួកមហាភូត ជាអនិទស្ស-
នសប្បដិឃៈ រូបាយតនៈ អាបោធាតុ ឥន្ទ្រិយ និងកពឡីការាហារ
អាស្រ័យ នូវផោដ្ឋព្វាយតនៈ ។ អនិទស្សនសប្បដិឃធម៌ក្តី អនិ-
ទស្សនអប្បដិឃធម៌ក្តី អាស្រ័យ នូវអនិទស្សនសប្បដិឃធម៌ ទើបកើត
ឡើង ព្រោះហេតុប្បច្ច័យ គឺ មហាភូត ២ ក្តី អាបោធាតុក្តី អាស្រ័យ
នូវមហាភូត ១ ជាអនិទស្សនសប្បដិឃៈ មហាភូត ១ ក្តី អាបោធាតុក្តី
អាស្រ័យ នូវមហាភូត ២ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប
ជាអនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យ នូវ
ពួកមហាភូត ជាអនិទស្សនសប្បដិឃៈ ចក្ខាយតនៈ សោតាយតនៈ អា-
បោធាតុ ឥន្ទ្រិយ និងកពឡីការាហារ អាស្រ័យ នូវផោដ្ឋព្វាយតនៈ ។

អនិទស្សនសប្បដិឃំ ធម្មំ បដិច្ច សនិទស្សនសប្បដិឃោ ច អនិទស្សនសប្បដិឃោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា អនិទស្សនសប្បដិឃេ មហាភូតេ បដិច្ច សនិទស្សនសប្បដិឃញ្ច អនិទស្សនសប្បដិឃញ្ច ចិត្តសមុដ្ឋានំ រូបំ កដត្តារូបំ ឧបាទារូបំ ផោដ្ឋព្វាយតនំ បដិច្ច រូបាយតនំ ចក្ខាយតនំ សោតាយតនំ ។ អនិទស្សនសប្បដិឃំ ធម្មំ បដិច្ច សនិទស្សនសប្បដិឃោ ច អនិទស្សនសប្បដិឃោ ច អនិទស្សនអប្បដិឃោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា អនិទស្សនសប្បដិឃេ មហាភូតេ បដិច្ច សនិទស្សនសប្បដិឃញ្ច អនិទស្សនសប្បដិឃញ្ច អនិទស្សនអប្បដិឃញ្ច ចិត្តសមុដ្ឋានំ រូបំ កដត្តារូបំ ឧបាទារូបំ ផោដ្ឋព្វាយតនំ បដិច្ច រូបាយតនំ ចក្ខាយតនំ សោតាយតនំ អាបោធាតុ ឥន្ទ្រិយំ កពឡីការោ អាហារោ ។

(៦៣៦) អនិទស្សនអប្បដិឃំ ធម្មំ បដិច្ច អនិទស្សនអប្បដិឃោ ធម្មោ ... ហេតុប្បច្ចយា អនិទស្សនអប្បដិឃំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា អនិទស្សនអប្បដិឃញ្ច ចិត្តសមុដ្ឋានំ រូបំ

សនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនសប្បដិឃធម៌ក្តី អាស្រ័យ នូវអនិទស្សនសប្បដិឃធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាសនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនសប្បដិឃៈក្តី អាស្រ័យ នូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈ រូបាយតនៈ ចក្ខាយតនៈ សោតាយតនៈ អាស្រ័យ នូវផោដ្ឋព្វាយតនៈ ។ សនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ក្តី អាស្រ័យ នូវអនិទស្សនសប្បដិឃធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាសនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យ នូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈ រូបាយតនៈ ចក្ខាយតនៈ សោតាយតនៈ អាបោធាតុ ឥន្ទ្រិយ និងកពឡីការាហារ អាស្រ័យ នូវផោដ្ឋព្វាយតនៈ ។

(៦៣៦) អនិទស្សនអប្បដិឃធម៌ អាស្រ័យ នូវអនិទស្សនអប្បដិឃធម៌ ... ព្រោះហេតុប្បច្ច័យ គឺ ខន្ធ៣ ក្តី ចិត្តសមុដ្ឋានរូប ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យ នូវខន្ធ១ ជាអនិទស្សនអប្បដិឃៈ

ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា អនិទស្សនអប្បដិឃញ្ច
ចិត្តសមុដ្ឋានំ រូបំ បដិសន្ធិក្ខណេ អនិទស្សនអប្ប-
ដិឃំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា អនិទស្ស-
នអប្បដិឃញ្ច កដត្តារូបំ ទ្វេ ខន្ធេ ... ខន្ធេ បដិច្ច
វត្ថុ វត្ថុំ បដិច្ច ខន្ធា អាបោធាតុំ បដិច្ច អនិទស្សន-
អប្បដិឃំ ចិត្តសមុដ្ឋានំ រូបំ កដត្តារូបំ ឧបាទារូបំ
អាបោធាតុំ បដិច្ច ឥន្ទ្រិយំ កពឡិង្ការោ អាហា-
រោ ។ អនិទស្សនអប្បដិឃំ ធម្មំ បដិច្ច សនិទស្ស-
នសប្បដិឃោ ធម្មោ ... ហេតុប្បច្ចយា អនិទស្ស-
នអប្បដិឃេ ខន្ធេ បដិច្ច សនិទស្សនសប្បដិឃំ ចិត្ត-
សមុដ្ឋានំ រូបំ បដិសន្ធិក្ខណេ អនិទស្សនអប្បដិឃេ
ខន្ធេ បដិច្ច សនិទស្សនសប្បដិឃំ កដត្តារូបំ អា-
បោធាតុំ បដិច្ច សនិទស្សនសប្បដិឃំ ចិត្តសមុដ្ឋានំ
រូបំ កដត្តារូបំ ឧបាទារូបំ អាបោធាតុំ បដិច្ច រូបា-
